D59678

TSL

K. 224

Khoem Chhum ខឹម ឈុំ

អនុ ពលទ ទី. 43 ក្រុម [illegible]

ចាប់ - 13-8-78

35 ans

K224

ចម្លើយ របស់ឈ្មោះ ខឹម . ឈុំ

អនុរបទាតំបន់ ៤៣ ភូមិភាគកណ្តាល

Khem Chhum

13-8-78 ចាប់ 35 ans

កំ ពី

ប្រវត្តិ សកម្មភាពក្បត់ក្បាប់

18.9.78

ធ្វើនៅថ្ងៃទី ១៨.៩.១៩៧៨

សូមរាយការជូនអង្គការពីប្រវត្តសកម្មភាព

ក្បត់របស់ខ្ញុំ

---

ខ្ញុំឈ្មោះខឹម ឆុំ អាយុ៣៥ឆ្នាំ ភេទប្រុស មានគ្រួសាររួចហើយ ឈ្មោះម៉ី- សេងទៅតួ នាទីមុនអង្គការចាប់លេខាស្រុកស្ទោង អនុលេខាតំបន់៤៣ ភូមិភាគកណ្តាល ។

ស្រុកកំណើតនៅភូមិដំណាក់ស្នួល ឃុំព្រៃក្អួង ស្រុកឈូក តំបន់៣៥ ភាគនិរតី ។ ឪពុកឈ្មោះខឹម- កែម ស្លាប់ ម្តាយឈ្មោះកឹម- ហេន ស្លាប់ ។ មានបងប្អូន ៥នាក់ប្រុស៣ ស្រី២ ប្រុសឈ្មោះអ៊ិល ស្លាប់ ។

តាំងពីតូចមកខ្ញុំរស់នៅក្នុងបន្ទប់ឪពុកម្តាយ ដល់អាយុ ១៣ ឆ្នាំ ទៅនៅអង្គជំ ឃុំព្រៃក្អួង ស្រុកឈូកតំបន់៣៥ ដល់អាយុ១៥ ឆ្នាំ ខ្ញុំបួសនៅវត្តនោះ រួចពីវស្សាទៅរៀននៅវត្តអង្គចៅពញា មួយវស្សា រួចត្រឡប់មកផ្ទះវិញ ។

១៩៥៨ ខ្ញុំសឹកមកធ្វើស្រែ កាប់ឈើអារឈើលក់ នៅភូមិកំណើត ក្នុងការរកស៊ីនេះខ្ញុំមានការទាក់ទងជាមួយឈ្មោះចិន ជាប្រធានភូមិដំណាក់ស្នួល និង ឈ្មោះឆែម អនុប្រធានភូមិដំណាក់ស្នួល ទាំងពីរនាក់នេះមិនត្រូវជាសាច់ញាតិនឹងខ្ញុំទេ នៅក្នុងភូមិជាមួយគ្នា ។ ដោយខ្ញុំខ្វះខាតគេជួយឧបត្ថម្ភ គោរទេះ និងដឹកបណ្តូលឈើ- ពូឆែមធាត់ឲ្យអូសដោយឥតយកថ្លៃ ឯពូចិនឲ្យគោរទេះដឹកអត់យកថ្លៃដែរ ដូច្នេះការទាក់ទងនេះតាំងពីខ្ញុំសឹកមក រហូតដល់ឆ្នាំ ១៩៦០ ពេញកំពុងកាប់ឈើយកទៅលក់ជាមួយគ្នា ពូចិន និង ពូឆែម និយាយជាមួយខ្ញុំថាអ្នកឯងបើខ្វះអញចឹងមិនងាយរកស៊ីចិញ្ចឹមគ្រួសារទេ បើអ្នកឯងចង់រកស៊ីបាន ល្អត្រូវធ្វើតាមខ្ញុំ ខ្ញុំសួរថាធ្វើអ្វីទៅពូ ពូឆែមថាការងារនេះស្រួលទេឲ្យតែអ្នកឯងព្រមធ្វើគិញ ដើរស៊ើបការខ្មែរក្រហម បើអ្នកឯងធ្វើការបានល្អគង់តែបានលុយចាយទេ ពេញនោះដោយមានមនោសញ្ចេតនាជំពាក់ជំពិនទៅលើគេផង ខ្ញុំក៏យល់ព្រមធ្វើគិញ រួចពូចិនពូឆែមណែនាំបន្ថែមថា បើអ្នកឯងយល់ព្រមហើយអ្នកឯងដើរស៊ើបការឲ្យខ្ញុំ តែត្រូវរក្សាការសម្ងាត់ បើមិនរក្សាការសម្ងាត់ទេ ដើរស៊ើបការមិនបានទេ ឯកម្លាំងគិញដែលត្រូវទាក់ទងតាមភូមិនេះ មានឈ្មោះប៊ុត ឈ្មោះកប ឈ្មោះដីន ឈ្មោះអ៊ុម- ក្នុងភូមិដំណាក់ស្នួល ឯនៅភូមិព្រៃវែងមានឈ្មោះនុត និង ឈ្មោះចេន ជាកម្លាំង

ពិញ្ញ ជើងថែទី ។

១ - កប   អតីតៈកសិករ នៅឆ្នាំ ១៩៧៥ ធ្វើប្រធានរោងចា ស្រុកត្រាំកក់ បច្ចុប្បន្នក្លាប់មិនបាន ។

២ - ជិន   អតីត មេ១០ខ្ទង់ ឆ្នាំ ៧៣ ធ្វើគណៈកងធំនៅភូមិដំណាក់ស្នួល បច្ចុប្បន្នពុំដឹង

៣ - នុត   អតីតធ្វើជាងទទេះ បច្ចុប្បន្នអនុមេខា ស្រុកកំពង់ត្រាច តំបន់ ៣៥

៤ - ចេន   មេកងអាណាព្យាបាលភូមិ បច្ចុប្បន្នមេខា ស្រុកឈូក អនុមេខាតំបន់ ៣៥ ។

១៩៦១ ពូចិន និង ពូថែម បាននាំខ្ញុំ និង កប ទៅជួបលោកឃឹម ពីវ នៅក្នុងនៅលើផ្ទះ ពូថែម គឺឈ្មោះថា និង ឈ្មោះខាំផុំ ការជួបនេះគ្រាន់តែឱ្យខ្ញុំស្គាល់ លោកទាំងពីរជាមេពិញ ជាថែខ្មែរៈរបស់អាណក្ដិ ៥ ទំនាវា និងលោកថែកវ - នៅក្រុមចប់ អេះ ភ្នំពេញ ។ បើយលោកទាំងពីរនេះជាអាចារ្យ នៅវត្តអុណ្ណាលោមភ្នំពេញ ។ ពូចិនបានប្រាប់ឱ្យលោកដឹងថាខ្ញុំ និង កប នេះ ជាក្មាក់ជារ - ជើបការដែលពូចិនកសាងបាន ។ លោកថាបានអប់រំប្រូវែទក្សាការលេខាត់ឱ្យបានល្អ ។ លោកថាប្រាប់ថាពូចិន និង ពូថែម ឱ្យទាក់ទងនិងលោកផ្ទាល់ បើយលោកថា និង លោខាំង ទាក់ទងទៅអាណក្ដិ ៥ ទុំ-នវា និង លោថែកវ នៅខេត្តអេះភ្នំពេញ ។ នៅដើមឆ្នាំ ១៩៦៣ ពូចិន និង ថែម លើកថាលោកខាំផុំ នាំខ្ញុំទៅ ឱ្យលោកថែកវ និង អាណក្ដិ ៥ ស្គាល់នៅវត្តបក្រីទឹង ។ ពេលនោះ អាណក្ដិ ៥ ទុំនវា ឱ្យស្គាល់ខែប្រមកបង្កប់ក្នុងបដិវត្តមានឈ្មោះតាស៊ី និង ប៊ុត បន្ទាប់មកអាណក្ដិ ៥ទុំនវាឱ្យបើបុគ្គលិកទទួលនាមមួយឱ្យខ្ញុំយកទៅឱ្យតាស៊ី ។

១៩៦៣ ដំផែល សកម្មភាពខ្ញុំ -កប -ចេន -ជិន -នុត -ថែម និង ចិន បាននាំទាហាន- នៅបន្ទាយស្អូកំបុតមកអុកទឡ្ហកទាតត្បាត់កន្លែងតាម៉ុកនៅឲ្យប្ដុតាដង់ និង កន្លែង - បងបុក បងត្រិន នៅត្រពាំងតាព្រាំ ចំនួន២-៣ដងគ្រាន់តែបានកំទេចកន្លែងអើមនុស្ស កំទេចមិនបានទេ ។

ចុងឆ្នាំ១៩៦៣ ពូចិន និងពូថែមបាននាំខ្ញុំយកសំបុត្រឱ្យទទួលនាមរបស់អាណក្ដិ៥ ទុំ នវា និងលោកគ្រូថែកវទៅរកជួបឈ្មោះប៊ុតនិងតាស៊ី នៅក្រាំងលាវ ទៅដល់ខ្ញុំ ទាំងពានាក់ជួបឈ្មោះប៊ុតពូចិនក៏ឲ្យវកតាស៊ី ឈ្មោះប៊ុតអត់ប្រាប់យើងខ្ញុំទេខ្ទប ពូចិនឱ្យលើ, បុត្រឱ្យទទួលនាមរបស់លោកគ្រូថាទៅឈ្មោះប៊ុត ។ ខ្ញុំចាំអស់រយៈមួយថ្ងៃបានតាស៊ី មកពីភ្នំពេញទៅទើបជួបគ្នា តាស៊ីសួរពួកខ្ញុំថា យ៉ាងមេចទៅឈាភាពការខាងពិង

ធ្វើការបានអីខ្លះ  ពូចិនឆ្លើយថាមិនទាន់កសាងកម្លាំងគិញក៏មិនទាន់បានច្រើនដែរ -តាស៊ីណែនាំថាការកសាងកម្លាំងគិញត្រូវកសាងថែមទៀតព្រោះសភាពការបដិវត្តលឿនថ្ងៃតឹងតែងត្រូវខំរក្សាការសម្ងាត់  ត្រូវជឿងសាត់ខ្សែទាក់ទងគ្នា ហើយត្រូវទាក់ទងឱ្យជាប់បើមានការអ្វីដែលផលប្លាយដល់ខ្សែគិញរាយការណ៍ឱ្យខ្ញុំដឹងផង ហើយសេចក្តីរាយការណ៍ផ្សេងៗត្រូវរាយការណ៍ឱ្យខ្ញុំ មួយខែមួយដង ។

ក្រោយពីជួបតាស៊ីមកខ្ញុំកសាងកម្លាំងបាន ៣ នាក់ នៅភូមិដំណាក់ស្នួលមានឈ្មោះតេង -ឈ្មោះញ៉ឹម -ឈ្មោះជឿង ទាំង៣ នាក់នេះត្រូវជាបងប្អូនជីដូនមួយរបស់ខ្ញុំ ។

នៅចុងឆ្នាំ ១៩៦៣ ដដែលខ្ញុំឱ្យញ៉ឹម -ជឿង -តេងទៅស៊ើបការនៅភូមិព្រៃខ្មៅ ក្នុងឃុំព្រែក្អុង ទៅបាន៣ ថ្ងៃញ៉ឹម -តេង -ជឿង ត្រឡប់មករាយការណ៍-ឱ្យខ្ញុំវិញ ខ្ញុំក៏ទៅរាយការណ៍ឱ្យពូចិន និងពូឆែម ទាក់ទងនាំទាហាននៅបន្ទាយព្រែក្អុងមកចាប់ឈ្មោះលាត់ និងឈ្មោះអែមទៅកំទិចចោល ដែលនាំប្រជាជនទៅចូលព្រៃប្រឆាំងនិងរដ្ឋាភិបាលលន់ណុល ។

នៅដើមឆ្នាំ១៩៦៥ អ៊ុំនុតនិង ពូចេន កសាងកម្លាំងបាន២ នាក់ឈ្មោះទៀន-ឈ្មោះប៊ិ នៅក្នុងភូមិព្រៃវែងជាមួយគ្នា ។

១៩៦៤ -៦៥ ដល់ ឆ្នាំ១៩៦៧ ខ្សែទាក់ទងរបស់ខ្ញុំនៅតែដដែល ឯសកម្មភាពតាមផ្ទានប្រជាជននៅក្នុងភូមិដំណាក់ស្នួលយកអង្ករឱ្យខ្មែរក្រហម និងសម្លាប់ខ្មែរក្រហមអស់ ៣ នាក់ដែលទាក់ទងយកអង្ករពីប្រជាជន (មានឈ្មោះលិន ឈ្មោះស៊ុំ ឈ្មោះផែន)។ ដើមឆ្នាំ ១៩៦៨ មានកុប្បកម្មនៅបន្ទាយផ្សុងពេលនោះអាសក្តិ ៥ទុំនរា បានចាត់តាំងកម្លាំងគិញឱ្យមកបង្កប់ខ្លួនក្នុងបដិវត្តដោយខ្សែលោកថាត្រូវមកភ្នំពេញ មុនពេលលោកថា ទៅលោកថាឱ្យតាស៊ី ហៅខ្ញុំ -ពូចិន -ពូឆែម -អ៊ុំនុត និង ពូចេនទៅជួបលោកថា នៅវត្តស្រែចែង ។ ពេលជួបជុំគ្នាតាស៊ីនិយាយថាអញ្ជើញមិត្តទាំងអស់មកដើម្បីរៀបចំខ្សែគិញធ្វើការក្នុងជួរបដិវត្តឱ្យបានត្រឹមត្រូវតទៅមុខទៀត ។-ព្រោះតាមខ្ញុំពិនិត្យសកម្មភាពធ្វើការកន្លងមកបានល្អនេះតាមមិត្ត ចិន រាយការណ៍មាន បងនុត មិត្តចេន និងមិត្តឃុំ ដែលមានលក្ខណៈនិងសកម្មភាពគ្រប់គ្រាន់ ពីមុនមិត្តជាភ្នាក់ងារគិញមិត្តធ្វើការបានល្អ ឥឡូវខ្ញុំបញ្ចូលមិត្តជា សេ អ៊ី អា វិញក៏រឹតតែ-បាន ។ សេ អ៊ី អា វាមានសិទ្ធិធំជាងគិញ ហើយវាដំណែងឱ្យសង្គមលោកសេរីផងហើយអ្នកណាធ្វើការបានល្អ ហើយបង្កប់ក្នុងបដិវត្តបានយូរគឺបានធ្វើធំ ប៉ុន្តែសមាជិក សេ អ៊ី អា នេះចូលហើយត្រូវរក្សាការសម្ងាត់ជាងគិញទៅទៀត ។ តើមិត្តទាំងអស់យល់ស្រប

ឬទេ ខ្ញុំ អ៊ុំនុត ពូចេន ឆ្លើយយល់ព្រមចូលជាសមាជិក សេ អ៊ី អា ។
វិធីធ្វើបញ្ចូលសេអ៊ីអា តាស៊ីចងធង់សេ អ៊ី អា នៅចំពីមុខខ្ញុំ ឈើខៀវឆ្នូត៥ ។

- តាស៊ី ធ្វើគណៈអធិបតី
- លោកគ្រូថា គ្រូវ៉ាន់ ជាសាក្សី
- ពូចិន ពូឆែម អ្នកនាំចូល

សមាជិកត្រូវចូល សេ អ៊ី អា មាន អ៊ុំនុត ពូចេន និង ខ្ញុំ ។ ពេលនោះមានគោរពទង់សេ អ៊ីអា ហើយសូត្រប្រវត្តិរូបខ្ញុំទាំងពួ នាក់ ។ រួចតាស៊ីថែរនាំថា ហើយមានជាសមាជិកសេ អ៊ី អាដូច្នេះត្រូវបង្កប់បំពីរ័ត្តហើយកសាងកម្លាំងសេ អ៊ី អាធ្វើសកម្មភាពសេ អ៊ី អា ប្រឆាំងដាច់ខាតជាមួយពួកកុម្មុយនិស្ត ។

ក្រោយពីចូលលោកគ្រូថា ក៏ទៅភ្នំពេញ ឯតាស៊ីផ្អាននិង ប្រាប់ពីកម្លាំងសេ អ៊ី អា ឱយខ្ញុំស្គាល់ គឺមានឈ្មោះ :

១ - ផែន អតីតរកស៊ីកាប់ឈើលក់ បច្ចុប្បន្នលេខាតំបន់៤៣ភាគកណ្តាល
២ - វ៉ន អតីតកងអស្សាស្សាភូមិ បច្ចុប្បន្នលេខាតំបន់តាកែវ និរតី
៣ - ឈេន អតីតបួស បច្ចុប្បន្នប្រធានមន្ទីរស្រុកឈូក តំបន់៣៥ និរតី
៤ - ឈយ អតីតកងទ័ពស្រ្វះ បច្ចុប្បន្នលេខាស្រុកកំពត តំបន់៣៥
៥ - ដួង អតីតកងទ័ពស្រ្វះ បច្ចុប្បន្នប្រធានយោធាស្រុកកំពត
៦ - អ៊ិត អតីតកម្មករលេវី បច្ចុប្បន្នអនុប្រធានយោធាស្រុកកំពត
៧ - រិន អតីតសិស្សថ្នាក់ទី៧ បច្ចុប្បន្នលេខាតំបន់៣ភូមិភាគពាយ័ព្យ
៨ - យុត អតីតកសិករ បច្ចុប្បន្នលេខាស្រុកកំពង់សៀម តំបន់៤១

ខែ២ - ឆ្នាំ១៩៦៨ ដខែដលខ្មែរក្រហមធ្វើកុប្បកម្មនៅបន្ទាយអូរកំបុត ពេលនោះតាស៊ីចាត់តាំងខ្ញុំ ពូចិន ពូឆែម តាប៊ិត មិត្តជុំន និងមិត្តកប មកបង្កប់ខ្លួនក្នុងកុប្បកម្មធ្វើ - សកម្មភាព ហើយមួយចំណែកទៀតមានពូចេន និង ពូនុតទៅបន្ទាយវត្តព្រែក្លង ។ សកម្មភាពពួកខ្ញុំប្រឆាំងក្នុងកុប្បកម្មពេលប្រជាជនបែកទៅពូឆែម ទៅទាក់ទងអាលែប សំ នៅបន្ទាយអូរកំបុតមុន ឱយខ្ញុំ ពូចិន តាប៊ិតមិត្តជីន មិត្តកបបែកក្បួនជាមួយប្រជាជន ទៅជិតដល់បន្ទាយអូរកំបុត ខ្ញុំចេញក្រៅមុនធ្វើឱយទាហានឃើញ - អាទាហានក្នុងបន្ទាយឃើញក៏បាញ់ទៅប្រជាជន ក្នុងកុប្បកម្មក៏រត់មកផ្ទះអស់ទៀង -

ខ្លួន ។ ក្រោយពីកុប្បកម្មមកខ្ញុំបានចូលបដិវត្ត គឺមកបង្កប់ខ្លួននៅមន្ទីរស្លាក់ការរបស់តំបន់៣៥ នៅត្រពាំងឈ្លាំង ពេលខ្ញុំមកផ្ទះម្ដងពុកខ្ញុំតែងអប់រំគ្រួសារ ខ្ញុំឱ្យឈប់ការពីបដិវត្ត អប់រំឱ្យស្អប់បដិវត្តឱ្យស្រឡាញ់របបឯកជន ហើយខ្ញុំមិនឱ្យគ្រួសារខ្ញុំឧបត្ថម្ភជាអង្ករជាសម្ភារៈផ្សេងៗទៅឱ្យបដិវត្តទេ ហើយគ្រួសារខ្ញុំតាមខ្ញុំបន្តបន្ទាប់ដែរ ។

នៅ ចុងឆ្នាំ១៩៦៨ តាស៊ីបានចុះពីមន្ទីរវល្លិ ជាមួយបងផែន មិត្តណយ មិត្តរិន-មកមន្ទីរស្មឹងឈើទាលពក ពេលនោះក៏បានជួបខ្ញុំ ពូចេន អ៊ុំនុតពូចិន ពូឆែម មិត្តជឹម និងបងវ៉ន តាស៊ីនិយាយថាឥឡូវពួកយើងទាំងអស់នេះ មកធ្វើការនៅក្នុងព្រៃ-ឯពួកយើងភូមិមានខ្លះដែលរំខានផ្ដល់ជីវិតឱ្យយើង ។ឥឡូវឯងយកលាងកម្លាំងសេរីអាខ្ញុំចាត់មិត្តទាំងអស់ឱ្យទៅនៅតាមខ្សែកក្នុងជួរបដិវត្ត គឺមិត្តវ៉ន-ចេន-នុតទៅមន្ទីរជើមអំពិលភ្នំតាម៉ៅ ។ ឈុំ-ចិន-ឆែម-ជឹម នៅមន្ទីរត្រពាំងឈ្លាំង ឯ មិត្តផែន-រិនណយ នៅជាមួយខ្ញុំ ។ តាស៊ីណែនាំថា យើងត្រូវបង្កប់ខ្លួនក្នុងជួរបដិវត្តធ្វើការអូសទាញទាំងយុទ្ធជនទាំងកម្មាភិបាលឱ្យបានមកខាងយើង ។

ឆ្នាំ១៩៦៩ ខ្ញុំ ពូចិន ពូឆែម កសាងកម្លាំងបាន៤នាក់មានឈ្មោះ ៈ

១- បូរ អតីតកសិករ បច្ចុប្បន្នលេខាអនុសេនាធំក្នុងវរៈសេនាធំលេខ៧០២ របស់ភូមិភាគនិរតី ។

២- អេង អនុលេខាវរៈសេនាតូចលេខ៤០៣ ស្លាប់ឆ្នាំ៧៥ ។

៣- ម៉ី អតីតៈកសិករ ត្រូវជាក្មួយអាលក្ខិស្មុននៅបន្ទាយអូរកំបុត-បច្ចុប្បន្នប្រធានរោងចក្រជីរវ៉ុស្សិតនៅភ្នំទូកមាសរបស់អង្គការ ។

៤- អឹង អតីតៈសិស្សថ្នាក់ទី៧ បច្ចុប្បន្នប្រធានមន្ទីរតំបន់តាកែវ ។

ក្រោយពីកសាងកម្លាំងហើយខ្ញុំបានទៅរាយការណ៍ឱ្យបងវ៉ន ។

ឆ្នាំ១៩៦៩ ៨ខែដែលប្រហែលក្នុងចុងឆ្នាំ តាស៊ី ត្រូវអង្គការហៅផ្លាស់មកអមលាំងគាត់បានឱ្យខ្ញុំ-ពូចិន-ពូឆែម-បងវ៉នទៅជួបនៅមន្ទីរឈើទាលពក តាស៊ីនិយាយថាអង្គការផ្លាស់ខ្ញុំ មិត្តវ៉ីនទៅ[illegible]មិត្តចាប[illegible]ត្រូវវិញ ដូច្នេះនៅពេលនេះធ្វើការទាក់ទងគ្នាបណ្ដើរនាក់ចុះ ហើយរាយការណ៍ទៅតាមរយៈមិត្តចាប ព្រោះមិត្តចាបក៏ដូចខ្ញុំដែរ បើមានការអីគង់តែខ្ញុំឱ្យមិត្តចាបដឹងទេ ។

ឆ្នាំ ១៩៧០ ក្រោយរដ្ឋប្រហារ អង្គការឱ្យកម្មាភិបាល និងយុវជនចុះមកភូមិ-ឃុំវិញ ក្នុងពេលនោះតាចាប ក៏ចុះមកពីភ្នំឱរ៉ាល់ មកសង់មន្ទីរនៅភ្លឹកខាងលិចវត្តស្រែវែង ។ តាចាបក៏បានឱ្យពួកខ្ញុំទៅជួបនឹងគាត់ មានបងផែន-បងវ៉ន-ពូសែម ពូនុត-ពូរចន-ពូចិន-មិត្តរិន-មិត្តណយ-និងមិត្តយុត ។ តាចាបនិយាយថា ខ្ញុំឱ្យមិត្តទាំងអស់មកនេះ ដើម្បីស្គាល់គ្នាទៅវិញទៅមក ក្រោយពីតាស៊ីទៅអមលាំង តាស៊ីបានប្រាប់ខ្ញុំ ឱ្យស្គាល់មិត្តទាំងអស់ជាខ្សែរទាក់ទងរបស់គាត់ ផងទៀត មិត្តទាំងអស់ទទួលស្គាល់ខ្ញុំ ហើយការកិច្ចសេអ៊ីអា ត្រូវរាយការឱ្យខ្ញុំ ឬឱ្យមិត្ត-ផែនក៏បានដែរ ។ យើងជួបគ្នាដំបូងនេះ ដើម្បីស្គាល់គ្នា និងទទួលផែនការពីខ្ញុំយកទៅធ្វើតាមមុខព្រួញនិមួយៗ ។ ផែនការដែលយើងត្រូវធ្វើគឺ សំខាន់កសាងកម្លាំងសេអ៊ីអា បង្កប់ក្នុងទីផ្ចិតក្នុងបដិវត្ត តាមផ្លូវកម្មាភិបាល តាំងពីភូមិ-ឃុំឡើងទៅ ទើបកសាងកម្លាំងយើងខ្លាំង វាយបដិវត្តបានក្នុងពេលខាងក្រោយ ។ ម្យ៉ាងទៀត ត្រូវយកចិត្តទុកដាក់នាំទប់កម្លាំងបដិវត្ត ជាបន្តបន្ទាប់ដែរ គឺឱ្យបដិវត្តធំទេវីនលូតលាស់បាន និងបំផ្លាញគោក្របី ស្រូវអង្ករ ហើយនឹងបង្កបង្កើត-ការអុកឡុកតាមមូលដ្ឋាន ធ្វើយ៉ាងណាឱ្យប្រជាជនស្អប់បដិវត្ត ។ ក្រោយពីទទួលផែនការពីតាចាបហើយ ហើយខ្ញុំក៏យកផែនការនេះទៅអនុវត្ត នៅខែ ៧ ឆ្នាំ ១៩៧០ដដែល ខ្ញុំកសាងកម្លាំងបាន ២នាក់ គឺឈ្មោះ ញ៉ិប-និងមឿង ទន្ទឹមនេះ ខ្ញុំបានចាត់តាំង ឱ្យប្រជាជនទាំងក្មេង ទាំងចាស់ច្រៀងលេងចំរៀងសង្គម ចាស់បង្កើតការសប្បាយ តាមភូមិនិមួយៗ ពេលនោះមានលែងសីលធម៌ យុវជន-យុវនារី ធ្វើឱ្យប្រជាជនស្រឡាញ់របបចាស់ ហើយដើម្បីឱ្យស្អប់បដិវត្តជាបណ្តើៗ និងក៏ឱ្យយុវជន-យុវនារី ចង់ទៅសមរភូមិ ដើរទៅដើម្បីនឹករត់មកក្រោយវិញ ។ ក្រោយមកខ្ញុំ-តាញ៉ិប-បានទៅជួបមិត្តណយ នៅមន្ទីរស្រុកកំពត ខ្ញុំសួរថា សភាពការខាងមិត្តណយយ៉ាងម៉េច តាំងពីទទួលផែនការពីតាស៊ីមក មិត្តណយ ឆ្លើយថា សភាពការណ៍ខាងខ្ញុំសព្វថ្ងៃនេះ ចលនាយុវជន-យុវនារី ឱ្យរត់ទៅតំបន់ខ្មាំងទៅបានចំនួន ១០០នាក់ដែរ ។ ហើយបញ្ជូនស្រូវអង្ករជួកគោក្របី ឱ្យទៅក្រុង-កំពតរាល់ថ្ងៃដែរ ឯកម្លាំងកសាងបានពីរនាក់ឈ្មោះឌិន និងនារីម្នាក់ឈ្មោះ ណេន។

ខ្ញុំបានសួរទៅមិត្តឈឿនវិញថា បើខាងមិត្តងាយបញ្ជោញមនុស្សទៅតំបន់ខាងជើងចាំ បញ្ជូនកម្លាំង១០០នាក់ពីខាងខ្ញុំផងបានទេ មិត្តឈឿនឆ្លើយថាបាទ ។ ខ្ញុំតាញ៉ឹបត្រឡប់មកវិញបំផុសយុវជន-យុវនារីបាន១០០ នាក់ហើយក៏បញ្ជូនទៅក្រុងកំពត-តាមរយៈមិត្តឈឿន ។ ប្រហែលខែ១០-ឆ្នាំ១៩៧០ តាចាបបានហៅប្រជុំនៅផ្ទះបងវ៉ែន មានបងវ៉ែនមិត្តយុត ពូចេន-តុម-សៀង និងលាន តាចាបបាននិយាយថាខ្ញុំហៅមិត្តយើងមកឱ្យរាយការណ៍ពីសកម្មភាពកន្លងមក បើយើងមករាយការណ៍តែម្នាក់ៗ-យើងក្តាប់សភាពការណ៍ទៅវិញ នៅមកមិនបានដូចផ្ទះលមិត្តយើងរាយការណ៍ម្នាក់ម្តង បងវ៉ែនរាយការណ៍ថាកសាងកម្លាំងបាន៣នាក់ឈ្មោះបឿន ឈ្មោះភឿន ឈ្មោះរាប បាននាំស្រូវអង្ករគោក្របីជ្រូកមាន់ចំនួន ៥០០ ក្បាលទៅស្រុកយួនតាមរយៈមិត្តតុមស្រុកគិរីវង់ បង្កត់បាយប្រជាជន បង្កើតចោរព្រៃបានមួយក្រុមមានឈ្មោះគិន-ផាមេ ឱ្យដើរលួចឆក់គោក្របីបងប្អូន ។បំផុសប្រជាជនឱ្យរត់ទៅស្រុក-យួនអស់ ១០០ គ្រួសារ ។ បងរឹន រាយការណ៍ថា កសាងកម្លាំងបាន៣ នាក់ ៖ ឈ្មោះចន ឈ្មោះសាត ឈ្មោះវ៉ៃ សកម្មភាពការពារព្រំដែនបើកដៃឱ្យប្រជាជនរត់ទៅស្រុកយួន ចាត់តាំងឱ្យយុវជនបាញ់គ្រាប់លេង ។

បេន រាយការណ៍ថាមិនដោះស្រាយជីវភាពប្រជាជន និង មិនបញ្ជូនស្បៀងទៅសមរភូមិ លុះរាយការណ៍ចប់តាចាបនិយាយថា នៅខាងមិត្តវ៉ែន ត្រូវបន្តទាក់ទងជាមួយយួនបើមានប្រជាជនចង់ទៅយួនឱ្យទៅចុះ ទន្ទឹមយើងមិត្តវ៉ែនឯងត្រូវបន្តការកសាងកម្លាំងយើងថែមទៀត ហើយចាត់តាំងមនុស្សយើងក្នុងវត្តអំណែកបតាមមុខព្រួញនិមួយៗ-ខាងចោរព្រៃត្រូវបង្កើតឱ្យបានច្រើនជាងនេះទៀតលំរាបឆាននៅសមរភូមិក្រោយ ហើយត្រូវទាក់ទងមិត្តជាខាងតំបន់២៥ ផង ។ ឯខាងមិត្តឈុំ មិត្តរិនក៏ដូចគ្នាដែរ ។ ១៩៧១ ខ្ញុំកសាងកម្លាំងបានពីនាក់ឈ្មោះដួប និងឈ្មោះក្លា ។ ហើយខ្ញុំធ្វើសកម្មភាពរួមជាមួយ តាមឿង តាញ៉ឹម តាក្លា និងដួប គឺបង្កត់ឫយប្រជាជន-នៅឃុំស្ទឹងកែវដោយមិនដោះស្រាយហើយលើកពាក្យលោកឱ្យប្រជាជនម្នាក់ៗការខ្លួនឯង ។ ក្នុងឆ្នាំ៧១ នេះដែរខ្ញុំចាត់តាំងតាក្លាឱ្យទៅបំផុសប្រជាជននៅខាងតាកែនគឺនាំប្រេងបត់សង្គមចាស់ និងចលនាឱ្យប្រជាជនចូលធ្វើចោរព្រៃ

អស់១៥ នាក់ទាក់ទងចោទថាព្រៃឈ្មោះព្រាំ សាន់ ឱ្យអ្នកទៀតកលួចគោក្របីមានទាំង អង្គការបស់ប្រជាជន ។ ម្យ៉ាងទៀតខ្ញុំបំផុសប្រជាជនឱ្យរៀបការកូនដែលមាន អាយុ ១៦-១៧ ឆ្នាំឡើងទៅក៏ឱ្យអង្គការវិលយកទៅលមភូមិមុខ ។

ខែ២ ឆ្នាំ១៩៧១ តាចាប គាត់មកផ្ទះខ្ញុំ គាត់សួរខ្ញុំពីពីសភាពការកន្លែងខ្ញុំ ខ្ញុំរាយការជូនគាត់នូវសកម្មភាពដែលបានធ្វើខាងលើ រួចតាចាបគាត់ថា ត្រូវអង្គការឱ្យធ្វើទំនប់គ្រប់ឃុំ ស្រុក ទូទាំងតំបន់៣៥ នូវច្នះខាងមិត្តធ្វើពីរចុះនៅអូរអា ត្រៅក់ទឹរនិងអូរអង្គ្រង តែធ្វើមេចក៏ឱ្យដាច់ទឹក ហើយប្រើប្រាស់ស៊ីម៉ង់ឱ្យច្រើន ក្រោយទទួលផែនការពីតាចាបមក ខ្ញុំចាត់តាំងឱ្យតាមៀស តាដួប តាក្លា និងតាញ៉ិបទៅកាប់ទំនប់ទាំងពីរ ហើយក៏ចាត់តាំងកម្លាំងប្រជាជនចំនួន៥០០០នាក់ទៅធ្វើទំនប់នេះ ចំណាយស៊ីម៉ង់២៥០០បាវ លក្ខណៈធ្វើគឺយកស៊ីម៉ង់ទៅចាក់ដើម រាបដំបូកគល់មិនគាស់កាប់ចេញ អស់រយៈ៣ខែរួចហើយ ទំនប់នេះត្រូវទឹកជាបន្តបន្ទាប់អត់បានទឹកប្រើទេ ។ ខែ១១ ឆ្នាំ៧១ ក្រោយពីធ្វើសកម្មភាពមកបងផែន និង បងតុំ បងសៀងបងសោនមកជួបខ្ញុំនៅកោះសោ្ល ខ្ញុំសួរបងទៅណា បងផែនថាទៅកន្លែងតាចាប តែផ្លៀតចូលកន្លែងមិត្តឯងបន្តិច ម្ដើរាយការពីសកម្មភាពមិត្តឯងកន្លងមកមើ៉ ខ្ញុំថាកន្លងមកអត់ដែលបានទាក់ទងខែ្ង ខាងតំបន់២៥ទេ កន្លែងតាចាបក៏មិនដែលទៅផង កម្លាំងកសាងបានមិត្តដួប និង មិត្តក្លា តែផែនការតាចាបដាក់ឱ្យនោះទាំងបង្កត់ឲ្យប្រជាជនទាស់ធ្វើឱ្យមិនសំរេចផែនការបស់អង្គការធ្វើទំនប់នៅអូរត្រាក់ទឹរ និង អូរអង្គ្រង ៗ រួចបងផែនឱ្យខ្ញុំជូនទៅ ទៅកន្លែងតាចាប ពេលទៅដល់កន្លែងតាចាបនៅភ្លឹក ក៏ឃើញមិត្តយយមកជួបតាចាបដែរ តាចាបសួរថាថ្ងៃនេះគេមកអ្វីកន្លែងខ្ញុំច្រើនម្លេះ បងផែនឆ្លើយថាមកជំរាបតាពីរឿងមិត្តតុំ មិត្តសៀង មិត្តសោន់ដែលខ្ញុំទៅជួបបងជា ២៥ គាត់ឱ្យទេសនាមមក ត្រូវខ្ញុំទាក់ទងបានហើយនាំមកជួបចាដើម្បីស្គាល់ និងរាយជូនតារឿងទាក់ទងជួនយប់បានទៅទៀតហើយព្រោះអង្គការបិតព្រាំដែន ហើយឱ្យយោធាដើចាប់ចោទព្រៃ និង ចាប់កម្លាំងឈើងនៅស្រុកអង្គជ័យ ។

បងផែនរាយការចប់ តាចាបសួរមិត្តយាយថា ម៉េចទៅ មិត្តយាយទាក់ទងអាសក្តិ -
ចាន់ ស៊ិគុល ក្រុងកំពតមកគេប្រជាជនបានទៅភូមិណាខ្លះ មិត្តយាយរាយការថា
គេបានឃុំកណ្ដាលមួយ ។ ខ្ញុំក៏រាយការឱ្យតាចាបអំពីសកម្មភាពខ្ញុំបានធ្វើទៅទំ
នប់អូរត្រាក់ជ័រ និង អូរអង្គ្រែង ។ តាម៉ីវបណែនាំថា ខាងមិត្តឃុំ និង មិត្តយាយ
ត្រូវរួមជាមួយកម្លាំងមិត្តប្រឆាំងនិងការធ្វើទំនប់នៅស្ទឹងកោះស្លា ឥឡូវអង្គការ
ឱ្យធ្វើនៅត្រង់កំពង់លោកដើម្បីបានទឹកចាក់ពេញមួយតំបន់៣៥ តែយើងទៅ-
ធ្វើនៅស្ទឹងតាមប៉ិវិញដើម្បីពន្យារពេលកុំឱ្យបានទឹកប្រើងាយ ។ ឯខាងមិត្តផែន
មានភារៈកិច្ចរកវិធីសម្លាប់តាម៉ុក ដោយទាក់ទងមិត្តជា ។ រួចតាចាបក៏
បានឱ្យទេសនាមកម្លាំងឱ្យដឹងទៀតនៅតំបន់២៥ និងភូមិភាគបស្ចិមមានឈ្មោះ ៖

១- សៀន អតីតធ្វើស្រែ បច្ចុប្បន្នអនុលេខាតំបន់២៥ និរតី
២- ផុន អតីតកម្មករសេរី បច្ចុប្បន្នលេខាស្រុកកោះធំតំបន់២៥
៣- បូ នារី អតីតរកស៊ីលក់ដូរ បច្ចុប្បន្នលេខាស្រុកកៀនស្វាយ ២៥
៤- ជឹម អតីតធ្វើស្រែ បច្ចុប្បន្នអនុលេខាស្រុកកោះធំ ២៥
៥- អោប អតីតលក់ដូរ បច្ចុប្បន្នប្រធានពាណិជ្ជកម្មរបស់តំបន់២៥
៦- លន អតីតកាប់ឈើលក់ បច្ចុប្បន្នលេខាស្រុកស្ទឹងត្រង់ ៤២
៧- ញឹក មុនអង្គការចាប់លេខាតំបន់ ៣២ ភាគបស្ចិម
៨- អាម អតីតបួស បច្ចុប្បន្នអនុលេខាតំបន់៣២ ភាគបស្ចិម
៩- សាត់ អតីតក្ដាប់មិនបាន បច្ចុប្បន្នប្រធានមន្ទីរតំបន់៣២
១០- កែវ អតីតបួស មុនអង្គការចាប់លេខាស្រុកឧត្ដុង្គ
១១- ម៉ែន អតីតសិស្សថ្នាក់ទី៣ មុនអង្គការចាប់អចិន្ត្រៃតំបន់៣១
១២- ខែត អតីតក្ដាប់មិនបាន លេខាស្រុកកំពង់ត្រឡាចលើតំបន់៣១
១៣- កប អតីតបួស មុនអង្គការចាប់លេខា ស្រុកតាលៀងប្លៀ
១៤- ចាន់ មុនអង្គការចាប់លេខាតំបន់៣១

ក្រោយពីទទួលផែនការតាចាបមក ខ្ញុំ មិត្តយាយ ពូចេន មិត្តយុត និង អ៊ុំនុត ជួប
គ្នាលើកផែនការពន្យារពេលធ្វើទំនប់តាមផែនការតាចាប់ មិត្តយាយចាត់តាំងពូ-
នុត អ៊ុំចេនខាងដឹកស្រែក មិត្តយាយនិងខ្ញុំ ខាងទំនប់និងលំហង់ទ្វារទឹក ។ បានឯកភា
ពគ្នារួចខ្ញុំមិត្តយាយជំរុញប្រជាជនឱ្យកាប់ឈើធំៗ ខាងលំហង់ដាក់ដីខ្សាច់ និងថ្ម
ច្រើនប៉ុលដល់មិនជាប់ ខាងពូចិន អ៊ុំនុត នាំប្រជាជនដឹកប្រទាញយកកន្លែងថ្មធំៗគឺ-

ជើងភ្នំអចមីទនេព្រាង ដឹកបានចិត្តហើយគ្រឿកម្លាំងច្រើន ម្រ៉ាងទៀតនាំគ្នាលេង
សីលធម៌ បរិយាកាសប្រចបួកប្រចបល់មិនល្អបានធ្វើការងារទេនាំឱ្យទំនប់មិនសំរេច -
ហើយបានខូចជាមួយនារីណេកវ និង នារីភាន់ហើយកសាងឱ្យបំផុសយុទ្ធជន -នារីលេង
សីលធម៌នៅក្នុងការដ្ឋានប្រទ្បាយ ឯការដ្ឋានទំនប់បណ្តោយឱ្យប្រជាជនធ្វើទាំ
ងយប់ទាំងថ្ងៃហើយហូបបបរព្រឹកល្ងាចខ្ញុំនាំគ្នាលេងសីលធម៌មិនគិតដោះស្រាយ ។
ទំនប់យកស៊ីម៉ង់ត្រាន់ទៅតើតពុំល្អដីទឹកឡើងមកដាក់ពីបីសារ ។ ក្រោយមកបង
ផែនទៅជួបខ្ញុំនៅទំនប់ ខ្ញុំរាយការឱ្យគាត់ពីសកម្មភាពរួច បងផែនបានណែនាំ -
ថាមិត្តឯងត្រូវធ្វើទ្វារទឹកមិនបាច់ដឹកគ្រឹះទំរាំទេដើម្បីទឹកធ្លាក់ទៅលើងទាំងអស់តែ -
ម្តងក៏ឱ្យបានទឹកប្រើ ហើយបាតទំនប់មិនបាច់គាស់ឫសឈើអីទេ ហើយយកគល់ឈើទទឹងពុ
ដាក់បណ្តោយបាតទំនប់ ឯព្រែកដីកដីកឱ្យចោតឱ្យដីធ្លាក់វាយប់ ឬកិនប្រជាជន
កំពុងដឹកដែរ ។ ក្រោយពីទទួលការណែនាំរបស់បងផែនមកខ្ញុំយកទៅណែនាំប្អូន
ធ្វើតាមដោយអត់ដឹកគ្រឹះហើយចាក់ស៊ីម៉ងត៍ដីតែម្តង ចំណែកខាងព្រែកដីកខ្ញុំឱ្យ -
ពូចេន អ៊ុំនុត ដឹកឱ្យចោតធ្លាក់ដីកិនប្រជាជនស្លាប់និងបាក់ដៃជើងទៀតផង ។
ហើយប្រជាជនមួយចំនួនធំថ្នាក់និងមាត់ក៏មិនដោះស្រាយជីវភាព ឱ្យធ្វើការ -
ទាំងគ្រុន ទាំងឈឺទៀត ។ រហូតមកដល់ខែ២-ឆ្នាំ១៩៧២ ខ្ញុំបានទៅផ្ទះបង -
ផែន ដើម្បីរកក្រណាត់ភ្លេង ទៅដល់ក៏ជួបបងផែនញបានសួរពីសកម្មភាពខ្ញុំនៅ
ទំនប់កោះស្លា ខ្ញុំឆ្លើយថាខ្ញុំធ្វើតាមការណែនាំរបស់បង ហើយទំនប់នេះក៏មិនទាន់
រួចដែរព្រោះបាក់ ១ លើកដា ២ លើកហើយ បងផែនថាមិត្តឯងដែលជួបតាស៊ី
ទេ ខ្ញុំថាអត់ដែលបានជួបទេ ជួបតែតាចាប ខ្ញុំសួរវិញថាចុះបងឯងដែលទាក់
ទងទៅខាងបស្ចិមដែរ បងផែន ថាខ្ញុំដែលទៅមួយដងដែរ ខ្ញុំថាមេចទៅ -
ខ្សែខាងបស្ចិម... បងផែនថាខ្ញុំទៅជួបតាស៊ីគាត់ប្រាប់ខ្ញុំថាខ្សែនៅបស្ចិមនេះ -
មានគ្រប់ស្រុកទាំងអស់ឱ្យតែលេខាស្រុក តែលេខាតំបន់៣១គឺមិត្តសារុន មិនមែន
មែនខ្សែយើងទេ ហើយតំបន់៣២មិត្តពាង្វឹក កោះកុងមិត្តរ៉ន កម្លាំងខាងយើង ។-
ខ្ញុំសួរចុះផែនការសម្លាប់តាម៉ុកបងធ្វើបានយ៉ាងមេចដែរ បងផែនថាកន្លងមកតា -
ម៉ុក មកផ្ទះខ្ញុំមិនដែលហូបបាយសោះ ការប៉ុនប៉ងឱ្យគាត់ពុំអត់ហូបទេ គាត់ហូបខ្លួនឯង -
ហើយការធ្វើដំណើររបស់គាត់មិនទាន់ទេ បងផែនណែនាំខ្ញុំថាមិត្តឯងក៏រកវិធី -

សម្លាប់ដែរ ព្រោះគាត់ទៅមើលចំណប់កោះស្លា ញឹកឃើញលបបញ្ជូនស្រូវផង ខ្ញុំថា ចុះខាងតំបន់២៥ បងដែលទៅទាក់ទងបងជាដែរ ខ្ញុំដែលទៅសួររឿងផែនការសម្លាប់តាម៉ុក ដែរតែបងជាថាមិនដឹងរកវិធីអ្វីដែរ ។ បន្ទាប់មកបងផែនប្រាប់ពីសកម្មភាពបងជាឱ្យខ្ញុំដឹងថា បងជាកន្លងមកគាត់បញ្ចេញស្រូវអង្ករទៅជូនអស់-៦០០០ ថាំងហើយ គោ ក្របី អស់ប្រហែល ៣០០ ក្បាល ឯនាំប្រជាជនទៅស្រុកយួនអស់ ១០០ គ្រួសារ ។ រៀបខ្ញុំធ្វើដំណើរមកបងផែនផែនាំថាមិត្តត្រូវកសាងកម្លាំងឱ្យបានច្រើន ហើយត្រូវទាក់ទងទាហានខាងចក្រស៊ីម៉ង់ឬបន្ទាយកំពតឱ្យបានដាប់ដែរស្រែអ្នកឃើងធ្វើសកម្មភាព ។ ក្រោយពីជួបបងផែនមក នៅក្នុងខែ ២ ១៩៧២ ដដែលខ្ញុំ និង តាសៀបានទៅទាក់ទងអាលក្ខិណាខនៅបន្ទាយខេឯចក្រស៊ីម៉ង់មករកប្រជាជនចាមនៅភូមិទីព្រឡូងចូលបន្ទាយខាងចក្រទឹងបានចំនួន៥០គ្រួសារ និងក្របី៥០ នឹមដែរ ។ នៅតាកែនតាកាលបំផុសប្រជាជនរត់ចូលធ្វើចោរព្រៃអស់៣ភូមិ គឺភូមិខ្ពប ភូមិដៃស្តីណា និង ភូមិត្រពាំងក្តី ។ នៅឆ្នាំ ៧២ដដែលខ្ញុំកសាងកម្លាំងបានឈ្មោះជឿន អតីតកូនសិស្សថ្នាក់ទី២ បច្ចុប្បន្នអនុប្រធានខាងម៉ាស៊ីនអាល្បើរបស់តំបន់៣៥ ឈ្មោះឃឿង អតីតកសិករភ្នំជ្រូក បច្ចុប្បន្នប្រជាជននៅភូមិត្រពាំងម្នាស់ ។

ខែ១៣ ឆ្នាំ៧២ តាស៊ី បងវ៉ន បងអានចុះពីអមលាំងមករកគ្រាប់កាំភ្លើងកន្លែងឯតាចាប ហើយក៏ហៅខ្ញុំ ពូចេន បងផែន និង មិត្តយ៉េយទៅជួប តាស៊ីនិយាយ-ថាខ្ញុំសុំជំរាបមិត្តទាំងអស់ឱ្យស្គាល់មិត្តអាន ដែលខ្ញុំកសាងបានតាំងពីឆ្នាំ១៩៦៤ មកឥឡូវឱ្យមកធ្វើការកន្លែងនេះ គឺទៅធ្វើការនៅខាងតំបន់២៥ ជាមួយមិត្តជា តាស៊ីបន្តទៀតថា សភាពការបដិវត្តបច្ចុប្បន្ននេះកំពុងល្បឿនទៅមុខពិសេសខាង-ផ្នែកយោធា គឺវាយះឈ្លើពួកលន់ណុល តែយើងទាំងអស់ឃើញអញ្ចឹងហើយ មិត្តទាំង-អស់កុំភាំលអស់សង្ឃឹមឱ្យសោះ ព្រោះកម្លាំងយើងនៅមានច្រើនទៀតដែលបង្កប់ក្នុងជួរបដិវត្តនៅគ្រប់តំបន់ គ្រប់ភូមិភាគ និងក្រសួងមន្ទីរ ក៏មានកម្លាំងយើង-បង្កប់នៅទីនេះដែរ តែកម្លាំងដែលមានបណ្តើងមិនទាន់គ្រប់គ្រាន់ទេយើងបន្ថែមការកសាងកម្លាំងយើងឱ្យបានច្រើនជាងនេះទៅទៀតងាយយើងបង្កប់ក្នុងជួរ-បដិវត្ត បើឥឡូវមិនបានវាយបដិវត្ត ពេលចប់សង្គ្រាមហើយក៏យើងវាយ យើង-

ព្រៀមវាយទ្បូត ។ ដូច្នេះយើងត្រូវទាក់ទងគ្នាឱ្យជាប់ ពីតំបន់២៥មក តាកែវ កំពត ឬទៅភូមិភាគបស្ចិម ។ តែមិត្តទាំងអស់នៅកន្លែងនេះត្រូវទាក់ទងមិត្តចាប ផ្ទាល់ មិត្តចាបមានភារៈកិច្ចទាក់ទងខ្ញុំទៅបស្ចិម ។ តាស៊ីនិយាយទៀតថាមិត្ត-អានទៅទទួលយោធាតំបន់ ២៥ ទាក់ទងនិងមិត្តជា មិត្តចាប មិត្តផែន ដែរៗ

ខែ៤-៧២ ខ្ញុំកសាងបានមិត្តព្រាយ មិត្តបឿន និងមិត្តជៃ ។ ដល់ខែ៥ ខ្ញុំទៅជួប-ពូចេនទៅស្រុកឈូក បំណងរកលាក់បិតនដ្ឋល់ ពូចេនសួរខ្ញុំថាមិត្តឃុំឯងដែលទៅតំបន់ ២៥ ទេ ខ្ញុំថាអត់ដែលទៅទេ ពូចេនសួរថាបុះកម្លាំងកសាងបានប៉ុន្មានហើយ-ខ្ញុំថាបាន ៣ នាក់ដែរ ពូចេនប្រាប់ថាខ្ញុំបានមិត្តម៉េង ១ មិត្តឡាយ ១ នៅ-ខាងបងគុតបានឈ្មោះផន ឈ្មោះគយ ឈ្មោះគីវ ខ្ញុំសួរថាសកម្មភាពបានអ្វីហើយពូចេន ឆ្លើយថាចលនាយុទ្ធជនបាន ៣០ នាក់ និងគេ ត្រូវកនាំទៅឱ្យសក្តិ៤ចាន់សំអុល-នៅក្រុងកំពត តាមរយៈមិត្តណយ ។

ខែ៦ ខែ៨ ជារយៈធ្វើស្រែ ខ្ញុំ តាញ៉ឹប តាក្តា តាមៀង តាជួប មិត្តឃឿន មិត្តសារឹម មិត្តព្រាយ បានធ្វើសកម្មភាពបង្វែងមាគ៌ា ធ្វើស្រែមិនដាក់ជីវ មិនរើក ស្លឹ យកស្រូវដាក់ស្រែជ៏រទៅ យកស្រូវធ្ងន់ដាក់ស្រែគោក សាបលាយស្រូវធ្ងន់ និង ស្រាល ។ ខែ៨-៧២ ខ្ញុំទៅរកពូជស្រូវនៅផ្ទះមិត្តណយ ក៏ជួបបងផែនមករកអំ-បិលកន្លែងមិត្តណយ ដែរ បងផែនសួរខ្ញុំទៅណា ខ្ញុំមករកពូជស្រូវ ហើយគាត់សួរ មិត្តណយវិញថាសភាពការទាក់ទងសក្តិ៤សំអុលនៅកំពតយ៉ាងមេចហើយ មិត្តណយ រាយការថាចាត់តាំងមិត្តជួបទៅទាក់ទងសក្តិ៤សំអុល គេមកកេណ្ឌនាវីស្រែអំបិល នៅត្រង់សេះសបាន ៤០ នាក់ដែរ និងព្យាយឱ្យសក្តិ៤សំអុលផ្លាស់ដាក់ការផ្ដាន ក្បាលទមាស ។ ពេលបងផែនត្រឡប់ទៅវិញគាត់ប្រាប់ថាមិត្តឃុំ ឯងនិងមិត្ត-ណយទាក់ទងលោកសក្តិ៤ សំអុល ចុះខ្ញុំទាក់ទងសក្តិ៤កន្លះហ៊ុនឌីម នៅបន្ទាយវត្តឈើ ទាលជាមួយកម្លាំងខ្ញុំកសាងបានឯណុះ ហើយ ។ ខែ១០តាចាបមកប្រាប់ខ្ញុំថា៣-៤ថ្ងៃ-ទៀតអង្គការវាយបន្ទាយចក្រីទីងហើយ ឃុំឯងទៅឱ្យលោកសក្តិ៣ លាខន វត់ទៅ ក្រុងកំពតផង ហើយមិត្តឃុំ ត្រូវទំការពារបន្ទាយនេះផង ។

ខែ១១-៧២ កងទ័ពបដិវត្តន៍វាយបន្ទាយចក្រីទីង ខ្ញុំបានចាត់តាំងតាសៀឱ្យទៅ-ប្រាប់អាសក្តិ៣លាខន ដកខ្លួនរត់ទៅក្រុងកំពត ហើយឱ្យមិត្តណយទាក់ទងសក្តិ៤ចាន់-

ឃុំស្រុល ចាំផ្លូវ ៗ ថ្ងៃ៥ ខែ ១១ ឆ្នាំ ១៩៧២ វេលាម៉ោង ៤ មុនពេល ចូលសមរភូមិ តាចាប មកដាក់ផែនការឱ្យខ្ញុំចាំសម្លាប់អ្នករបួស មិត្តវិន បញ្ជា-សមរភូមិចាំដកថយពេលខ្មាំងបាញ់ទ័ព ឬ គប់គ្រាប់ ដើម្បីកងទ័ពសំរាក ហើយនោះ ខាងកំពតផ្លូវដាក់ ៗ ម៉ោង ៤ ព្រឹកក្នុងថ្ងៃទី ៩ ដែលចាប់វាយបន្ទាយ បក្រីទឹង រហូតថ្ងៃម៉ោង ១ ឬ ម៉ោង ២ ទាហានគប់គ្រាប់ដាប់ទាំងសល្បៀងពេល នេះមិត្តវិន ធ្វើតាមការណែនាំរបស់ តាចាប គឺនាំទ័ពមកសំរាកប្រហែល១គីឡូ ពីបន្ទាយ ដកផុតបាញ់កន្លះម៉ោង មិត្តឈយ ឱ្យទាហាននៅក្រុងកំពតផ្លូវ ដាក់ ខែ១ ត្រៀមត្រូវរបួស និង ស្លាប់ទ័ព ខ្ញុំបានចាត់តាំង តាឃឿន មិត្តសារឹមនិងមិត្ត ទីដ ធ្វើសកម្មភាពពេលដែលរបួស អ្នកដែលត្រូវរបួសធ្ងន់សម្លាប់ចោលតាមផ្លូវ ៗ បន្ទាយបក្រីទឹងទាហានជំនួយពីកំពតបានទៀងវិញ តាចាប ឱ្យមិត្តវិនដកកងទ័ព-ចេញ ដើម្បីកុំឱ្យតា ម៉ុក ចាប់ការខ្សោយ ៗ

ឆ្នាំ ១៩៧៣ ខែ ៣ អង្គការធ្វើសន្និបាតភាគ នៅមន្ទីរភូមិភាគត្រពាំងធំ ពេលនោះខ្ញុំក៏បានទៅចូលរួមធ្វើសន្និបាតដែរ ៗ ពេលអង្គការសំរាកពីនុទេស នាម បងផែនបានហៅខ្ញុំទៅអង្គុយលេងជាមួយនឹងបងជា បងអាន - និងបង សៀន នៅក្រោមដើមឈើមួយ បន្ទាប់និយាយនេះនិយាយនោះរួច បងជា -ក៏និយាយថា តាមសន្និបាតលើកទៀង អង្គការដាក់ផែនការឱ្យធ្វើសហករណ៍ មិត្តផែនឯងពេញចិត្តឬទេ បងផែនឆ្លើយថា ខ្ញុំមិនពេញចិត្តដែរ បងអាន បញ្ជាក់ថា ចុះ បើហើយមិនពេញចិត្ត បងឯងថាម៉េចទៅវិញ បងជាឆ្លើយថា តាមខ្ញុំទៅជួបចាប មុនពេលមកសន្និបាតនេះ តាចាបប្រាប់ខ្ញុំថាឱ្យខំកសាងកម្លាំង បង្កប់តាមភូមិ- ឃុំ ដើម្បីដល់ពេលអង្គការចាត់តាំងសហករណ៍ថ្ងៃមុខ កម្លាំងហើយនៅតាមភូមិ - ឃុំ - ស្រាប់ ងាយទប់ទល់ផែនការធ្វើសហករណ៍របស់អង្គការបាន បងអាន សួរបង ជា ទៀតថា តាចាបមានប្រាប់បងយ៉ាងម៉េចទៀតទេ បងជាឆ្លើយថា តាចាប គាត់ថាបើមានការអី ឱ្យទៅទាក់ទងនឹងគាត់ ដើម្បីគាត់ណែនាំថែម ឬឱ្យ

មិត្តដែលមកជួបនឹងខ្ញុំក៏បាន បងផែនសួរបង ផាថា បងឯងនៅតំបន់ ២៥ ដែល-បាននៅទាក់ទងតា ស៊ី ដែរ បងផា ថាបាននៅម្តងដែរ តាមតាស៊ី ថា ឲ្យរឿងនៅខាងភូមិភាគបស្ចិម អង្គការចាប់ខ្លួនហើយ គាត់ថាឱ្យរឿងទាក់ទង គ្នាប្រយ័ត្នបន្តិច ។

ចប់សន្និបាតហើយ ខ្ញុំត្រឡប់មកស្រុកកោះស្លាវិញ នៅដើមខែល្យារឆ្នាំ ១៩៧៣ អង្គការលើកផែនការឱ្យស្រុកកោះស្លាទាំងមូលចាត់តាំងធ្វើសហករណ៍ ខ្ញុំហៅតាញ៉ិប - តាឆ្លា - តាយឿន - តាជួប - មិត្តទឹផ - តាសឿ - និងមិត្ត សារឹម មកដាក់ផែនការឱ្យទៅបំផុសប្រជាជនតាមឃុំ កុំឱ្យប្រជាជនគួរពេញធ្វើសហករណ៍ ។

ក្រោយពីដាក់ផែនការមក តាញ៉ិប - តាក្លា - តាយឿន - តាជួប -មិត្តទឹផ - តាសឿ - មិត្តសារឹម បានមករាយការណ៍ប្រាប់ខ្ញុំថា សពីសភាពការណ៍ដែលបំផុសបាន គឺនៅឃុំការពារ - ឃុំលបើក - ឃុំតាកែន - ឃុំចក្រីទីង - បំផុសប្រជាជនឱ្យធ្វើសហករណ៍ ឱ្យធ្វើ ខ្ញុំចាត់តាំងឱ្យប្រជាជនធ្វើស្រែប្រវាស់ដីវិញ នៅឃុំពពេលពក - និងឃុំស្ទឹងកែវ មិនឱ្យធ្វើសហករណ៍ដែរ ហើយឱ្យប្រជាជនធ្វើឯកជនតែម្តង -ដូច្នេះក្រោយពីអង្គការ ឱ្យធ្វើសហករណ៍មក ខ្ញុំឱ្យប្រជាជនធ្វើស្រែប្រវាស់ ដីវិញ ហើយធ្វើស្រែមិនឱ្យប្រជាជនដាក់ជី មិនលើកភ្លឺស្រែថែម ឱ្យស្រែមិនជាប់ទឹក ធ្វើឱ្យស្រូវស្លកអស់ ២០០ ហិកតានៅឃុំការពារ ។

ខ្ញុំមិនឱ្យប្រជាជនធ្វើស្រែដីខ្លាញ់ ទុកឱ្យដុះស្មៅចោល ហើយនាំប្រ-ជាជនទៅធ្វើស្រែលើដីក្រហមគ្មានជីជាតិ ហើយមិនដាក់ជីឱ្យស្រូវអត់ផល មួយហិកតាបានតែ ១០.២០ ថាំង ។ នៅឃុំលបើកបានចាត់តាំងមិត្ត សារឹម - តាយឿន ដឹកនាំប្រជាជនយកសំណាបប្រវែងមួយចំអាមទៅស្ទូង នាំឱ្យស្ទូងចែបក្រុយនិងរលួយអស់ ១៥០ ហិកតា ។ ខ្ញុំបានចាត់តាំង តាសឿ - និងតាក្លា ទៅ ធ្វើការនៅឃុំចក្រីទីង ឱ្យនាំប្រជាជនយកស្រូវពូជហួបសល់ពេលរដូវធ្វើស្រែអត់ពូជ ។

ដូច្នេះនៅក្នុងស្រុកកោះស្លាបានផលស្រូវ តែ ១៥ ម៉ឺនថាំងទេ អត់បានសំរេចតាមផែនការរបស់អង្គការ ២៥ ម៉ឺនទេ ប្រជាជនត្រូវហូបបបទាំងព្រឹក -ទាំងល្ងាច ។

នៅខែ ១០ ឆ្នាំ ១៩៧៣ ខ្ញុំបានចាត់តាំងការស្បី និងមិត្តសារឹមឱ្យ យក ស្រូវ ១០០០ ថាំង - គោ ៥ ក្បាល - ជ្រូក ២០ ក្បាល ទៅឱ្យសក្តិ ៣ លាខន នៅបន្ទាយទោងចក្រីទីង ។

នៅខែ ១២ ឆ្នាំ ១៩៧៣ ខ្ញុំបានកសាងកម្លាំងបានឈ្មោះ សេង្រួន - ឈ្មោះដី
នៅខែ ១ ឆ្នាំ ១៩៧៤ ខ្ញុំនិងពូ ចេន បានទទួលសំបុត្រពីតាចាប យកទៅឱ្យតា ស៊ី នៅភមលាំង មុនខ្ញុំទៅតាចាប ណែនាំថា សំបុត្រនេះយកទៅឱ្យតាស៊ី បើមិនជួបតាស៊ី ឱ្យទៅមិត្តកង ក៏ប្រធានមន្ទីរភូមិភាគក៏បានដែរ បើក្រៅពីនេះកុំឱ្យ - សោះ ពេលខ្ញុំនិងពូចេនទៅដល់ អត់បានជួបនឹងតាស៊ីទេ រួចខ្ញុំសួរនីរសារគាត់ថា តាស៊ីគាត់ទៅណាហើយ នីរសារគាត់ឆ្លើយថា គាត់ទៅធ្វើបាត់ហើយ ហើយខ្ញុំក៏ឱ្យសំបុត្រទៅនីរសារគាត់ទៅ លុះដល់ថ្ងៃល្ងាច ទើបឃើញតាស៊ីគាត់ត្រឡប់មកវិញ ហើយគាត់ឱ្យនីរសារគាត់មកហៅខ្ញុំនិង ពូចេនទៅជួបនឹងគាត់នៅនឹងមន្ទីរភូមិភាគ

ពេលទៅដល់គាត់សួរខ្ញុំ - នឹងពូចេនថាមកដល់យូរហើយ ខ្ញុំក៏ឆ្លើយថាមកដល់យូរហើយ បន្ទាប់មកតាស៊ី ក៏បានសួរខ្ញុំនិងពូចេលថា ចាំបទៅសភាពការណ៍នៅ - ខាងកំពតវាយ៉ាងណាដែរ ខ្ញុំក៏បានរាយប្រាប់តាស៊ីថា ក្នុងឆ្នាំ ១៩៧៣នេះ តាចាប បានដាក់ផែនការឱ្យខ្ញុំនិងមិត្តឈយ ទៅទាក់ទងទាហាននៅបន្ទាយក្រុងកំពត និង បន្ទាយទោងចក្រីទីង សម្រាប់សហការណ៍គ្នាឱ្យទាហានទៀងគេរៀបប្រជាជនចូលក្រុង កំពត និងឱ្យផ្លាងដាក់យុទ្ធជនពេលដែលមកសំរាកលើលមរភូមិម្តងៗ និងនាំស្រូវ អង្ករ គោក្របីទៅឱ្យទាហាន ហើយខ្ញុំបានបំផុសប្រជាជនឱ្យរត់ចូលតំបន់ខ្មាំងនៅ កំពត ពេលដែលខ្ញុំរាយការណ៍ចប់ហើយ តាស៊ី ក៏បានប្រាប់ខ្ញុំថា មិត្តយុំឯងទៅវិញ ទៅប្រាប់មិត្តចាបឱ្យទៅទាក់ទងមិត្ត ផា ហើយឱ្យមិត្តផា បន្តខែទៀតទាក់ទៅខាងភូមិភាគបូព៌ាជាមួយនឹងមិត្ត ណាន ព្រោះមិត្តផានៅផិតភូមិភាគបូព៌ាស្រាប់ ហើយ មិត្តផាទាក់ទងហួន ឱ្យបានជាប់ដែរ ហើយត្រូវប្រាប់មិត្ត ផែន ឱ្យបន្តទាក់ទងហួន - ទៀត ។ ពេលតាស៊ីប្រាប់ហើយ ខ្ញុំនិង ពូចេន ក៏ត្រឡប់មកកន្លែងវិញ ។

ពេលខ្ញុំមកដល់ខ្ញុំបានទៅជួបតាចាបនៅមន្ទីរតំបន់នៅត្រពាំងស្លៅហើយ ខ្ញុំ ប្រាប់តាចាប ថា តាស៊ីឱ្យតាទៅទាក់ទងបង ផា ហើយឱ្យបងផា ទៅទាក់ទង

ខ្សែខាងបូព៌ា ឈ្មោះ យាន ហើយមិត្តជា បន្តទាក់ទងឃួនឱ្យផ្ដាច់ និងមិត្តផែនបន្តការ
ទាក់ទងឃួនឱ្យបានផ្ដាច់ដែរ ហើយតាចាប ល្បួងខ្ញុំថា ពេលដែលមិត្តឯងយកសំបុត្រទៅ
ឱ្យតាស៊ី តើយកទៅឱ្យគាត់ផ្ទាល់ ឬទៅយកឱ្យមិត្ត កង ហើយខ្ញុំឆ្លើយថា ខ្ញុំយកសំ
បុត្រទៅឱ្យនីរសាតាស៊ី ហើយយកទៅឱ្យតាស៊ីផ្ទាល់ លុះដល់ថ្ងៃល្ងាចបានខ្ញុំទៅជួប-
និងតាស៊ី និយាយតែប៉ុណ្ណឹងខ្ញុំ- និងពូចេន ក៏លាតាចាបត្រឡប់មកកន្លែងវិញ ។

ក្រោយមកប្រហែលជា ៣ ថ្ងៃតាចាប ហៅខ្ញុំទៅប្រាប់ថា មិត្តឃុំ ឯង
ទៅទាក់ទងមិត្ត ណយ- និងមិត្តរិន ហើយមិត្តណយ- និងមិត្តរិនទៅទាក់ទងលក្ខិ៍សំអុល
នៅក្រុងកំពត ហើយលក្ខិ ៥ សំអុលមកផ្សេងយកប្រដាប់នៅស្ពានព្រះពន្លា ហើយ
ឱ្យលក្ខិ ៥ ផ្លាំងដាក់កងទ័ពរបស់តំបន់ដែលស្នាក់នៅភូមិស្ពឹងសំបួរ ។ ក្រោយពី
តាចាបប្រាប់ខ្ញុំមក ខ្ញុំក៏បានទៅជួបមិត្ត រិន និងមិត្តណយនៅមន្ទីរស្រុកកំពត ពេល-
ខ្ញុំប្រាប់មិត្ត រិន- និងមិត្តណយថាតាមការណែនាំរបស់តាចាប ថាឱ្យមិត្តរិន និងមិត្តណយ
ឯង ទៅទាក់ទងទាហានលក្ខិ ៥ សំអុល ហើយឱ្យយកទាហានទៅគៀរប្រដាប់ផង
នៅភូមិព្រះពន្លា និងឱ្យលក្ខិ ៥ សំអុលផ្លាំងដាក់កងទ័ពដែលស្នាក់នៅភូមិស្ពឹងសំបួរ ។

ក្រោយពីខ្ញុំទៅប្រាប់មិត្តរិននិងមិត្តណយមក ហើយមិត្តរិន និងមិត្តណយបាន-
ទៅទាក់ទងលក្ខិ ៥ សំអុលមកគៀរប្រដាប់នៅភូមិព្រះពន្លា ហើយគៀរប្រដាប់
ភូមិព្រះពន្លាបានទាំងអស់យកទៅក្រុងកំពត ហើយផ្លាំងដាក់កងទ័ពស្លាប់ ១៥ នាក់
និងរបួស ២០ នាក់ ។

នៅខែ ១១ ឆ្នាំ ១៩៧៥ អង្គការបានលើកផែនការវាយក្រុងកំពត -
ពេលនោះតាចាប បានហៅបងជា- បងផែន- ខ្ញុំផ្ទាល់- មិត្តណយ- មិត្តរិន- មិត្ត
ចន- មិត្តជឺផ- ទៅជួបនៅមន្ទីរយោធារបស់តំបន់ ២៥ នៅភូមិម៉ាក់ប្រាង តាចាប
បានដាក់ផែនការ ទប់ទល់ផែនការវាយក្រុងកំពត តាចាប បានចែកភារៈកិច្ច-
ធ្វើសកម្មភាព មិត្តជា- មិត្តផែន- មិត្តឃុំ មិត្តណយ- ទទួលទាក់ទងទាហានចាស់សំអុល
នៅក្រុងកំពត ឱ្យផ្លាំងដាក់យោធាភូមិភាគ នៅពីកើតកំពត និងប្រាប់ចាស់សំ
អុលថា បើទប់ទល់កងទ័ពមិនបាន ឱ្យរត់ទៅបន្ទាយកោះដូង ។ មិត្តរិន-មិត្តជឺផ
មិត្តចន ទទួលខាងបោសសំអាតក្រុងកំពត ផ្លាំងដាក់យោធាភូមិភាគខាងជើងកំពត ។

ពេលកងទ័ពភូមិភាគនិរតីវាយបែក បន្ទាយការពារក្រុងកំពតរលំពីរកន្លែង គឺបន្ទាយក្បាលស្ពានរមាស និងបន្ទាយចាំរទេះភ្លើង ហើយពីខាងជើងលំទុកចូលដល់ផ្សារ ឯកងទ័ពតំបន់មិត្ត វិនមិនបញ្ជាឲ្យកងទ័ពទៀងសំរុក បែរជាឲ្យកងទ័ពដកអស់ ហើយផ្លោងដាក់ប្រយោធារហូត ដោយថាភូមិភាគដកថយ ។ ឯពីខាងកើតខ្ញុំបងស៊ែន បងជា - មិត្តឈាយ - ឲ្យចាត់សំរុល ផ្លោងដាក់ គឺសំរុកមិនបានទៅក្រុងកំពតទេ ។

ឯមិត្តវិន - ផ្លោងដាក់យោធាទៅលើមតភូមិកំពតនោះ ។ មួយទៀតក្នុងពេលកងទ័ពកំពុងចាប់ផ្តើមវាយខ្លាំង ខ្ញុំបងជា - បងស៊ែន - មិត្តឈាយ ឲ្យកងទ័ពស្រុកចូលទៅច្រញ្ញកងទ័ពភូមិភាគពីខាងក្រោយ ហើយខ្ញុំ - បងស៊ែន - បងជា មិត្តឈាយ ទាក់ទងចាត់សំរុល ហើយឲ្យពត៌មានខាងគេអូទៅចាត់សំរុល កន្លែងយោធា ៧ ត្រង់ប្រជុំទ្រៀល ខ្ញុំឲ្យផ្លោងដាក់អស់មួយកងតូច ដោយថាចូលដល់ភ្នំដូនជី ខ្ញុំទាក់-ទងចាត់សំរុល តាមរកឲ្យផ្លោងដាក់កងទ័ពអស់មួយកងអនុសេនាធំទៀត ។

លុះដល់កងទ័ពចូលដល់ផ្សារ ខ្ញុំបងជា - មិត្តឈាយ - បងស៊ែនទាក់ទងចាត់សំរុល តាមគេអូឲ្យផ្លោងដាក់អស់១ កងអនុសេនាតូចទៀត ។ សកម្មភាពខ្ញុំបងជា - បងស៊ែន - មិត្តឈាយ - រហូតខែ ២ ឆ្នាំ ១៩៧៥ ។ អង្គការសំរាកវាយក្រុងកំពត។

ខែ ៣ ឆ្នាំ ១៩៧៥ តាចាប ឲ្យអ៊ំតុត - ចេន - មិត្តស៊ែន - បងជា - ឲ្យទៅជួបកន្លែងមិត្តឈាយ មន្ទីរស្រុកកំពត ដែលមានមិត្តឈិយ - ជួង - អិត - តាវី ឈេន តាប៊ិត - មិត្តឌិន - មិត្តជឿន - មិត្តជីម - ចន - ងៃ - សាត - វិន - ចេន - ជឿន ឃឿន - ជាវ - ។ តាចាបនិយាយថា ឥឡូវសភាពការទូទាំងប្រទេស ច្បាស់ជាឥន្ត្រីមបានជ័យជំនះហើយ លន់ - ណុល យ៉ាងឆាប់ពុកនេះ ដូច្នេះយើងត្រូវរួមសកម្មភាព ជាមួយទាហានទៅកំពត ដើម្បីពង្រីក ពង្រឹងកម្លាំងបដិវត្តគ្រប់រូបភាព និងបន្តបលនាប្រជាជនឲ្យរត់ចូលតំបន់ខ្លាំង ឬយើងទាក់ទងទាហានឲ្យទៀងគេរៀវប្រជាជន ភូមិណា ឬនាំស្រូវអង្ករ ឲ្យគេរាក្របីទាហានផង ។ ហេតុនេះយើងទាំងអស់គ្នា ត្រៀមចលនៈឲ្យច្បាស់ កុំបដិវត្តវិវដ្តៈហើយ យើងកុំភ្លេចការងារយើង ។ ឯបដិវត្តពិតមែនតែតវដ៏ជោះ គ្មានអីលបាយដែរ គ្មានបុណ្យទាន ។

តាចាប និយាយថា យើងត្រូវត្រៀមស្បៀង អាវុធ គ្រាប់រំសេវឱ្យហើយ -
យើងផ្ទុះអាវុធពេលដែលបដិវត្តរំដោះហើយ បើតាមតាស៊ីឱ្យដឹងថា ពេលរំដោះ
ហើយត្រូវតែផ្ទុះអាវុធ យើងត្រូវដណ្ដើមអំណាចពីបដិវត្តមកវិញ ក្នុងការផ្ទុះ-
យើងមិនបង្អែកប្អូនគេជួយយើង ទាំងអាវុធ - ទាំងមនុស្ស ប្អូនគេថាឱ្យតែយើង
ត្រៀមស្បៀងឱ្យហើយទៅ ។ បើយើងវាយបដិវត្តមិនឈ្នះយើងរត់ចូលព្រៃនឹង
រត់ចូលប្អូន ព្រោះយើងត្រៀមស្បៀងជាស្រេចហើយ ហើយត្រូវរៀបចំកម្លាំង
ត្រៀមឱ្យស្រេចទៅ ។

ដូច្នេះខាងមិត្តវិនត្រូវទាក់ទងខាងប្អូនឱ្យផ្ដាច់ ពេលយើងមានការយើង
មិនព្រួយ ហើយតាមស្រុកនិមួយយើងត្រូវត្រៀមស្រូវអង្ករ - គោ - ក្របី - ជ្រូក
មាន់ - ទា - សម្រាប់ផ្ដល់ឱ្យប្អូនផង - សម្រាប់ផ្ដល់ឱ្យយើងផង ។ ទន្ទឹមនឹង នេះ
ត្រូវបំផុសចលនាយុវជន - យុវនារី និងប្រជាជនឱ្យរត់ចូលតំបន់ខ្មាំង ។ យើងសហ-
ការណ៍ជាមួយទាហាន ដោយយើងត្រៀមអាវុធ កងទ័ព - នៅតាមឃុំ - ស្រុក -
តំបន់ ពេលកងទ័ពលន់ - ណុល សិរុកខ្លាំង យើងជួយវាយពីក្រោយ មួយទៀតយើង
ត្រូវទប់ទល់នឹងផែនការរបស់អង្គការ ដែលដកប្រជាជនចេញពីទីក្រុង យើង មិន
ឱ្យដកប្រជាជនចេញពីទីក្រុង ថារកអីដោះស្រាយមិនបានទេ ។

តាចាប គាត់ថាមិត្ត ឈុំ ទៅទាក់ទងមិត្តដែនហើយឱ្យមិត្តដែនទៅទាក់-
ទងមិត្តផា - មិត្តអាន - ដើម្បីរៀបចំអនុវត្តផែនការនេះ ។ ក្រោយពី ទទួល
ផែនការតាចាបហើយ ខ្ញុំបានទៅជួបបងដែន ពេលទៅដល់កន្លែងគាត់ ខ្ញុំបាន
និយាយប្រាប់គាត់ថា តាចាប ឱ្យខ្ញុំមកប្រាប់បងឯង អំពីវិធានការទប់ទល់ផែនគា
អង្គការវាយផ្ដាច់ព្រ័ត្រទូទាំងប្រទេសនៅថ្ងៃខាងមុខក្នុងឆ្នាំ ១៩៧៥នេះ បងដែន
សួរខ្ញុំថា ផែនការទប់ទល់អីខ្លះ ខ្ញុំនិយាយថា តាចាប ថាកុំឱ្យផ្ដល់ស្បៀងអាហារ
ទៅឱ្យសមរភូមិមុខគ្រប់គ្រាន់ ទាំងអង្ករ - បន្លែបង្ការ មួយទៀតបើអង្គការ
ត្រូវការកម្លាំងកងទ័ពក្ដី ដឹកជញ្ជូនសម្ភារៈក្ដី យើងកុំផ្ដល់ឱ្យអង្គការទាំងអស់ ។
ផ្ដល់ឱ្យតិចតួចបានហើយ ហើយយើងត្រូវប្រឆាំងនឹងផែនការរបស់អង្គការដកប្រជា-
ជនចេញពីទីក្រុង ហើយយើងនឹងត្រៀមកងទ័ពគ្រាប់រំសេវ សម្រាប់លួចវាយ-

កងទ័ពបដិវត្តពីក្រោយខ្នងវិញ ។ ខ្ញុំឆ្លើយថា តាចាបប្រាប់ខ្ញុំថា ឱ្យបងងង - ទៅជម្រាបចងដាផង ។ ខ្ញុំក៏ត្រឡប់មកវិញ ហើយបានរៀបចំតាមផែនការ របស់តាចាប ។ ហើយខ្ញុំបានទៅបក្សពួកខ្ញុំមកដាក់ផែនការឱ្យបានគ្រប់ឃុំគុវត្ត - គឺមានឈ្មោះ តាយឿន - កាត់ហោធាមួយអនុសេនាតូច សម្រាប់លួចវាយ កងទ័ពបដិវត្ត និងធ្វើលក្ខណភាគនៅលើភូមិក្រោយទៀត ធ្វើឱ្យកងទ័ពបដិវត្ត ដកកម្លាំងទៅការពារខាងក្រោយផង ។

ក្រោយពីទទួលផែនការពី តាចាប មកខ្ញុំក៏ចាត់តាំងតា យឿន - តាញ៉ិប ដឹកស្រូវចេញពីមន្ទីរកោះស្លា ទៅទុកនៅស្រុក កំពត ហើយមិត្តយើងដឹកទៅ - ស្រុកឈូក តាមរយៈមិត្តទៅការពារព្រំប្រទល់ ។ ឯតាក្របីផ្លូវក្តុំនាំប្រជាជនកាប់ស៊ី ១ ទំថ្ងៃពីរបីផង ដល់អង្គការរកខ្ញុំចាត់តាំង តាយឿន - តាញ៉ិប -ទៅដឹកស្រូវពីប្រជាជនមកឱ្យ ។

ខែ ៣ ឆ្នាំ ១៩៧៥ ខ្សែផល អង្គការវាយក្រុងកំពតម្តងទៀត តាចាប - បានហៅខ្ញុំ - មិត្តណយ - មិត្តទិន - ទៅដាក់ផែនការ តាចាបឱ្យកងទ័ពស្រុកកោះស្លា នៅជាមួយកងទ័ពភូមិភាគនិរតីខាងជើង កងទ័ពស្រុកកំពតនៅខាងត្បូងជាមួយកងទ័ពភូមិភាគខាងត្បូង មិត្តទិនទទួលខាងផ្លូវដាក់កងទ័ពភូមិភាគនិរតី ពេលសំរុកចូលកំពត តាចាបចាំមិត្តឃុំ - មិត្តណយ ត្រូវទាក់ទងលក្ខិ យសំរុល តាមគេឱ្យផ្លូវដាក់កងទ័ពភូមិភាគនិរតីទៀត ។

ពេលទទួលផែនការហើយ ខ្ញុំបានចាត់តាំងតាយឿនឱ្យដឹកនាំកងទ័ពស្រុក ១ កងអនុសេនតូច ចូលទៅទ័ព-ក្រៀមជាមួយនឹងកងទ័ពភូមិភាគទ័ព ដល់ពេលផ្ទុះអាវុធកងទ័ពភូមិភាគសំរុកឡើង កងទ័ពស្រុកកោះស្លា និងកងទ័ពស្រុកកំពត លួចបាញ់កងទ័ពភូមិភាគពីក្រោយ ។ ខ្ញុំមិត្តណយ ទាក់ទងលក្ខិ ៤ សំរុលតាមគេ ឱ្យផ្លូវដាក់កងទ័ពភូមិភាគនិរតី ចូលដល់ភូមិតារកង ពីខាងកើតសាលាខេត្តកំពត ។ ខាងមិត្តទិន បានផ្លូវដាក់កងទ័ពភូមិភាគដែលកំពុងសំរុកចូល ពីខាងជើងស្ពាន មុខរបស់កងទ័ពភូមិភាគសំរុក ចូលទៅមុខមិនបាន ។ ពេលពួកខ្ញុំធ្វើសុកឡកម្លាំងកងទ័ព

ភូមិភាគត្រូវផ្ដាច់ថយវិញ ក្រុងកំពតវាយមិនបែក ។ ក្រោយមកប្រហែលជា១០ ថ្ងៃដែរ ត្រូវរំដោះទូទាំងប្រទេស ។ ក្រោយពីរំដោះទូទាំងប្រទេសមក អង្គការលើកផែនការរៀបចំរដ្ឋអំណាចបដិវត្ត តាំងពីភូមិ-ឃុំ-ស្រុក ខេត្ត-ទៅ ឱ្យបានស្អាតជាទូទៅ ហើយឱ្យដកពួក-ទាហាន-រដ្ឋការ ចេញពីរដ្ឋអំណាចបដិវត្ត ពេលនោះខ្ញុំបានហៅ តាញ៉ិប-តាក្លា-តាយឿន-តាជួបឱ្យសកទាហានចេញពីក្រុងកំពត មកចាត់តាំងឱ្យធ្វើគណៈភូមិត្រពាំងបីឈ្មោះ ធីម ហើយខ្ញុំឱ្យហៅមេឃុំ ទៀង ទើបនឹងចេញពីក្រុងកំពត មកធ្វើស្មៀននៅឃុំការពារ ។ ខ្ញុំឱ្យយកសែប ទាហានចេញពីកំពត ទៅធ្វើប្រធានឃ្លាំងនៅមន្ទីរស្រុកកោះស្លា ហើយខ្ញុំយកប្រជាជនថ្មី ដែលចេះខាងគ្រឿងម៉ាស៊ីនចំនួន ១០ មកឱ្យទទួលខាងជាងស្រុកកោះស្លា ។ ខ្ញុំយកមេខទីព្រចាស់ឈ្មោះ សារ៉ូ ចេញពីកំពត ឱ្យធ្វើប្រធានពាណិជ្ជកម្មស្រុកកោះស្លាដែរ ។ នៅភូមិសហករមួយពុ ខ្ញុំឱ្យយកប្រជាជនថ្មី ឱ្យទទួលនាទីដឹកនាំប្រជាជនចាស់ស្មើគ្រប់ភូមិ ដើម្បីប្រឆាំងផែនការរបស់អង្គការ ហើយដើម្បីកសាងពួកទាហាន នឹងរដ្ឋការទាំងអស់នោះធ្វើជាកម្លាំងប្រឆាំងនឹងបដិវត្តទៅថ្ងៃក្រោយទៀត ។

នៅខែ ៨ ឆ្នាំ១៩៧៥ តាចាប ឱ្យខ្ញុំទៅជួបគាត់នៅមន្ទីរក្រុងកំពត រូបតាចាប និយាយថា តាមតាស៊ី ប្រាប់ថា នៅខែ ៥ ឆ្នាំ ១៩៧៥ បក្សកុម្មុយនីស្តកម្ពុជាត្រូវធ្វើមេវិញ ទទួលអបអរកំណើតកងទ័ពបដិវត្តកម្ពុជា នៅថ្ងៃនោះខាងភូមិភាគឧត្តរត្រូវធ្វើរដ្ឋប្រហារ បក្សកុម្មុយនីស្តកម្ពុជា ។ បើខាង-ភូមិភាគឧត្តរធ្វើរដ្ឋប្រហារបក្សកុម្មុយនីស្តកម្ពុជា ខ្ញុំនឹងឱ្យដើរឹងខាងក្រោយ ហើយតាចាបថា យើងក៏ត្រូវធ្វើរដ្ឋប្រហារតាម៉ុកដែរ ដូច្នេះមិត្ត ឃុំ ឯងទៅជួបនឹងមិត្តផែន ឱ្យមិត្តផែនប្រាប់មិត្ត ជា-មិត្តអាន- ហើយឱ្យមិត្តជា ទាក់ទង នឹងមិត្តយាន នៅខាងភូមិភាគបូព៌ាផង ។

ក្រោយពីតាចាប ប្រាប់មក ខ្ញុំបានទៅជួបបងផែននៅមន្ទីរស្រុកអង្គជ័យ បងផែនសួរខ្ញុំថា មិត្តឃុំ ឯងទៅណា ខ្ញុំឆ្លើយថា តាចាប គាត់ប្រាប់ខ្ញុំ ឱ្យមកប្រាប់បងឯងថា នៅថ្ងៃបក្សធ្វើបុណ្យកំណើតកងទ័ពបដិវត្តកម្ពុជា នៅខែ១៥ឆ្នាំ

១៩៧៥ នៅខាងភូមិភាគឧត្តរធ្វើផ្លូវប្រហាបក្រ នៅថ្ងៃបុណ្យនោះ តាចាប ប្រាប់ថា ឱ្យបងត្រៀមអាវុធ កងទ័ព និងស្បៀងឱ្យស្រេច ហើយតាចាប - ប្រាប់ខ្ញុំថា ឱ្យបងទៅចាក់ចងបងជា - បងអាន - ហើយឱ្យបងជាទៅចាក់ចង ឃួន - និងមិត្តយាន នៅភូមិភាគបូព៌ាផង ឱ្យត្រៀមទ័ព និងគ្រាប់រំសេវ និង ស្បៀងឱ្យហើយ ។ តាចាបប្រាប់ទៀតថា បើថ្ងៃនោះបានផ្ទះ ឬមិនបានផ្ទះ ចាំតាស៊ុឱ្យសំរឹងក្រោយ ។ ខ្ញុំប្រាប់បងផែនរួច ក៏ត្រឡប់មកកន្លែងវិញ - ហើយខ្ញុំក៏បានទៅតាញ៉ិប - តាភ្លា - តាជួប - តាយឿន - តាសៀ ទៅជួបផ្ទាល់ ផែនការ ខ្ញុំនិយាយថា តាចាប ប្រាប់ថានៅខែ ៩ ឆ្នាំ ១៩៧៥ ខាងភូមិភាគ ឧត្តរធ្វើផ្លូវប្រហារបក្រហើយ ឯយើងត្រូវត្រៀមធ្វើដែរ គឺវាយនៅមន្ទីរ - ភូមិភាគ និងកងទ័ពភូមិភាគនីរតី ។ ហើយខ្ញុំចាត់តាំងឱ្យតាយឿន -ទទួលយោធា និងឱ្យត្រៀមអាវុធ និងគ្រាប់រំសេវ ។ ឯតាញ៉ិប - តាភ្លា - តាជួប -តាសៀ ឱ្យទៅកម្លាំងទាំងអស់មកដែលនាំ និងត្រៀមធ្វើផ្លូវប្រហារ នៅមន្ទីរភូមិភាគនឹង កងទ័ពភូមិភាគនីរតីដែរ ។

នៅថ្ងៃធ្វើផ្លូវប្រហារ បងផែន - បងជា - និងបងអាន បានចាត់តាំងបង តុំ - និងបងសៀង ឱ្យចាំបាញ់តាម៉ុក ពេលដែលតាម៉ុកឡើងថ្លែងការ ហើយ បងជា - បងអាន - រៀបចំកងទ័ពពីរកងវរៈសេនាតូច បងផែនរៀបចំកងទ័ព មួយវរៈសេនាតូច សម្រាប់វាយចូលមន្ទីរភូមិភាគនីរតី ។ តែត្រូវមិនបានធ្វើ-វិញ ដោយមេទិញនេះធ្វើថ្ងៃ ហើយកងទ័ពតាម៉ុកច្រើន ។

ក្រោយពីបុណ្យ តាចាប ហៅខ្ញុំទៅប្រាប់ថា មិត្តកងបានមកប្រាប់ថា - ខាងភូមិភាគឧត្តរ ថាធ្វើផ្លូវប្រហារនោះត្រូវអាខានវិញ ព្រោះថ្ងៃបុណ្យ អង្គការមិនឱ្យកងទ័ពចូល ហើយមិនឱ្យយកអាវុធទៅ ក្នុងអង្គមេទិញនោះទេ ។ ហើយកាលនោះចក្រកិទទួលបញ្ជាធ្វើផ្ទាល់តែម្តង ដល់អង្គការមិនឱ្យកងទ័ពចូលធ្វើ-មេទិញនោះ ដូច្នេះការបំងធ្វើផ្លូវប្រហារបក្រត្រូវអាខាន ។

នៅខែ ១១ ឆ្នាំ ១៩៧៥ ក្រោយពីតាចាប បានប្រាប់ខ្ញុំថា ការធ្វើ-

រដ្ឋប្រហារបក្ស ត្រូវអាខានមក ខ្ញុំទៅ តាញឿប - តាក្លា - តាជួប - តាយឿន មកប្រាប់ថា ផែនការដែលចង់ធ្វើរដ្ឋប្រហារបក្ស ត្រូវអាខានធ្វើទៅវិញ ។ ខ្ញុំនិយាយថាទោះត្រូវអាខានក៏ដោយ បើយើងនៅតែត្រៀមគ្រាប់រំសេវ ស្បៀង និងមនុស្ស សម្រាប់ធ្វើទៅថ្ងៃក្រោយទៀត ។ រួចខ្ញុំនិយាយថា តាមតា - ចាបប្រាប់ខ្ញុំថា ត្រូវពង្រឹងពង្រីកនៅក្នុងសហករណ៍គ្រប់រូបភាពទៅទៀត ខ្ញុំក៏យកផែនការនោះមកដាក់ឱ្យធ្វើគ្រប់កន្លែង នៅឃុំលបើក ខ្ញុំឱ្យតាតុំជួប ប្រមូលប្រជាជនមួយឃុំដែលខ្លាំងទៅធ្វើការ ដែលមួយកន្លែងឱ្យខាតពេលវេលាធ្វើ ការ និងឱ្យតាជួបបើកទឹកទំនប់ស្រែស្លក លិចស្រូវខូចអស់ ១០០ហិកតា ។

នៅឃុំការពារ ពេលច្រូតឱ្យតាញឿប ឱ្យចាត់តាំងឱ្យប្រជាជនទៅ - រកត្រីទៅវិញ មិនឱ្យច្រូតស្រូវ ស្រូវទុំធ្លាក់ជ្រុះ ចំនួន ១៥០ ហិកតា ។ នៅឃុំចក្រីទីង តាក្លា - ចាត់តាំងមិត្តសារឹម ដើរលួចដុតស្រូវកណ្តាប់ក្នុងស្រែ អស់ ២០ ហាន និងលួចដុតជង្រុកស្រូវរួមនៅភូមិពីល្វែង អស់ ២៨ជង្រុក នៅភូមិ ត្រពាំងក្រឹងពីកន្លែង ។ នៅឃុំពពេលតាមឿង បានចាត់តាំងមិត្តបឿន កាប់ជើងគោ - ជើងក្របីនៅភូមិដំរីផុង រំខានការភ្ជួររាស់នៅសហករណ៍ ភូមិមហាព្រុំ ។ នៅឃុំស្ទឹង តាសឿ ឱ្យប្រជាជនយកសំណាបស្រូវស្រាលទៅដាក់ទឹកជ្រៅ ខូចអស់ ២០ហិកតា ។

មួយទៀតនៅខែ ១០ ឆ្នាំ ១៩៧៥ ខ្ញុំបានចាត់តាំងតាយឿន ឱ្យបាញ់ឡានភ្ញៀវបរទេសបាន ៣ដង បាញ់ឡានចិនម្តងនៅភ្នំទ្វារ របួស ១នាក់ - ស្លាប់ ២នាក់ ហើយឡានភ្ញៀវមិនស្គាល់ម្តងនៅផ្លូវចូលទៅរោងចក្រទឹកអត់ដឹងត្រូវមនុស្សយ៉ាងណាទេ ។

នៅខែ ១១ ឆ្នាំ ១៩៧៥ តាយឿនទៅលួចដុតឃ្លាំងគ្រាប់រំសេវ របស់តំបន់ ៣៥ អស់មួយឃ្លាំងនៅអង្គរមាស ។ នៅខែ ១១ ឆ្នាំ ១៩៧៥ ខ្ញុំបាន - កសាងកម្លាំងបានឈ្មោះ សាញ់ - និងឈ្មោះ មិន ។ ក្រោយបន្តិចខ្ញុំ - តាញឿប បានទៅកន្លែងពួចេននៅមន្ទីរស្រុកឈូក ខ្ញុំសួរថាម៉េចស្ថានភាពការណ៍ក្រោយរំ - ដោះមក ពួចេននិយាយថា អង្គការឱ្យរៀបចំរដ្ឋអំណាចមួយនៅតាមភូមិ ឃុំ

ឱ្យបានល្អ តែខ្ញុំទៅយកលក្តិ ១ ទាហានទើបចេញពីកំពត ឱ្យមកធ្វើប្រធាន ឃុំ ព្រែកទៀវ ហើយយកថៅកែម៉ាស៊ីនស្រូវ ឱ្យធ្វើប្រធានឃុំមានជ័យ ទើបយកទា-ហានទើបចេញពីកំពត ឱ្យធ្វើប្រធានសហករណ៍ជិតគ្រប់ភូមិ នៅខាងឃុំព្រែកទៀវ មួយទៀតតាចាប ឱ្យខ្ញុំធ្វើ មណ្ឌលកុមារមួយនៅស្រុកឈូក នៅផ្លូវដំលសម្រាប់-បញ្ជូនកូនទាហាន ដែលឪពុកវាងាប់ក្នុងសង្គ្រាមចំនួន ១៥០ នាក់ និងយក ប្រធានថ្មី ទៅកាន់ប្រធានរដ្ឋកិច្ចឃុំឈូក-ឃុំត្រាំងល្ពាយ យកទាហានឈ្មោះ ស៊ីន ពាក់អណ្តង់ដែប ទៅធ្វើប្រធានសាធារណៈការស្រុកឈូក និងយកយុវជន-យុវ-នារី ចេញពីកំពតមកធ្វើគ្រូបង្រៀនកុមារ តាមភូមិនៅជិតគ្រប់ភូមិក្នុងស្រុក ទាំងមូល កុំឱ្យកុមាររៀនល្អត្រតាមរបៀបបដិវត្ត ឱ្យរៀនតាមរបបសង្គម ចាស់ ៗ រួចពូចេន សួរខ្ញុំថា ម៉េចទៅកន្លែងមិត្តឯង ខ្ញុំថា ក៏ដូចកន្លែងពូ-ឯងដែរ ខ្ញុំក៏ត្រឡប់មកវិញ ។

នៅចុងខែ ១១ ឆ្នាំ ១៩៧៥ តាចាប ហៅខ្ញុំមិត្ត ឈយ មិត្តឃុត-បងផែន ពូចេន-មិត្តរិន-ទៅជួបនៅមន្ទីរតំបន់ក្រុងកំពត តាចាប និយាយថាអញ្ជើញ មិត្តទាំងអស់មកនេះ ដើម្បីពិនិត្យការងារធ្វើកន្លងមក ហើយលើកផែនការថ្មីធ្វើ ទៀត សុំមិត្តរាយការណ៍អំពីសកម្មភាពគ្រប់កន្លែង :

បន្ទាប់មកបងផែន-មិត្តរិន-ពូចេន-មិត្តឃុត-និងខ្ញុំរាយការណ៍ជូន តាចាប រួចហើយ តាចាបនិយាយថា សកម្មភាពយើងនៅគ្រប់ស្រុកបានមួយកំរិត សំខាន់ហើយ តែយើងត្រូវបន្តសកម្មភាពបំផ្លាញបដិវត្តតទៅទៀត អ្នកនៅក្នុង-សហករណ៍ បំផ្លាញក្នុងសហករណ៍ អ្នកនៅក្នុងក្រសួងមន្ទីរ ត្រូវបំផ្លាញក្នុងក្រសួង-មន្ទីរ ៗ

តាចាប និយាយទៀតថា ខ្ញុំសុំលើកអំពីសភាពការណ៍ចលនាបដិវត្ត និងចលនារបស់យើង សព្វថ្ងៃយើងឃើញចលនាបដិវត្តគ្រប់គ្រងរដ្ឋអំណាចទាំងស្រុង ឯចលនាយើងវិញ បរាជ័យនៅខែ ៤ ឆ្នាំ ១៩៧៥ ទាំងស្រុងទៅហើយ ដូច្នេះ ឥឡូវយើងកំសាកលអស់សង្ឃឹម ព្រោះអ្នកដឹកនាំយើងខាងលើ មិនទាន់រកមុខ-នៅទៀតទេ ដែលមានខ្លួនបង្កើតផ្សាមួយទៀតណាម ឥឡូវខ្ញុំសុំឱ្យទេសនាមឱ្យ

មិត្តអ៊ឹងនៅក្នុងខែ១ យើងគឺមាន បក្សមួយទៀតដឹកនាំ ដែលក្រៅពីបក្សកុម្មុយនីស កម្ពុជា គឺបក្សពលករកម្ពុជា ពេលយើងឈ្នះបក្សកុម្មុយនីស យើងលើកបក្សនេះដឹកនាំ បងផែនសួរថា ចុះអ្នកដឹកនាំបក្សពលករខម្ពុជានេះឈ្មោះអ្វីខ្លះដែរបង តាចាបនិយាយថា អ្នកដឹកនាំយើងមានបងភឹម លេខាភូមិភាគបូព៌ា ទទួលលេខាបក្សពលករកម្ពុជា - បងញឹម អនុលេខាបក្សពលករកម្ពុជា - តាស៊ុំមាជិកគណៈអចិន្ត្រៃ - មានខ្ញុំជាសមាជិក - ឈូកបូព៌ា ជាសមាជិកត្រៀម ។ ហើយយើងត្រូវអនុវត្តតាមផែនការបក្សពលករកម្ពុជារហូតដល់ទទួលជ័យជំនះ លើបក្សកុម្មុយនីសទាំងស្រុង ។

ហើយតាចាប បន្តទៀតថា យើងត្រូវទាក់ទងគ្នាឱ្យបានជាប់ និងចំកសាង កម្លាំងយើង ឱ្យបានច្រើនតទៅទៀត ហើយនឹងរួមគ្នាធ្វើសកម្មភាពពង្រឹងពង្រីកបដិវត្ត ដោយបំផ្លាញឃ្លាំងអាវុធគ្រាប់រំសេវ បំផ្លាញគ្រឿងម៉ាស៊ីនឡានដុតស្ពានត្រើននៅព្រុំប្រទល់កោះស្លា និងលួចបាញ់កម្មាភិបាលចេញចូលធ្វើការ ចុងបញ្ចប់តាចាប បញ្ជាក់ថាយើងត្រូវរក្សាការសម្ងាត់ ,កុំឱ្យធ្លុះធ្លាយ អំពីបក្សពលករកម្ពុជា និងអ្នកដឹកនាំយើងកុំឱ្យបែកការណ៍ដល់អ្នកបដិវត្តឱ្យសោះ ។

នៅខែ១ ឆ្នាំ ១៩៧៦ ខ្ញុំហៅតាញឹប - តាក្លា - តាជួប - តាសៀ -មិត្តផៃ - មិត្តសារឹម - មិត្តបឿន - តាយឿន - តាមឿង មកដាក់ផែនការ ខ្ញុំនិយាយថា តាមតាចាបថា កន្លងមកយើងទាំងអស់គ្នាធ្វើសកម្មភាពប្រឆាំងនឹងបដិវត្តបានតិចតួច ហើយធ្វើឱ្យបដិវត្តបរាជ័យមិនបានទេ ដូច្នេះយើងត្រូវរួមកម្លាំងយើង - ទើបយើងវាយបដិវត្តបាន ឥឡូវនេះយើងត្រូវបន្តធ្វើសកម្មភាព ពង្រឹងពង្រីកបដិវត្តតទៅទៀត ខ្ញុំចែកភារៈកិច្ច :

តាយឿន - តាក្លា - តាសៀ - ទទួលខាងបាញ់ឡានភ្ញៀវ និងបំផ្លាញឃ្លាំងគ្រាប់រំសេវ និងឃ្លាំងសម្ភារៈក្រណាត់ ។

តាញឹប - មិត្តបឿន - មិត្តផៃ ទទួលខាងបំផ្លាញរបស់បរ សហករណ៍ តាមឿង - មិត្តសារឹម ទទួលពង្រឹងពង្រីក បំផ្លាញសហករណ៍ដែរ ។ ពេលដាក់ ផែនការរួច តាយឿន - តាសៀ ទៅលួចដុតឡានស្រែអំបិលទន្ល អស់ ២ គ្រឿង - ហើយលួចដុតឃ្លាំងក្រណាត់ខោអាវ មុងភួយរបស់ប្រជាជនសហករណ៍ ភូមិដំណាក់ល្អួល អស់

មួយឃ្លាំង ហើយលួចផុតស្លានត្រើងនេះអស់មួយកន្លែង ។ ខាងតាញ៉ិប-មិត្តបឿន - មិត្តវ៉ែដ - ឱ្យប្រជាជនលើកទំនប់នៅអូរគុយ កាត់ទ្រព្យក់ខ្មោចខ្មី-អស់ តាញ៉ិប - មិត្តបឿន - មិត្តវ៉ែដ - ត្រូវឱ្យប្រជាជនលើកទំនប់នៅអូរគុយ អត់ឱ្យកាល់ឬឈើចេញ នឹងឱ្យប្រជាជនដាក់គល់ឈើ នឹងឈើក្នុងទំនប់ ភ្លៀងមកព្រាក់អស់ ។ ទន្ទឹមនេះតាញ៉ិប - មិត្តបឿន - មិត្តវ៉ែដ - បើកឱ្យប្រជាជន-លេងល្បែងស៊ីសងបៀ - អាប៉ោង - ប្រជល់មាន់នៅក្នុងសហករណ៍ កុំឱ្យប្រជាជនធ្វើការក្នុងសហករណ៍បាន ។ កុំឱ្យសហករណ៍រួតលាស់បាន នឹងឱ្យស្លប់បដិវត្ត ។ តាមឿង - មិត្តសារឹម ឱ្យប្រជាជនរំលាយផ្ទះព្រាយខួមចេញ ឱ្យប្រជាជនទៅហូបព្រាយឯកជន ទន្ទឹមនេះឱ្យចែកចានឆ្នាំងគោក្របី ទៅតាមផ្ទះវិញទាំងអស់ តាមឿង - មិត្តសារឹម លួចរំលាយទំនប់ផ្លូវលិចប្រាក់ នឹងលួចកាត់សរស្ពានឱ្យដាច់ ពេលទ្យានមកភ្លូក អស់មួយគ្រឿងខូចអស់ ។

នៅចុងខែ ១ ឆ្នាំ ១៩៧៦ តាចាប ឱ្យខ្ញុំ - មិត្តឈយទៅជួបមិត្តបងវ៉ែផន នៅអង្គជ័យ តាចាប បានប្រាប់ថា មិត្តឈ៉ុំ ឯងទៅជួបមិត្តវ៉ែផន ឱ្យមិត្តវ៉ែផនពិនិត្យតាមក្រុំក្រុមរបស់វ៉ែផន តើមានកងទ័ពចោរក្រង់ណាខ្លះ មានកាំ-ភ្លើងអីខ្លះ ក្រោយពីទទួលវ៉ែផនការពី តាចាប មក មិត្តឈយ បានទៅជួបបងវ៉ែផន នៅមន្ទីរស្រុកអង្គរជ័យ ខ្ញុំប្រាប់បងវ៉ែផនថា តាចាប ឱ្យបងឯងទៅ-ពិនិត្យក្រុំក្រុមរបស់វ៉ែផន មើលកងទ័ពភូមិភាគដាក់ត្រង់ណាខ្លះ មានកាំភ្លើង អីខ្លះ ចំនួនប៉ុន្មាននាក់ សុំបងពិនិត្យឱ្យបានច្បាស់ ហើយរាយការណ៍ឱ្យគាត់-ផង ។ ខ្ញុំសួរបងវ៉ែផនថា កន្លែងបងឯងយ៉ាងណាកន្លងមក បងវ៉ែផនថា កន្លងមកខ្ញុំឱ្យមិត្ត តុំ - មិត្តសៀងចាប់យុវជន - យុវនារីខូចសីលធម៌អស់ ១០នាក់ យកទៅសម្លាប់ចោល នឹងឱ្យចាប់ប្រជាជនរត់ពីការដ្ឋាន ២០ នាក់ទៀតទៅវាយបង្អត់បាយ បងហាលថ្ងៃមួយថ្ងៃទៀត ហើយឱ្យមិត្តតុំ - មិត្តសៀង កាត់ផ្លូវរទេះភ្លើង អស់ ១កង់ នៅជិតភ្នំការទ្យង់ ធ្វើឱ្យរទេះភ្លើងភ្លូកអស់ ៣ ហ្វ៊ុង ។ បងវ៉ែផន សួរមិត្តឈយថា មិត្តឈយឯងធ្វើសកម្មភាពបានយ៉ាងណាខ្លះ មិត្តឈយឆ្លើយថា-

កន្លងមកខ្ញុំបានចាត់តាំងមិត្ត ដួង - មិត្តអ៊ិត - យកមីនទៅដាក់ឃ្លាំងស្រែអំបិលទន្លេ រួចមិត្តដួង - មិត្តអ៊ិត យកទៅដាក់ឱ្យផ្ទះមួយឃ្លាំង ។ ហើយខ្ញុំនឹងមិត្ត ឆោម បានអង្គត់ចាយប្រជាជន នៅឃុំទឹកល្អក់ - ឃុំព្រែកល្បាច់ - នឹងឃុំកោះតូច ប្រជាជនធ្វើស្រែបានហើយ ខ្ញុំមិនព្រមចែកស្រូវឱ្យប្រជាជនហូប បណ្ដោយឱ្យ ស្លាប់អស់ ៣៥០ នាក់ ។ ចន្លឹមនេះខ្ញុំបានឱ្យមិត្ត ឆោម លាក់ក្រណាត់ ៣០០ គី មិនចែកឱ្យប្រជាជន ទុកឱ្យពុកភុយអស់ ។ រួចបងផែនសួរខ្ញុំថា ចុះកន្លងមិត្តឃុំ សភាពការណ៍យ៉ាងណាដែរ ខ្ញុំឆ្លើយថា ខាងខ្ញុំសភាពការណ៍ក៏មិនប្លែកមិត្តឈយ ប៉ុន្មានដែរ ប្រហាក់ប្រហែលគ្នាទេ ។ និយាយហើយខ្ញុំមិត្ត ឈយ ត្រឡប់ មកវិញ ។

នៅខែ១ ២ ឆ្នាំ ១៩៧៦ អង្គការបានលើកផែនការឱ្យតំបន់ ៣៥ធ្វើទំនប់កោះស្លាឱ្យហើយក្នុងឆ្នាំ ១៩៧៦ ដែរអង្គការត្រូវផ្លាស់បង អាន - ពីតំបន់ ២៥ មកធ្វើគណៈអចិន្ត្រៃតំបន់ ៣៥ ដែរ ហើយពេលនោះតាចាប បានហៅបង អាន - ខ្ញុំ - មិត្តឈយ - មិត្តឃុត - ទៅប្រជុំនៅមន្ទីរស្រុកកោះ ស្លា - នាចាប បានលើកថា ផែនការនេះអង្គការបានលើកឱ្យតំបន់ ៣៥ ធ្វើទំនប់ស្ទឹង - កោះស្លាឱ្យហើយ តើយើងត្រូវរកវិធីទប់ទល់កុំឱ្យផែនការនេះ បានសំរេចឱ្យសោះ ។ តាចាប និយាយថា ក្នុងការធ្វើយើងធ្វើកុំឱ្យជាប់ ដូចជាទ្វារទឹកបំពាយប៉ុន្មានក៏បានដែរ ខាងស៊ីម៉ង់ នឹងដែក បើអស់យើងស្នើអង្គការទៀត ហើយយើងធ្វើកុំឱ្យជាប់ ឯទំនប់យើងធ្វើបាតតូច តែលើកឱ្យខ្ពស់ ហើយដាក់គល់ឈើ ឫសឈើក្នុងទំនប់ កុំឱ្យទំនប់នោះជាប់ ឯព្រែកដីក ត្រូវជីកឱ្យចោទ - ធ្វើល្មមព្រួញហើយ ។ ឯប្រជាជនយើងមិនបាច់គិតគូរពីជំរក សុខភាពអនាម័យអីទេ ធ្វើយ៉ាងណាកុំឱ្យផែនការរបស់អង្គការសំរេចឱ្យសោះ ។ រួចតា - ចាប ថាមិត្តអាន - មិត្តឃុំ - មិត្តឈយ - មិត្តឃុត - ទទួលធ្វើសកម្មភាពដូចដាក់ផែនការមកហើយ ។ ក្រោយពីបានទទួលផែនការពីតាចាបរួច បងអានចែកភារៈកិច្ចធ្វើ ខ្ញុំទទួលខាងទ្វារទឹក - មិត្តឃុំទទួលខាងទំនប់ - ឯមិត្តឈយ - នឹងមិត្តឃុត ទទួលខាងព្រែកដីក ពេលធ្វើខាងបងអាន បញ្ជាឱ្យជាងធ្វើទ្វារទឹកទាំង៣

រួចបង្ខំបញ្ជាឱ្យជាងវាយចោលធ្វើម្ដងទៀត ។ ខាងខ្ញុំឱ្យប្រជាជនធ្វើទំនប់ទ្វារតូច លើកឱ្យខ្ពស់ លើកបានកំពស់ ៥ ម៉ែត្រធ្លាក់មួយម្ដង៍ រួចឱ្យប្រជាជនលើកមួយផងទៀត លើកក្រោយបានកំពស់ ៧ ម៉ែត្រ ខ្ញុំបានបាត់តាំងមិត្តមិន បងមាស ឱ្យទំលាយធ្លាក់មួយផងទៀត ។ ខាងមិត្តឈឿ - មិត្តឃុត ជំរុញប្រជាជនឱ្យជីកព្រែកចោទ ធ្វើក្នុងមួយថ្ងៃបានតិចតួច ហើយមិត្តឈឿឱ្យជាងវាស់ លំនៅដំណាក់ នឹងភូមិត្រពាំងថ្ម ហើយឱ្យប្រជាជនរុះរើផ្ទះចេញ នឹង កាប់ ដូងត្នោត - ដើមឈើចោលអស់ ។ ហើយក្នុងការធ្វើ បើមានប្រជាជន - ណាមកមិនទាន់ពេលម៉ោង ខ្ញុំត្រូវដាក់ទារណ្ឌកម្ម ឱ្យរែកដី ១០ម៉ែត្រ គីប ខ្ញុំធ្វើយ៉ាងនេះឱ្យប្រជាជនទំនាស់ នឹងមាគ៌ារបស់បក្ស , មួយទៀតខ្ញុំមិនដោះ ស្រាយជម្រកឱ្យប្រជាជនទេ ឱ្យប្រជាជនដេកក្រោមដើមឈើ គល់ឈើ - គ្មានផ្ទះ គ្មានសំបូង ដេកនឹងដី ម្លោះហើយប្រជាជនឈឺនៅក្នុងការដ្ឋាន មិន សូវមានមនុស្សធ្វើការទេ បន្ទាប់មកតាចាបចុះមកពិនិត្យសកម្មភាពខ្ញុំនៅទំន ប់ ហើយបងភានបានរាយការជូនតាចាប អំពីសកម្មភាពនៅក្នុងការដ្ឋានរប ស់យើងខ្ញុំ តាចាបក៏និយាយថា បញ្ហាដែក នឹងស៊ីម៉ង់ ធ្វើប៉ុន្មានអស់ ក៏អស់ ទៅ របស់អង្គការទេ អស់នឹងស្នើអង្គការទៀត ។ មួយទៀត យើង - ត្រូវជំរុញប្រជាជនឱ្យធ្វើទាំងយប់ - ទាំងថ្ងៃ ទាំងឈឺ ទាំងជា ឱ្យប្រជា - ជនចេះតែកើតទំនាស់ជាមួយនឹងមាគ៌ារបស់អង្គការជាប់ ។

នៅខែ១ ៣ ឆ្នាំ ១៩៧៦ បងភាន នឹងខ្ញុំបានទៅផ្ទះ មិត្តរិន នៅ ឬស្សី ក្នុងស្រុកកំពង់ត្រាច ទៅដល់មិត្តរិន សួរទៅណាបង បងភាន ឆ្លើយ ថា មកកន្លែងមិត្ត រិនឯងនឹង ផ្លាចដ់យល់ពីសភាពការនៅកន្លែងមិត្តឯង នឹង នៅតាមព្រំប្រទល់ដែនតើយ៉ាងណាដែរ មិត្តរិនឆ្លើយថា សភាពការនៅ - តាមព្រំប្រទល់ខាងយួន នឹងយើង ជារូបភាពមានបាញ់គ្នាខ្លះដែរ តែ ខ្លឹម សារយួននឹងយើងដូចបងប្អូនបង្កើតអញ្ចឹង យើងទៅព្រួយអី កន្លងមកខ្ញុំបានទៅ - ទាក់ទងរួចហើយ បើមានការអីគេជួយយើងទាំងអាវុធ ទាំងមនុស្ស ។ ឯនៅក្នុងអង្គភាពយោធាខ្ញុំ ខ្ញុំកសាងកម្លាំងបានមួយចំនួនដែរ ដូចជាមិត្តសាត

មិត្តចន - មិត្តដៃង - សុទ្ធតែកម្មាភិបាល ហើយនៅមិត្ត យឿន - មិត្តចេន - មិត្ត
ផាវ - សុទ្ធតែកម្មាភិបាលដែរ ហើយកម្លាំងទ័ពកណ្ដាលបាន ៣នាក់ទៀតគឺ មិត្ត
ចំរើន - មិត្តបាន - និងមិត្តភុម ។

បងអានសួរថា ចុះតាចាបដែលមកដែរ មិត្តរិនគាត់ថា តាចាប-
ដែលមកមួយដងដែរ គាត់និយាយជាមួយនឹងខ្ញុំថា ត្រូវទាក់ទងប្អូនឲ្យជិតស្និត-
ដៃមនដែន ដល់ពេលយើងវាយបដិវត្តថ្ងៃក្រោយ កម្លាំងធំមួយយើងមានស្រេច
តាចាប និយាយថា យើងត្រូវជួយផ្ដល់ជាស្រូវអង្ករ ជ្រូកគោក្របីឲ្យប្អូនផង
ឲ្យគេកាន់តែកក់ក្ដៅជាមួយនឹងយើង ។ មិត្តរិនថាកន្លងមក តាចាប ដឹក
ស្រូវទៅឲ្យប្អូន ១០០០ ថាំង គោក្របីអស់ ១០០ក្បាល ជ្រូក ២០០ ក្បាល
តាមរយៈខ្ញុំបញ្ជូនទៅឲ្យប្អូនតែម្ដង ។

លុះត្រឡប់ពីកន្លែងមិត្ត រិន មក ខ្ញុំបងអានចូលទៅទាក់ទងតា ជឹម
និងតាជឿន នៅត្រង់កំពតទៀត ទៅដល់មិត្តជឿន សួរខ្ញុំថា បងមកពីទី
ណា ខ្ញុំថាមកពីកន្លែងមិត្ត រិន មិត្តជឿនឯងបានដឹងថា តាចាបទៅកន្លែ
ងដែរ មិត្តជឿន ថាយើញជិះឡានទៅពីព្រឹកមិញទៅហើយ ខ្ញុំសួរ មិត្ត
ជឿន ទៀតថា ម៉េចទៅកំពតនេះសភាពការយ៉ាងណាដែរ មិត្តជឿនថា
សភាពការនៅកន្លែងនេះ គ្មានអីព្រួយបារម្ភទេ ព្រោះភាគច្រើនសុទ្ធ តែ
កម្លាំងយើង យើងធ្វើការបានពេញទី ទន្ទឹមនេះនៅកំពត នៅដៃលីសែង
ខ្ញុំបលនាយុទ្ធជន - យុទ្ធនារី ទាក់ទងគ្នាប្រមែកប្រសាច ពេញទីក្រុង ខ្ញុំសួរ
ថាមិត្តជឿន ដែលទៅទាក់ទងមិត្តឆោមដែរ មិត្តជឿនឆ្លើយថា ដែលទៅ
ទាក់ទងមួយដងដែរ ខ្ញុំសួរថាម៉េចទៅកន្លែងតាឆោម មិត្តជឿនឆ្លើយថា-
នៅកន្លែងតាឆោម តាឆោមថាគេកសាងកម្លាំងបាន ៣ នាក់ គឺឈ្មោះ -
ខាន - គ្រុយ - និងឈ្មោះ មួន ខ្ញុំសួរចុះមិត្តជឿន ឯងកសាងកម្លាំងបានប៉ុន្មាន
ដែរ មិត្តជឿនឆ្លើយថា ខ្ញុំបានកសាងបាន ៥នាក់គឺឈ្មោះ ឆន - សុខ - ម៉ៅ
ឃុំ - ញ៉ំ - ខ្ញុំនិយាយថា យើងត្រូវទាក់ទងគ្នាធ្វើការ ព្រោះមិត្តឯងនៅ
ខាងក្រុង ខ្ញុំនៅខាងស្រែ ឲ្យដឹងពីសភាពការទៅមក ក្រោយពីនិ -

ឃាយគ្នាហើយ បងអាន នឹងខ្ញុំនឹងទៅទំនប់វិញ ទៅដល់បងអាន នឹងខ្ញុំ - ពិភាក្សាគ្នាថា ធ្វើទំនប់ដោយយកពិធីដូចម្ដេច ដាក់ឱ្យប្រជាជនធ្វើទៀត លើកនេះខ្ញុំឱ្យបងមាល - មិត្តឆិន - ទៅទំលាយទំនប់ចុងខាងជើងព្រែកមួយកន្លែង ហើយប្រជាជនទៅធ្វើមួយផ្លូវទៀត បងអានបញ្ជាឱ្យដាំងធ្វើល្អ តែមិនដាក់ ដែកទេ លុះធ្វើហើយ យកទៅត្រូវព្រែកខ្ទប់ខ្ញុំអស់ ។ ខ្ញុំជំរុញឱ្យប្រជាជនធ្វើទំនប់មិនត្រង់នេះវាចកដុកកង់ ។

ក្រោយមកបងអានប្រាប់ខ្ញុំ នឹងមិត្ត ណយថា ត្រូវយកកម្លាំងមកធ្វើការទៀត ហៅមិត្តឡាយ - ឯមិត្តណយហៅមិត្តឈេន នឹងមិត្តម៉េង មកចាត់តាំងទាំង ៣នាក់នេះ ទទួលខាងនារីបំផុសឱ្យរាំច្រៀង តាមមេភ្លេងបណ្ដូមចាស់ នឹងបំផុសខាងសីលធម៌នៅក្នុងការដ្ឋាន ។ ហើយខ្ញុំចាត់តាំងមិត្ត ទីជ - មិត្តជី មិត្តសៀន - ដើរលួចចាបកាបិតខោអាវប្រជាជន ហើយនឹងធ្វើកុកច្បាកលបខាងប្រជាជន ។ ខាងបង អាន ចាត់តាំងមិត្ត មាល់ - នឹងមិត្តឆិន - ឱ្យយកស៊ីម៉ង់នឹងដែកទោល ហើយឱ្យមិត្ត យុត នឹងមិត្តណយ ខាងព្រែកជីក វាស់ឱ្យប៉ះពាល់នឹងភូមិប្រជាជនទៀត ។

ក្រោយពីទទួលផែនការមកខ្ញុំយកទៅធ្វើ មិត្តមាល នឹងមិត្តឆិន បាន យកស៊ីម៉ង់ ៣៥០ បាវ នឹងដែកសរសៃ ៥៥០ដើមទៅទំម្លាក់ទឹកស្ទឹងបោល នឹងធ្វើឱ្យស៊ីម៉ង់ក្នុងឃ្លាំងកំពប់ខ្លះខ្លាយ ខូចអស់ប្រហែល ១០០ បាវទៀត ។ ខាង មិត្តទីជ - មិត្តសៀន - មិត្តជី លួចចបចកាប់ក្នុងការដ្ឋានបាន ៤០០ផ្លែ យកទៅនបឹងបោល នឹងដើរលបកន្លែងប្រជាជន ឱ្យដើរលមួយយប់ៗ ប្រជាជនមិនសូវបាន សំរាកទេ ។ ឯខាងមិត្តម៉េង - មិត្តឡាយ - នឹងមិត្តឈេន បំផុសសីលធម៌ នឹងរាំច្រៀង ធ្វើឱ្យយុវជន - យុវនារីទាក់ទងគ្នា ស្រឡាញ់គ្នា ហើយរវល់ - តែរាំច្រៀងភ្លេចការងារអស់ ទន្ទឹមនេះយុវជន - យុវនារី រត់រឺធ្វើការ មិនបាន ។ ឯខាងមិត្តណយ - មិត្តយុត - វិញ ឱ្យនារីកាស់ដើមត្នោត ពេល ផ្លូវប្រទាក់ប្រទើសនារីខតមិនរួច មិនស្លាប់ ៣នាក់ ហើយមិត្តណយ វាស់ - ព្រែកជីក ឱ្យប៉ះដីទួល នឹងភូមិប្រជាជន ធ្វើឱ្យប្រជាជនកើតចំនាស់នឹងអង្គ

ការបដិវត្ត ។

ក្រោយមកនៅដើមវស្សាឆ្នាំ ១៩៧៦ បងផែន - បងគុំ - បានមក ជួបនឹងបង អាន នៅទំនប់កោះស្លា បងអានសួរថា មិត្តផែនអញ្ជើញមក ពីណាវិញ បងផែនឆ្លើយថា មកពីជួបនឹងតាចាប នៅកំពត ហើយហួសមកជួប បងអានឯងផង បងផែនសួរថា ទំនប់បងធ្វើហើយឬនៅ បងអាន ឆ្លើយ ថាធ្វើមិនទាន់ហើយទេទំនប់ បើយើងធ្វើឲ្យហើយបានទឹកសំបូរ ប្រជាជនជឿ លើអង្គការបដិវត្តហើយ យើងមិនងាយភ្លូសទាញទេ ។ បងអានសួរបង ផែន ថា ក្រោយពីផែនការធ្វើវដ្តប្រហារបក្សមក តើនៅខាងមិត្តផែន យ៉ាង- ណា បងផែននិយាយថា ខាងខ្ញុំនៅត្រៀមកម្លាំង គ្រាប់រំសេវដែល អស់ បន្ថយទេ នៅតែចាំទទួលផែនការផ្ទុះអាវុធ ។ បងអានសួរថា ដែលទៅ- ទាក់ទងបង ជា ឬនៅខាងបូព៌ាដែរ បងផែនឆ្លើយថា ខ្ញុំទៅតែត្រឹមបង ជាទេ តែនៅខាងភូមិភាគបូព៌ាបងជាថា បានទៅទាក់ទងឈ្មោះ យ៉ាន ដែរ គេរៀបចំកម្លាំងធ្វើវដ្តប្រហារបក្ស ហើយកម្លាំងនៅខាងភូមិភាគ- បូព៌ាក៏ច្រើនណាស់ដែរ បងអានសួរនៅឯណាខ្លះ បងផែនថា នៅគ្រប់តំបន់ ទាំងអស់ តែមិនដឹងប៉ុន្មានទេ ។ បងផែនសួរបង អានថា ចុះបងឯង- ដែលទៅទាក់ទងតាស៊ីដែរ បងអានថាមិនដែលបានទៅទេ រវល់តែនៅ ទំនប់ បងផែនថា យើងត្រូវឆ្លៀតពេល ហើយជាការងារសំខាន់របស់យើង- ផង ។ បងឯងទៅជួបបានយល់ពីសភាពការណ៍ទាំងអស់គ្នា ។ បងអានថា ខាងខ្ញុំក៏ចាំទទួលផែនការដែរ ឲ្យតែផែនការខាងលើមក នឹងរៀបចំភ្លាម រួចបងផែនក៏លាទៅវិញទៅ បងអាននិយាយជាមួយខ្ញុំ- នឹងមិត្តឈយថា - ឥឡូវនេះយើងនៅទំនប់ យើងកសាងកម្លាំងបានងាយណាស់ ដូចទាហ៊ានកម្លាំង ជំនួយយើងដែរ ។ ចាប់តាំងពីខែ ៣ ដល់ខែ ៦ ឆ្នាំ ១៩៧៦ បងអាន ឲ្យ ខ្ញុំប្រមូលទាហ៊ានមកទុកមួយជុំ នៅទំនប់ស្ទឹងកោះស្លា ហើយបងអានឲ្យខ្ញុំអប់រំ- ទាហ៊ានឲ្យធ្វើសកម្មភាពប្រឆាំងនឹងបដិវត្ត ។ ក្រោយពីទទួលការណែនាំពីបង អានមក ខ្ញុំបានអប់រំ ហើយចាត់តាំងឲ្យធ្វើសកម្មភាពគឺ លួចដុតជង្រុកស្រូវ ត្រ

ពាំងស្រមី អស់ពីរកន្លែង លួចទំលាយទំនប់ថ្លុក និងលិចស្រូវ ៥០ ហិកតា លួចផុតចំការផ្លូវទេនទៅស្ទឹងទ័កវអស់ ១ ចំការ – លួចកាប់គោស៊ីអស់ ១០ ក្បាល លោកនាយកណ៏ឱ្យភ្នូរវាយគោងាប់ពីរក្បាល ហើយទេះគេបមិនធ្វើការងារ លួចមាន់ប្រជាជនអស់ជិត ២០០ ក្បាល ។ នៅចំនប់ដើរទារាទំនារី ដើរលួចកន្លែងបងប្អូនសំរាក ធ្វើឱ្យផ្អើលមួយយប់ពុំបង្អិនមិនបង់បានសំរាកទេ ។

ទាហានដែលខ្ញុំកសាងបានឱ្យធ្វើសកម្មភាព មានឈ្មោះខាងក្រោមនេះ :

១ – ផុន អតីតៈទាហានពាក់អស្តង់ បច្ចុប្បន្នជាប្រជាជននៅភូមិត្រពាំងវិផ្លល ឃុំបើក ស្រុកកោះស្លា ។

២ – សុស អតីតៈទាហានសក្តិ ១ បច្ចុប្បន្នប្រជាជននៅភូមិទីព្រថ្នង ឃុំបក្រីទឹង ស្រុកកោះស្លា តំបន់ ៣៥ ។

៣ – សារិ អតីតៈទាហានពលច្បាស់ឯក បច្ចុប្បន្នប្រជាជននៅភូមិ-ទីព្រថ្នង ឃុំបក្រីទឹង ស្រុកកោះស្លា តំបន់ ៣៥ ។

៤ – ទិតជា អតីតៈទាហានពលច្បាស់ឯក បច្ចុប្បន្ននៅភូមិបឹង ឃុំបក្រីទឹង ស្រុកកោះស្លា តំបន់ ៣៥ ។

៥ – ភួង អតីតៈទាហានពាក់អស្តង់ បច្ចុប្បន្នធ្វើប្រធានចំការដំឡូងមី ភូមិស្រែជ្រៅ ឃុំបើក ស្រុកកោះស្លា ។

៦ – ហង់ អតីតៈពាក់សក្តិ ១ បច្ចុប្បន្នធ្វើប្រធានឃ្លាំងអង្ករ ភូមិបឹង ឃុំបក្រីទឹង ស្រុកកោះស្លា តំបន់ ៣៥ ។

៧ – ទេន អតីតៈទាហានពាក់ខ្សែ ១ជាន់ បច្ចុប្បន្ននៅភូមិ-ស្រែជ្រៅ ឃុំបើក ស្រុកកោះស្លា តំបន់ ៣៥ ។

៨ – សំអេប អតីតៈទាហានខ្សែ ១ជាន់ បច្ចុប្បន្នជាប្រជាជន-នៅភូមិស្រែជ្រៅ ឃុំបើក ស្រុកកោះស្លា តំបន់៣៥

៩ – ចាបមាស អតីតៈទាហានពលទោ បច្ចុប្បន្នជាប្រជាជននៅភូមិត្រពាំងបន្ទាយ ស្រុកកោះស្លា តំបន់ ៣៥ ។

១០- ទើន អតីតៈទាហានពលបាលឯក បច្ចុប្បន្នជាប្រជាជននៅ-
ភូមិត្រពាំងទំនួល ឃុំរបើក ស្រុកកោះស្លា តំបន់ ៣៥

១១- សារុំ អតីតៈទាហានពលបាលឯក បច្ចុប្បន្នជាប្រជាជននៅ-
ភូមិត្រពាំងទំនួល ឃុំរបើក ស្រុកកោះស្លា តំបន់ ៣៥

១២- ឡាច អតីតៈទាហានពាក់អស្លង់ បច្ចុប្បន្នជាប្រជាជននៅ-
ភូមិទួលខ្ពស់ ឃុំរបើក ស្រុកកោះស្លា តំបន់ ៣៥ ។

អំពើសកម្មភាពចាប់ពីខែ ៧.៨.៩.១០ ឆ្នាំ ១៩៧៦ ខ្ញុំតាញ៉ិប- តាសៀ- តាផ្លូប- តាយឿន- តាមឿង- មិត្តសារឹម- មិត្តរឹង- មិត្តបឿន- និងមិត្តមាឃ ខ្ញុំនិយាយថា តាចាប់ឱ្យឃើងពង្រឹងពង្រីកសហករណ៍ ហើយនៅឆ្នាំ ១៩៧៦- បក្សលើកទិសធ្វើស្រែមួយហិកតាឱ្យបាន ៣តោន ឃើងត្រូវរកវិធីទប់ទល់កុំ ឱ្យបាន ។ ហើយក៏ធ្វើនៅឃុំការពារខ្ញុំឱ្យប្រជាជន យកសំណាបចាស់ថ្នាំងណាទៅស្ទូង ពេលស្ទូងខ្ញុំឱ្យស្ទូងរង្វើល ស្ទូងហើយស្គួងវាវិនាសវាដើងអត់បានដល់១៥០ ហិកតា នៅឃុំរបើកឱ្យប្រជាជនដកសំណាបយកទៅផ្លាប់ទុក ៥.៥ថ្ងៃ ទើបឿង- ស្អុយទើបឱ្យប្រជាជនយកទៅស្ទូង ខូចអស់ប្រហែល ២០០ ហិកតា ។ ផ្លូវធ្វើស្រែខ្ញុំឱ្យប្រជាជនទៅកាប់ឈើ មកធ្វើផ្ទះសិន កាប់ឈើហើយ ទើបឱ្យប្រជាជនធ្វើ ជិតផុតរដូវទៅហើយ គ្រាន់តែស្ទូងហើយអស់ទឹកស្ងួតស្លក ២៥០ហិកតា ។ ហើយធ្វើស្រែខ្ញុំមិនឱ្យប្រជាជនដាក់ជី និងពង្រាបដី តាមផែនការអង្គការទេ ។ និងបំបែកកម្លាំងប្រជាជនឱ្យទៅធ្វើការផ្សេងទៅវិញ រំខានដល់ការស្ទូងដក ។ មួយទៀតពេលធ្វើស្រែខ្ញុំឱ្យប្រជាជនទៅកាប់បំការ និងលើកទំនប់ ដើម្បីប្រទាញកម្លាំងកុំឱ្យសហករណ៍ធ្វើស្រែបាន ។ ហើយកុំឱ្យសំរេចផែនការរបស់អង្គការបាន ។ ម្យ៉ាងទៀតខ្ញុំប្រមូលកម្លាំងយុវជន- យុវនារីនៅឃុំទាំងអស់ឱ្យទៅការពារទំនប់កោះស្លា កុំឱ្យសហករណ៍មានកម្លាំងធ្វើការបាន ។ លុះដល់ពេលស្រូវទុំ ខ្ញុំមិនឱ្យប្រជាជនប្រញាប់ច្រូតទេ ទុកឱ្យទុំញុះក្នុងស្រែ ស្រូវបាក់ករជ្រុះអស់ ៥០ ហិកតា- ហើយបានច្រូត ។

នៅចុងឆ្នាំ ១៩៧៦ តាចាប ប្រាប់ខ្ញុំថា នៅពេលចំរូតខាងមុខ យើងត្រូវរៀបចំកម្លាំងយើង ត្រៀមអាវុធគ្រាប់រំសេវ និងស្បៀងឱ្យហើយស្រេច ព្រោះតាមតាស៊ី ប្រាប់ថា នៅពេលចំរូតនោះ យើងត្រូវផ្ទុះអាវុធ ។ ខ្ញុំសួរតាចាបថា យើងផ្ទុះនៅកន្លែងណាខ្លះ តាចាបឆ្លើយថា មិនទាន់កំណត់កន្លែងទេ តែបើគេផ្ទុះ បានយើងក៏ផ្ទុះ នៅកន្លែងមន្ទីរភូមិភាគ និងកងទ័ពភូមិភាគនីរតីដែរ ខ្ញុំថាកងទ័ពភូមិភាគមានច្រើនកងពលណាស់ មិនងាយ-វាយបានទេ តាចាបថា ចុះកម្លាំងយើងទូទាំងតំបន់ កម្លាំងខាងមិត្តដែនផង-និងខាងមិត្តដាផង ហើយរួមផ្សំជាមួយយួនទៀត យើងឈ្នះទៅហើយ ។

ក្រោយពីជួបតាចាបមក ខ្ញុំបានឱ្យតាញ៉ិប- តាក្លា- និងតាយឿន រៀបចំកងទ័ពគ្រាប់រំសេវ និងស្បៀងអាហារ ។ ជិតដល់ពេលច្រូត ខ្ញុំរវះ តែរងចាំដែនការ តែមិនឃើញសោះ ។ ដោយនៅមិនសុខ ខ្ញុំក៏ទៅជួបនិងបងអាន នៅមន្ទីរកុកកញ្ចាន់ ទៅដល់បងអានសួរថា ទៅណានឹង មិត្តឃុំ ខ្ញុំឆ្លើយថាមកជួប និងបងឯងបន្តិច ព្រោះពីថ្ងៃមុនតាចាបប្រាប់ខ្ញុំថា ដល់ពេលច្រូតត្រូវផ្ទុះអាវុធ តើផ្ទុះថ្ងៃណាទៅ បងអានឆ្លើយថា ខ្ញុំមិនដឹងថ្ងៃដែរ ។ រួចខ្ញុំសួរបងអានថា បងលព្វទីថ្ងៃនេះ ខ្ញុំឃើញកម្លាំងបដិវត្តនៅ-គ្រប់កន្លែងច្រើនណាស់ យើងវាយឈ្នះបដិវត្តបានដែរ បងអាននិយាយថាកម្លាំងយើងក៏មិនតិចដែរ នៅគ្រប់ភូមិភាគ និងនៅគ្រប់តំបន់ ហើយនៅក្នុងកងទ័ពក្រសួងមន្ទីរក្នុងភ្នំពេញ ក៏មានដែរ ខ្ញុំសួរគាត់ទៀតថា មានច្រើនឬតិច ហើយបងឯងដឹងដែរថា តើកម្លាំងដែលមាននោះ ផ្ទុះអាវុធពិត-ជាឈ្នះមែន បងអានឆ្លើយថា បើយើងហ៊ានផ្ទុះពិតជាឈ្នះហើយ ។

នៅខាងភូមិភាគពាយ័ព្យក៏មានច្រើន នៅខាងភូមិភាគបូព៌ាក៏មានច្រើន-និងនៅភូមិភាគផ្សេងទៀតក៏មានច្រើនដែរ ពេលវាយយើងមិនវាយផ្តួល-ផ្តាលទេ គឺយើងវាយក្បាលម៉ាស៊ីនសំខាន់ៗ បើយើងវាយក្បាលម៉ាស៊ីនបាន-ហើយ កូនពុះវាងាយធ្វើទេ ។ ម្យ៉ាងទៀតយើងត្រូវមានជំនឿលើបក្ស

ពលកណ៏ះយើង ហើយយើងធ្វើតាមផែនការទាំងអស់ ទើបយើងឈ្នះ យើងកុំ-ឃ្លេងឃ្លោង សតិអារម្មណ៍ទៅវិញគិតតែពីការកសាងកម្លាំង យើងថែមទៀត ដូចយើងកសាងកម្លាំងទាហានថ្មីមុនអញ្ចឹង កម្លាំងនេះជាកម្លាំងប្រយុទ្ធខ្លាំង-ហើយត្រូវត្រៀមកម្លាំង ត្រៀមស្បៀងអាហារ ផ្សាប់ទំលងថែមទៀតឱ្យស្រេច ទើបយើងម្ចាស់ការ តែត្រូវប្រុងប្រយ័ត្នផង ព្រោះទាហានមិនស្ទួនបេះឧក្សារការសម្ងាត់ទេ កុំឱ្យធ្លុះធ្លាយផែនការយើងឱ្យសោះ ពេលទទួលការណែនាំពីបង អាន មក ខ្ញុំក៏ត្រឡប់មកកន្លែងវិញ ហើយខ្ញុំបានកសាងទាហានបាន ១០ នាក់ទៀត ហើយអប់រំឱ្យធ្វើសកម្មភាពប្រឆាំងនឹងបដិវត្ត-កន្លងមកលួចកាប់ទឹកងក្របីភូមិត្រពាំងថ្ម អស់ ១៥ក្បាល លួចបោចបន្លែស្លៅត្រប់ ត្រឡាច- ត្រសក់- របស់សហករណ៍ភូមិត្រពាំងទំនួលអស់ ១០ហិកតា ហើយយក-គ្រាប់មីនដាក់ស្ពានថ្មមួយនៅភូមិត្រពាំងបីបាក់ខ្ទេចខ្ទីអស់ និងលួចបើកគោក្របីស៊ីក្រាលអស់ ១០ក្រាលពេលយប់ គោក្របីស៊ីស្រូវនៅឃុំការពារអស់ ៧០ហិកតា ។ នៅឃុំសរើកអស់ ៣០ហិកតាទៀត ទន្ទឹមនេះលួចច្រូតស្រូវកំពុងដើមនៅឃុំចក្រីទឹងអស់ ១៥ហិកតា- លួចយកស្រូវដូពនៅភូមិត្រពាំងទំនួល ទៅបុកជ-ណ្ដាំបាយស៊ីអស់ ១០០ ថាំង ។ ហើយទំលំដើមឈើឱ្យដួលតាមផ្លូវជាតិ នៅ ភ្នំទ្វារ ១០ដើម ។ កម្លាំងដែលខ្ញុំកសាងបានឱ្យធ្វើសកម្មភាពនេះគឺមាន-ឈ្មោះ ៤

១- សាគុន អតីតៈទាហានពលទោ បច្ចុប្បន្ននៅក្នុងអង្គភាព-ស្រុកកោះស្លា តំបន់ ៣៥ ។

២- អ៊ីម អតីតៈទាហានពលទោ បច្ចុប្បន្ននៅក្នុងអង្គភាព-កងចល័តស្រុកកោះស្លា តំបន់ ៣៥ ។

៣- គីម អតីតៈទាហានពលទោ បច្ចុប្បន្ននៅក្នុងអង្គភាព-ស្រុកកោះស្លា តំបន់ ៣៥ ។

៤- ថែម អតីតៈទាហានពាក់អស្លង់ បច្ចុប្បន្ននៅភូមិត្រពាំងថ្ម

ឃុំរបើក ស្រុកកោះស្លា តំបន់ ៣៥ ។

៥- ម៉ក់ អតីតៈទាហានពលព្រលឯក បច្ចុប្បន្នជាប្រជាជន នៅ
ភូមិត្រពាំងថ្ម ឃុំរបើក ស្រុកកោះស្លា តំបន់ ៣៥។

៦- ឃី អតីតៈទាហានពលព្រលឯក បច្ចុប្បន្នជាប្រជាជននៅ
ភូមិត្រពាំងថ្ម ឃុំរបើក ស្រុកកោះស្លា តំបន់៣៥ ។

៧- ទៀម អតីតៈទាហានពលព្រលឯក បច្ចុប្បន្នជាប្រជាជននៅ-
ភូមិត្រពាំងថ្ម ឃុំរបើក ស្រុកកោះស្លា តំបន់ ៣៥។

៨- សុត អតីតៈទាហានពលព្រលឯក បច្ចុប្បន្នជាប្រជាជន នៅ
ភូមិត្រពាំងថ្ម ឃុំរបើក ស្រុកកោះស្លា តំបន់ ៣៥

៩- ខុន អតីតៈទាហានពលព្រលឯក បច្ចុប្បន្នជាប្រជាជន នៅ
ភូមិប្រេស ឃុំរបើក ស្រុកកោះផ្លា តំបន់ ៣៥ ។

១០- សារ៉ាយ អតីតៈទាហានពាក់អស្តង់ បច្ចុប្បន្នជាប្រជចជននៅ
ភូមិប្រេស ឃុំរបើក ស្រុកកោះស្លា តំបន់ ៣៥ ។

ដល់ពេលចំនួតបង អាន មកប្រាប់ខ្ញុំថា ផែនការផ្ទុះអាវុធត្រូវបរាជ័យហើយ ខ្ញុំសួរថាយ៉ាងម៉េចបានបរាជ័យ បងអានថា អង្គការចាប់ទៀតឡើងនៅភ្នំពេញ-មិនដឹងអស់ប៉ុន្មានទេ ។ បងអានប្រាប់តែប៉ុណ្ណឹងក៏ត្រឡប់ទៅកន្លែងវិញ ។

សកម្មភាពខ្ញុំពីខែ ១ មកដល់ខែ ៣ ឆ្នាំ ១៩៧៧ អង្គការកំណត់ឱ្យ-ប្រជាជនទាំងចាស់ នឹងទាំងថ្មី ទូទាំងតំបន់ ៣៥ ហូបបាយរួមនៅថ្ងៃទី.១ ខែ១ ឆ្នាំ ១៩៧៧ កាលនោះតាចាបនិយាយប្រាប់ខ្ញុំ នៅទីកញ្ញូ ថាបដិវត្តសង្គមនិយមមិនមែនលំដៅ ត្រង់ហូបបាយរួមនឹងទេ ហូបបាយរួមមិនចិលទេ ហូបឯកជនក៏បាន-ដែរ ពីព្រោះហូបបាយរួមទាលំបាកណាស់ យើងកុំគិតរឿងបាយរួម បើធ្វើផ្ទះបាយរួម ធ្វើនៅតាមផ្លូវជាតិបានហើយ ក្រោយពីទទួលការណែនាំពីតាចាបមក ខ្ញុំយកមកធ្វើ នៅតាមផ្លូវជាតិលេខ ៣ ខ្ញុំចាត់តាំងឱ្យប្រជាជនហូបបាយរួម មួយផ្ទះបាយ ខ្ញុំដាក់ឱ្យហូប ពីរ ១៥០ គ្រួសារ ទៅ ២០០គ្រួសារ ធ្វើឱ្យប្រ-

ជាជនលំបាកដើរមកហូបកើតមានទំនាស់ ដល់ពេលហូបម្ដងៗ ចាប់ហូបពីម៉ោង ៩ ព្រឹក រហូតដល់ពេលរសៀល ពេលយប់ ដល់ម៉ោង ១១យប់ ទើបហូបហើយ ខ្ញុំធ្វើនេះឱ្យប្រជាជនស្អប់ដែលការហូបបាយរួមរបស់បក្ស ៗ មួយទៀតខ្ញុំចលនាប្រ-ជាជនឱ្យប្រមូលជ្រូកមាន់ទាឱ្យអស់មក ហើយហូបតាមចិត្តចុះ ហូបបាន ៧ ថ្ងៃ អស់ជ្រូកមាន់ទារលីង ប្រជាជនចាប់ផ្ដើមហូបអំបិលរហូតមក ៗ
ឯផ្ទះបាយរួម ខ្ញុំឱ្យប្រជាជនធ្វើមិនល្អទេ ឱ្យតែមានសំបូងជិតប៉ុណ្ណោះ អង្គការថាមួយផ្ទះបាយរួម ឱ្យប្រជាជនហូបតែ ៣០ ឬ ៤០គ្រួសារ ហើយផ្ទះនៅជិត ៗ ជាយនៅហូប ៗ តែខ្ញុំកំណត់ក្នុងផ្ទះបាយមួយៗ ឱ្យប្រជាជនទៅហូបពី ១០០គ្រួសារ ទៅ១៥០ គ្រួសារ ឱ្យប្រជាជនលំបាកដើរហូប ឆ្ងាយក្នុងការមួយ កូនចៅទៅហូប ឱ្យប្រជាជនទំនាស់នឹងអង្គការ មួយទៀតរបស់របរដែលដាក់-រួមហើយ ខ្ញុំមិនឱ្យប្រជាជនមកបំពាល់ទាំងអស់ ទុកតែហូបពួកខ្ញុំ ដូចជាស្លួង នឹងដើមឈើហូបផ្លែ បើក្មួនណាហ៊ានបំពាល់ ខ្ញុំឱ្យដាក់ទារណ្ឌកម្ម ៗ

ដល់ថ្ងៃទី ១១ ខែ ៣ ឆ្នាំ ១៩៧៧ អង្គការឱ្យមកធ្វើការនៅភូមិភាគឧត្តរ មុនមកខ្ញុំឃើញ តាញ៉ិប - តាក្លា - តាជួប - តាឈឿ - មិត្តបឿន មិត្តណារីម - មិត្តថៃ - នឹងមិត្តព្រាយ មកប្រាប់ថា ត្រូវអង្គការផ្លាស់ឱ្យខ្ញុំទៅភូមិភាគឧត្តរហើយ មិត្តទាំងអស់នៅបន្តធ្វើការយើងតទៅទៀត ឯខ្ញុំទៅ-បន្តធ្វើការយើងនេះដែរ គឺទៅកន្លែងណាយើងធ្វើកន្លែងហ្នឹង ៗ ហើយតាជួប តាញ៉ិប - តាឈឿ - ត្រូវទៅទាក់ទងខ្សែយើងធ្វើការ គឺមិត្តណយ ស្រុកកំពត - ពូចេនស្រុកឈូក - នឹងអ៊ុំនុតស្រុកព្រៃក្នង - ខ្ញុំបានឧទ្ទេសនាមប្រាប់គេ-រួចហើយ ៗ

រួចតាចាប - ខ្ញុំ - មិត្តឃុត - បងអាន - នឹងមិត្តយើងទាំងអស់ធ្វើ ដំណើរមកភូមិភាគឧត្តរលំរាកនៅភ្នំពេញពីរយប់ ដល់ថ្ងៃទី១៤ ខែ ៣ ឆ្នាំ១៩៧៧ ទើបទៅកំពង់ចាម ៗ មកដល់កំពង់ចាម តាចាបបែងភារៈកិច្ច នៅទីកន្លែងនោះថា មិត្តឃុំ - មិត្តឆាយ - នៅកំពង់ធំ - មិត្តឃុត - មិត្តអាននៅកំពង់ចាម ខ្ញុំនៅខាងសៀមរាប ៗ តាចាបនិយាយទៀតថា យើងមកនេះគឺ

ត្រូវខំធ្វើការងារយើងតទៅទៀត ហើយបើមានការអីទៅទាក់ទងនឹងខ្ញុំ - ទៅសៀមរាប ឯផែនការយើងត្រូវតែដូចមុនសិនហើយ ដល់ក្តាប់សភាពការណ៍បាន និងទាក់ទងគ្នាបានស្រួល ខ្ញុំលើកទិសថ្ងៃក្រោយ ។ នៅចុងខែ ៣ឆ្នាំ ៧៧ ខ្ញុំបានទៅសៀមរាប ហើយទៅមន្ទីរតាចាប ពេលទៅដល់តាចាបសួរខ្ញុំ ថា មិត្តឃុំមកមានការអី ខ្ញុំឆ្លើយថា មកចង់ទៅលេងអង្គរវត្ត ហើយចង់មកជួបតា - ផង តើទៅលេងអង្គរវត្តសិនចុះ មកវិញចាំនិយាយគ្នា ខ្ញុំក៏ទៅអង្គរវត្ត ត្រឡប់មកវិញ តាចាបហៅខ្ញុំទៅនិយាយថា យើងធ្វើការ ធ្វើស្របនឹងសភាពការណ៍ ដូចជាចុះទៀតអង្គការឱ្យយើងឲ្យសំអាតទាហាន និងលមាលភាពក្បត់ - នៅកន្លែងនេះ យើងត្រូវធ្វើឱ្យស្របនឹងសភាពការណ៍ គឺទាហានណាដែលមុខប្រជាជនស្គាល់ទៅហើយ កុំទុក - តែបើទាហានណាដែលមិនស្គាល់ច្រើន ទុកវាកលាងកម្លាំងយើង ហើយយើងរៀបចំផែនការៈទាក់ទងឱ្យបានត្រឹមត្រូវ - ងាយធ្វើការរបស់យើងតទៅទៀត ហើយមិត្តឃុំឯងខំស្រូបទាញកម្មាភិបាលដែលអង្គឱ្យមក ឱ្យបានជាកម្លាំងរបស់យើង ឯកម្មាភិបាលនៅកន្លែងនេះស្រាប់ ដែលអង្គការឱ្យសំរិតសំរាំង យើងសំរិតសំរាំងខ្លះ យើងទុកខ្លះ ជាមនុស្សរបស់ - យើង ងាយយើងយល់ពីសភាពការនៅកន្លែងនេះ ហើយត្រូវអប់រំពួកនោះ នឹងថា មិត្តឯងនៅបើតាមអង្គការសំរិតសំរាំងចេញពីរដ្ឋអំណាច តែខ្ញុំទេដែលឃើញមិត្តឯង ធ្វើការបានល្អទុកមិត្តឯង តាមរបៈនេះយើងត្រូវ[illegible] ។ ជាកម្លាំងយើង ហើយយើងស្រូបទាញឱ្យបានច្រើន ។ រួចតាចាបនិយាយថា - ទៅធ្វើការសិនចុះ ចាំថ្ងៃទាក់ទងខែក្រោយមកពីនោះ នឹងខែក្រោយទៅខាងភូមិភាគឧត្តរនេះ ឱ្យបានច្បាស់ ចាំជួបគ្នាម្តងទៀត លើកផែនការឱ្យច្បាស់ ។ ហើយខ្ញុំក៏ត្រឡប់មកកន្លែងវិញ ហើយខ្ញុំពិនិត្យស្ទាបស្ទង់កម្មាភិបាលនៅភូមិភាគឧត្តរ ដើម្បីស្រូបទាញធ្វើជាកម្លាំង ។ ក្នុងខែ ៣នេះខ្ញុំមិនបានធ្វើអីបានទេ ។

ដល់ខែ ៤ ឆ្នាំ ១៩៧៧ ឈ្មោះ ចន - លេខាតំបន់ ៤៣ - ហៅខ្ញុំទៅទំនប់វិច្ចការ ទៅដល់ឃើញប្រជាជនធ្វើទំនប់មិនគាស់គល់ឈើ មិនយកល្បាចេញ មិនបានដីល្បាប់ចេញ បងចន់ក៏អត់ព្រមាតអីទាំងអស់ ទុកឱ្យប្រជាជនធ្វើ-

តាមចិត្ត ពេលនោះខ្ញុំឃើញគោលដៅបង ចនដូច្នោះ ខ្ញុំក៏ពិចារណាថាប្រហែលមិនបដិវត្តទេនឹង ក្រោយមកបានទៅអង្គុយក្នុងផ្ទះបង ចន និយាយថាធ្វើទំនប់មានអ្នកណាគេយកស្មៅចេញ នឹងបាក់ចេញទេ គេទុកឱ្យច្រើនធ្វើឆាប់-ហើយ ខ្ញុំឆ្លើយថាបាទ ៗ ពេលនោះខ្ញុំមិនទាន់យល់ពីបងចន ច្បាស់ទេ ដល់ថ្ងៃក្រោយខ្ញុំទៅទំនប់មួយវិច្ឆិការទៀត ខ្ញុំហៅកម្មាភិបាលមកប្រាប់ថា ថ្ងៃមុនបងចនថា ធ្វើទំនប់មិនបាច់យកស្មៅ ដីល្បាប់ចេញទេ បើអញ្ចឹង យើងធ្វើមិនបាច់យកស្មៅ នឹងបាក់ចេញទេ ខ្ញុំក៏យល់ស្របតាមគាត់ណែនាំនេះដែរ មិត្តទាំងអស់យកទៅធ្វើចុះ :

ក្រោយមកនៅទំនប់វិច្ឆិការ ត្រូវបាក់អស់ ២៨៦ ខ្ញុំឱ្យប្រជាជនទៅចប់ទៀត លុះថ្ងៃនេះទំនប់មួយវិច្ឆិការ ប្រែលក្រហែងប្រហោង ផាក់ទឹកមិនជាប់ទេ ទ្វារទឹកបង ចនគាត់ចាត់តាំងឈ្មោះ ញិន - គីម ឱ្យធ្វើលព្វ-ថ្ងៃនេះប្រេះស្រាំអស់ ៗ

ដល់ខែ ៥ ឆ្នាំ ១៩៧៧ តាចាប បានមកពីសៀមរាប ទៅព្រះវិហា គាត់ចូលមកផ្ទះខ្ញុំនៅស្ទាង ប្រាប់ខ្ញុំថា ឥឡូវនេះតាមតាសុីឱ្យដឹង-ថា នៅភូមិភាគឧត្តរនេះនៅមានខ្មាំងច្រើនទៀត ខ្ញុំសួរថានៅឯណាខ្លះទៅតា តាចាបថានៅកំពង់ធំឈ្មោះ មិត្តចនលេខាតំបន់ ៤៣ នឹងនៅ-ក្នុងកងទ័ពមានមិត្ត សី ប្រធានកងពលភូមិភាគឧត្តរ ៗ ដូច្នេះមិត្តឃុំឯងទាក់ទងជាមួយឈ្មោះ ចនទៅ ឯមិត្តភានចាំខ្ញុំប្រាប់ឱ្យទាក់ទងជាមួយនឹងមិត្ត សី ៗ

ហើយរួមគ្នាធ្វើការទាក់ទងគ្នា ទៅវិញទៅមក ខ្ញុំបានប្រាប់មិត្តចននឹងមិត្តសីរួចហើយ តាចាបគាត់ប្រាប់តែប៉ុណ្ណឹងគាត់ក៏ធ្វើដំណើរទៅតំបន់ព្រះវិហា-ទៅ ៗ បន្ទាប់មកខ្ញុំបានមកជួបនឹងបង ចន បងចនសួរខ្ញុំថាមកពីណា ខ្ញុំឆ្លើយថាមកពីស្ទាង បងចនថាមានការអី ខ្ញុំនិយាយថា ពីថ្ងៃមុនតាចាបបានប្រាប់បង

ឯងយ៉ាងម៉េចដែរ ពីរឿងខ្ញុំនឹងបងឯង បងចេនទៅស្ងៀមមួយសន្ទុះ ទើបនិយាយថា តាចាបប្រាប់ដែរ បងចេននិយាយថា ពួកយើងដែលមកពីនិរតីមានប៉ុន្មាន ខ្ញុំឆ្លើយថា មានមិត្តឆាយ - មិត្តយុត - បងភាន - នឹងមិត្តទី មិត្តយ៉ុង ទទួលខាងស្មៀង - ឲ្យមិត្តឆាយធ្វើប្រធានមន្ទីរតំបន់ ៤៣ ឯខ្ញុំធ្វើទៅមន្ទីរតំបន់ ៤៣ នឹងមានភារៈកិច្ចទាក់ទងខាងក្រៅទៀត ។ ខ្ញុំសួរថាចុះទៅកន្លែងយើង - យើងទៅមានគ្នាទៀតដែរ បងចេនថា ទៅសល់ខ្លះគឺមិត្ត ភី - មិត្តម៉ុំ -នឹងមិត្តទឹព មិត្តទៅទាក់ទងផង ខ្ញុំឆ្លើយថាបាទ ។ ក្រោយពីជួបបង ចេនហើយ ខ្ញុំត្រឡប់មកវិញ នៅក្នុងខែ ៥ ឆ្នាំ ១៩៧៧នេះ ខ្ញុំកសាងកម្លាំងបានពីរនាក់ គឺឈ្មោះ សាញ់ - នឹងឈ្មោះ ភួក ហើយសកម្មភាពខ្ញុំនៅក្នុងរដូវវស្សានេះ គឺក្នុងរយៈខែ ៣ ដល់ខែ ៦ ឆ្នាំ ១៩៧៧នេះពេលធ្វើស្រែ អង្គការហាមមិនឲ្យ - ព្រោះស្រូវស្រែលើទេ តែខ្ញុំឲ្យប្រជាជនព្រោះស្រែលើអស់ ២០០០ ហិកតា នឹងស្រែលងគោឲ្យស៊ីស្រូវនៅឃុំកំពង់ចិនអស់ ២០០ហិកតា ពេលវស្សាអត់បាយខ្លាំង - ខ្ញុំមិនដោះស្រាយជូនប្រជាជន ទុកឲ្យប្រជាជនស្លាប់អស់ ១៥០នាក់ ហើយមួយទៀតខ្ញុំគិតតែជំរុញឲ្យប្រជាជនធ្វើការ ។ ឯការដោះស្រាយស្បៀងខ្ញុំមិនខ្វល់ទាំងអស់ ក្នុងវស្សាឆ្នាំ ១៩៧៧ អង្ករមួយកំប៉ុងរូបពីរនាក់ទៅ ៨ នាក់ ហើយឲ្យលាយនឹងត្រកួន ។

នៅខែ ៦ ឆ្នាំ ១៩៧៧ អង្គការបានហៅទៅប្រជុំនៅកំពង់ចាម ពេលទៅខ្ញុំក៏ឈប់ទៅដេកកន្លែងបង ភាន ទៅដល់ជួបមិត្តទីនៅនឹងផ្ទះបង - ភានដែរ ទៅដល់ខ្ញុំសួរបង ភានថា បងអត់ទៅប្រជុំទេ បងភានឆ្លើយថា មិនទាន់ទៅទេ ពិភាក្សាគ្នាសិន បងភានចាប់និយាយថា សភាពការណ៍ - ទៅកំពង់ចាម តាមមិត្តស៊ីនិយាយ ពីដំបូងមុនគេឲ្យយកជនសុតខ្លាំងសំទ្បីមួយនេះអស់ ហើយទៅក្នុងកំពង់ចាមនេះកម្លាំងគេទាំងអស់នៅគ្រប់ក្រសួងទាំងអស់ ។ បងភាននិយាយថា នៅក្នុងតំបន់ ៤១ កន្លងមកក៏ឲ្យអ្នកណាធ្វើអីខុសបន្តិច គឺកំទេចចោលទាំងអស់ ហើយគ្រាន់ត្រឹមតែ ១០ខ្ទង់ទៀតទៅ ក៏វាយចោលដែរ

ដាក់កុំឱ្យដើបរួចដែរម្តង មិត្តទីវឆ្លើយថា ខ្ញុំក៏អព្វឹងដែរ កុំឱ្យអ្នកណាហ៊ានកាំ-រើកចាប់ទីវចោលឆ្លាមឥឡូវ ។ កាលមុនប្រជាជន ១ម៉ឺននាក់ ទៅ ឈើទែត ៨ម៉ឺននាក់សព្វថ្ងៃនេះ ។ ខ្ញុំសួរបងអានថា តាចាបដែលយកកន្លែងបងឯងដែរ បងអានឆ្លើយថា តាចាបដែលមកពីឯងដែរ មកលើកមុខគាត់ឱ្យទទួលនាមឱ្យស្គាល់មិត្តសី មកលើកក្រោយគាត់ប្រាប់ខ្ញុំឱ្យទៅទាក់ទងខាងភូមិភាគបូព៌ាផង ១ ហើយគាត់ឱ្យសហការណ៍គ្នាធ្វើការឱ្យបានស្រួល ព្រោះទៅ-ថ្ងៃខាងមុខនេះយើងត្រូវផ្ទុះអាវុធផង តាចាបឱ្យទៅទាក់ទងវៀតណាមឱ្យដាច់-ឱ្យហើយ ហើយឱ្យសើងនេះទៅទាក់ទងផង ។ បងអានសួរខ្ញុំថា ម៉េចទៅខាងកំពង់ធំ ខ្ញុំឆ្លើយថា ខាងខ្ញុំបានទាក់ទងជាមួយនឹងបងចនហើយ សភាពការទៅទីនោះអំណោយឱ្យយើងដែរ ព្រោះយើងទាំងអស់ទៅហើយ កន្លងមក-នៅក្នុងមន្ទីរតំបន់ ៤៣ ខ្ញុំបានចាត់តាំងមិត្តចិត្ត ឱ្យទៀងផ្ទះនារី ហើយយករលស ចោទកងទ័ពភូមិភាគឱ្យកើតទំនាស់មិនយល់ឃើញ ។ នៅស្ទោងខ្ញុំបង្កើតទំនាស់ខាងទសោទ ភូមិភាគ នឹងទសោទសហករណ៍ទំនាស់មិនយល់ ។ រួចក៏រៀបកន្លារស់ទៅ ខ្ញុំត្រឡប់មកវិញ មកដល់កំពង់ធំបងចន ហៅខ្ញុំ-មិត្ត ឆាយ ទៅប្រាប់ថា ឥឡូវនេះយើងគិតតកវិធីបំផ្លាញទំនប់មួយមករា ហើយបំពុលថ្នាំភ្លៀង មិត្តសុំទទួលបំផ្លាញខាងសហករណ៍ ។

ទទួលផែនការហើយខ្ញុំត្រឡប់ទៅធ្វើការវិញ ទៅដល់ខ្ញុំហៅ មិត្តសាញ់-មិត្តអ្នកមក ខ្ញុំនិយាយថាមិត្តអ្នក នឹងមិត្តសាញ់ឯង ទៅធ្វើការត្រូវ-បង្អត់បាយប្រជាជន ឱ្យប្រជាជនថាអង្គការមិនដោះស្រាយប្រជាជនទេ ឯក្រណាត់ខោអាវ យើងកុំចែកឱ្យប្រជាជន ឱ្យប្រជាជនទំនាស់នឹងអង្គការ -ក្រោយមកមិត្តអ្នកទុកក្រណាត់ ១០០គី មិនចែកជូនប្រជាជន ពេលប្រជាជនរកប្រាប់ប្រជាជនថា អង្គការមិនចែកក្រណាត់ទេ ឯមិត្តសាញ់លាក់អង្ករទុកដល់-កើតផ្កូវ មិនចែកប្រជាជនដែរ ចំនួនអង្ករ ៥០បាវ ហើយនៅឃុំនោះ ប្រជាជនស្លាប់អត់បាយ ៧០ នាក់ ។

សកម្មភាពខ្ញុំក្នុងខែ ៧-៨-៩ ឆ្នាំ ១៩៧៧ ក្រោយពីទទួលផែនការ

ឈ្មោះលីមបានយកពូជស្រូវ ទៅត្រាំព្រួសទីថ្ងៃ ត្រូវខូច ១០០ថាំង មិត្តហឿន-ទុកស៊ីមិនឱ្យខូច ៣៥០០ បាវ ទុកអំបិលមិនចែកឱ្យប្រជាជន ១០០០ ឆ្នាត មិត្តផារ៉ែលងចោទីព្រៃផែលកងទ័ពចាប់បានអស់ ៥នាក់ ។ មិត្តហឿនបំផ្លាញម៉ាស៊ីន-ឡានអស់ ២គ្រឿង ។

បន្ទាប់មកខ្ញុំរាយការណ៍ អំពីសភាពការណ៍ជូនបង ចន ផែន ក្រោយពីខ្ញុំរាយការណ៍ឱ្យបងចនហើយ បងចនលើកផែនការទៅថ្ងៃ ៣០ខែ ៤ ឆ្នាំ ១៩៧៧ ផ្ទុះអាវុធនៅកំពង់ចាម ហើយត្រៀមវាយទៅកំពង់ធំផែរ តែមីខាងកំពង់ចាមផ្ទុះ ខ្ញុំសួរបងចនថា ចុះនៅកំពង់ចាមក្លាហើយមានប៉ុន្មាននាក់ ហើយអ្នកណាបញ្ជា បងចនឆ្លើយថា ក្រោយពីអង្គការចាប់មិត្តលីមក គឺខ្ញុំទទួលខុសត្រូវ ដូច្នេះថ្ងៃបុណ្យនឹង បងពកហៅខ្ញុំទៅហើយ ហើយខ្ញុំបានដាក់ផែនការឱ្យមិត្តរៀបចំ នៅតាមក្រសួងទាំងអស់ អស់ហើយបងចុនគាត់ថា កម្លាំង-យើងនៅគ្រប់ក្រសួងនឹងមន្ទីររបស់ភូមិភាគទាំងអស់ ។ ហើយបងពកមានកម្លាំង ឯណា ។ ពេលដល់ថ្ងៃ ៣០ ខែ ៤ ឆ្នាំ ១៩៧៧ បងពកមកផ្ញើរីវិញទៅទំនប់មួយមករាវិញ ហើយផែនការវាយបងពកត្រូវអាខាន ទន្ទឹមនេះមិនបានវាយបងពក បងចនបញ្ជាឱ្យឈ្មោះ ទៀប- ឈ្មោះលី វាយឃ្លាំងគ្រាប់ ផ្ទុះខេត្ត នឹងវាយរ៉ែលងអ្នកដាប់គុក ពេលវាយទៅថ្ងៃឈ្លាប បងពកអត់ទៅទេ ពេលបង-ពកមកវិញបានចាប់ឈ្មោះ ទៀប- លី ហើយទើបចាប់ឈ្មោះ ចន ។ ក្រោយពីចាប់បងចនមក ។ ផ្នែកទៀតខ្ញុំមកជួបតាចាបនៅសៀមរាប ទៅដល់តាចាបកំពុងតែប្រជុំផែន រួចខ្ញុំឱ្យនីរសារគាត់ទៅប្រាប់គាត់ ថាខ្ញុំសុំមក-ជួបគាត់ ពេលនោះតាចាបឱ្យខ្ញុំចូលទៅ ទៅដល់ខ្ញុំឃើញឈ្មោះ ចិនឈ្មោះលាប- ឈ្មោះ ម៉ៅ- ឈ្មោះ សុខ- ឈ្មោះណាត- ឈ្មោះ ណម- ឈ្មោះ សានឈ្មោះ ណុង- ឈ្មោះមួន- ឈ្មោះ ឃុំ កំពុងប្រជុំ តាចាបបាននិយាយថា កម្លាំងយើងមានតែប៉ុណ្ណឹង ធ្វើការមិនខ្លាំងទេ យើងយកទាហាននៅតាមភូមិឱ្យបាន-ច្រើនមិនខ្វះទេ ទាហានសក្តិ ២.២ទៅគគោក ប្រមូលយក ១០០ នាក់ក៏យក

២០០គីឡូ យើងឱយធ្វើការផ្លានខាងស្រុកក្រឡាញ់ ឱយមិត្តមិនទទួលខុសត្រូវគ្រប់គ្រង ពេលមានការខែខាងមុខនេះ យើងយកកម្លាំងនេះប្រើការ តាចាបនិយាយតែប៉ុណ្ណោះក៏ឱយមិត្តយើងលំបាក រួចខ្ញុំរាយការឱយតាចាប អំពីអង្គការចាប់បងបន ឱយតាចាបជ្រាប ។ តាចាបនិយាយថាយើងផ្អាកមើលសិន បើវាមិនអីទេយើងត្រូវធ្វើតទៅទៀត ដើម្បីទទួលផែនការថ្មីខាងមុខ តាចាបនិយាយប៉ុណ្ណោះ ខ្ញុំក៏លាតាចាបត្រឡប់មកវិញ ។

នៅខែ ១០ ឆ្នាំ ១៩៧៧ ខ្ញុំបានទៅជួបមិត្ត ផន នៅចំការកៅស៊ូ ភូមិភាគកណ្តាល តាមការឧទេសនាមរបស់បងផែន ពេលទៅដល់ក៏ជួបមិត្ត ផន នៅចំការកៅស៊ូ ទៅដល់មិត្តផនហៅខ្ញុំឡើងទៅលើផ្ទះ ខ្ញុំនិយាយថា នៅខាងមិត្តផនឯងក្តាប់បានសភាពការណ៍យ៉ាងណាដែរ មិត្តឆ្លើយថា តាមពូដឹមប្រាប់ខ្ញុំថា នៅខាងភូមិភាគបូព៌ាយួនវាយចូលចំងាយ ៣០.៣០ គីឡូម៉ែត្រ ខ្ញុំសួរថាចុះបើយួនវាយចូលគពាំង តើយើងគិតយ៉ាងណា មិត្តផនឆ្លើយថា មិនទៅគិតអីទេ ឱយតែយួនចូលដល់ កម្លាំងខ្ញុំមានសហការណ៍ជាមួយនឹងយួន វាយ នៅកំពង់ចាមឥឡូវនឹង មិត្តផនសួរខ្ញុំថា ចុះបងឯងរៀបចំយ៉ាងណាដែរ ខ្ញុំឆ្លើយថាខ្ញុំរៀបចំកងទ័ពអស់ហើយ ហើយខ្ញុំអត់ទៅគិតអីទេ គិតតែដើរស៊ីផឹកលេងបៀរ សមរភូមិយ៉ាងម៉េចក៏ដោយចុះ ។ ខ្ញុំនិយាយប៉ុណ្ណោះក៏ត្រឡប់មកវិញ មកដល់កំពង់ធំខ្ញុំចូលប្រាប់មិត្ត ឆាយ ថាឥឡូវនេះសភាពការណ៍យួនវាយលុក ក្នុងភូមិភាគបូព៌ា ចូលជ្រៅណាស់ហើយ ដូច្នេះត្រូវសំរុកកសាងកម្លាំងឱយបានច្រើន ព្រោះនៅក្នុងមន្ទីរតំបន់ ៤៣នេះស្រេចតែយើងទេ មិត្តឆាយឆ្លើយថា នៅកន្លែងនេះងាយទេ ព្រោះបងពកអត់នៅផង យើងធ្វើអីស្រេចតែចិត្ត យើងទាំងអស់ ដូច្នេះនៅក្នុងមួយខែនេះ ខ្ញុំកសាងកម្លាំងថ្មីបាន ២នាក់ឈ្មោះ នារី ខែកវ - និងឈ្មោះ កន និងចាត់តាំងឱយឈ្មោះ ដាបំផ្លាញម៉ាស៊ីនបូមទឹក សំរាប់ក្រុងអស់មួយគ្រឿងខូចអស់ ខ្ញុំនិយាយថាឥឡូវនេះមិត្តឯងនៅកន្លែងនេះហើយ ត្រូវទទួលបំផ្លាញសម្ភារៈនៅក្នុងក្រុង និងអូសទាញកម្លាំងចាស់ ទាំង

កម្លាំងថ្មីឱ្យអស់ មិត្តនាយឆ្លើយថាបាទ ។ ខ្ញុំនិយាយជាមួយនឹងមិត្តនាយ ហើយ-ខ្ញុំក៏ទៅស្មោង ខ្ញុំហៅមិត្តអ្នក-មិត្តសាញ់-មកណែនាំឱ្យបំផុស ហើយឱ្យ មិត្តអ្នក-មិត្តសាញ់-បំផុសប្រជាជនឃុំកំពង់ចិនខាងត្បូង -ឃុំកំព្រាច-នឹងឃុំ-ទ្រា-ឃុំមនរ្សាក្រង-ឃុំប្រឡាយ ឱ្យបើកទឹកចែស្រចេញអស់ ១៥០០ ហិកតា ត្រូវស្លកអស់ទឹកខូចអស់ ធ្វើឱ្យប្រជាជនអត់បាយទាំង ៥ឃុំនេះ ។ ហូបបបរទាវទាំងព្រឹកទាំងល្ងាច ។ មធ្យោងទៀតនៅខែ ១០ ឆ្នាំ ១៩៧៧នេះ ប្រជាឈ នៅក្នុងស្រុកស្មោងទាំងមូលត្រូវអត់បាយហូប ប្រជាជនបបរលាយត្រកួនហូប ។ នឹងលាយត្រាវហូបមួយកំប៉ុង ៥នាក់ ខ្ញុំឃើញអត់ហើយមិនគិតគូរដោះស្រាយ ទេ-ឯខ្ញុំហូបបាយព្រឹកបាយល្ងាច ម្ហូប ២.៣មុខ ឯប្រជាជនដាច់ពោះស្លាប់អស់ដោយ-អត់បាយហូបប្រហែល ៦០០ នាក់ទូទាំងស្រុក ។

នៅខែ ១១ ឆ្នាំ ១៩៧៧ អង្គការបានចាត់តាំងបងផែនឱ្យមកធ្វើលេខាតំបន់ ៤៣ ភូមិភាគកណ្តាល ។ ពេលដែលបងផែនមកដល់ ខ្ញុំបានទៅជួបនឹងបងផែន បងផែនសួរខ្ញុំថា សព្វថ្ងៃនេះខ្ញុំកំពុងបង្អត់បាយប្រជាជននៅក្នុងស្រុកស្មោងស្លាប់អស់ ៦០០នាក់ហើយ ហើយកំពុងស្លាប់បន្តទៀត ។ បងផែននិយាយថា យើងកំពុងរវល់ដោះស្រាយ ទុកឱ្យប្រជាជនកាន់តែទំនាស់នឹងអង្គការខ្លាំងឡើងៗ បងផែននិយាយថា ឥឡូវមិត្តឯងត្រូវបន្តធ្វើសកម្មភាពទៀត ធ្វើឱ្យប្រជាជន-កាន់តែរើបកចេញពីបដិវត្ត ក្រោយពីបានទទួលការណែនាំពីបងផែនលេខាតំបន់៤៣មក ខ្ញុំបានទៅដាក់ឱ្យមិត្តអ្នក-មិត្តសាញ់ធ្វើទៀត ។

នៅក្នុងខែ ១១ ឆ្នាំ ១៩៧៧ នេះខ្ញុំកសាងកម្លាំងថ្មីបាន ៣នាក់ គឺឈ្មោះ ផន-នុន-នឹងឈ្មោះ ខុន នឹងទាក់ទងខែ១ប្រាស់បាន ២នាក់ ឈ្មោះ វង់-នឹងឈ្មោះ លៀន- គម្លាំងទាំងអស់នេះខ្ញុំបានដាក់ផែនការឱ្យធ្វើ តាមផែនការដែលខ្ញុំបានទទួលពីបងផែនដែរ ហើយខ្ញុំបានចាត់តាំងមិត្តនុនឱ្យប្រមូល-ទាហានទាំងចាស់-ទាំងថ្មី យកមកសម្លាប់ចោលទាំងប្តីទាំងប្រពន្ធកូនទាំង អស់ ហើយមិនឱ្យមិត្តនុនកប់ទេ ដើម្បីវាយមាគ៌ារបស់បក្ស នឹងឱ្យប្រជាជនថាបដិវត្តមិនត្រឹមត្រូវ មិនឱ្យប្រជាជនជឿលើអង្គការ ពេលដែលខ្ញុំសម្លាប់ទាហាន

មិនកប់ ៗ ហើយខ្ញុំបានចលនាទាហ៊ានឱ្យរត់អស់ ៦០គ្រួសារ ៗ

ម្យ៉ាងទៀតពេលកំពុងតែអត់បាយប្រជាជន មានការលួចបន្លែបង្ការ ឬចំណីហូបបន្តិចបន្តួច ខ្ញុំឱ្យមិត្តរុនចាប់មកសម្លាប់ចោលមិនថាចាស់ នឹងថ្មីទេ ៗ ឯខាងមិត្តផនដែនសាទ ខ្ញុំឱ្យបំផ្លាញត្រីចោល ហើយធ្វើកុំឱ្យបានត្រីជូនប្រជា-ជន ក្រោយមកមិត្តផនរាយការថា គេបានបើកត្រីចោលអស់ ២០០ តោន

នៅខែ ១២ ឆ្នាំ ១៩៧៧ ខ្ញុំបានចាត់តាំងមិត្តវង់- នឹងមិត្តសៀនលាក់ស្រូវទុក ៧០០០ថាំង នឹងឱ្យប្រមូលគោជ្រូក ចំនួន ១០០ក្បាល ថាទុកឱ្យកងទ័ព តែការពិត ខ្ញុំទុកស៊ីសប្បាយបក្សពួកខ្ញុំ ម្យ៉ាងទៀតពេលអង្គការសំរុក-វាយយួន ខ្ញុំជ្រើសរើសកងទ័ពចំនួន៣៣០នាក់ ហើយខ្ញុំបានរើសបាន ហើយខ្ញុំចលនាឱ្យរត់ទៅផ្ទះវិញ ក្រោយមកយុទ្ធជនរត់មកវិញជាបន្តបន្ទាប់ ម្យ៉ាង-ទៀតខ្ញុំជ្រើសកងទ័ពឱ្យអង្គការ ឱ្យយកប្រជាជនចាស់ នឹងទាំងប្រជាជន ថ្មី ក៏យក សមាសភាពអាក្រក់ក៏យក សមាសល្អក៏យក ឱ្យទៅធ្វើសកម្មភាពនៅក្នុងអង្គភាពកងទ័ព កុំឱ្យវាយយួនបានក្នុងពេលដែលកងទ័ពកំពុងវាយយួន ខ្ញុំមិត្តឆាយ-បងផែនរវាល់តែនាំគ្នាលេងបៀរ ដើរស៊ីផឹកនៅឯណេះបន្តិច ឯណោះបន្តិច មិនគិតដល់សមរភូមិទាល់តែសោះ ៗ

នៅខែ ១ ឆ្នាំ ១៩៧៨ អង្គការដាក់ឱ្យស្រុកស្នោងធ្វើទំនប់ នឹងដាក់ឱ្យដាំពោត នឹងស្រូវ ២.២០០ហិកតា ក្រោយដែលអង្គការដាក់ផែន-ការរួចមក បងផែនហៅខ្ញុំ- មិត្តទិត- មិត្តឆាយ ទៅប្រជុំលើកផែន ការបំផ្លាញទំនប់ នឹងបំផ្លាញការដាំពោត នឹងស្រូវក្នុងឆ្នាំ ១៩៧៨នេះ ៗ បងផែននិយាយថា អង្គការឱ្យយើងធ្វើទំនប់មួយ ហៅ ៣០ កញ្ញា នឹងដាំ-ស្រូវពោត ២២០០ហិកតា ឯទំនប់បងផែនឱ្យយកដីទាំងដុំ ទាំងស្មៅទៅដាក់-មិនបាច់វាយឱ្យម៉ត់ទេ ដល់ភ្លៀងមកត្រូវហូរច្រុះបាក់ទំនប់ទាំងផ្ទាំងៗ ហើយខ្ញុំឱ្យប្រជាជនធ្វើទៀត ឯកន្ទុយទ្វារ កាលធ្វើបងផែនមិនឱ្យដាងចក្រគ្រិះទេ ដល់បង្ហូរទឹកតាមមាត់ទ្វារ ត្រូវទឹកហូរច្រុះ ទឹករូងជំរៅ ៧ម៉ែត្រ ៗ ហើយអង្គការតម្រូវឱ្យធ្វើកន្ទុយទ្វារទឹកនេះថែម ដើម្បីកុំឱ្យបាក់ ពេលនោះ

រៀបចំកម្លាំងយើងឱ្យបានត្រឹមត្រូវ នឹងត្រៀមកម្លាំងគ្រាប់រំសេវ នឹងបន្ត - ទាក់ទងគ្នាឱ្យជាប់ដើម្បីឱ្យដឹងគ្នាទៅវិញ ទៅមក ។ ដូច្នេះខាងមិត្តឃុំត្រូវរៀបចំកម្លាំងឱ្យហើយ ពេលមានផែនការយើងវាយតែម្តង ។

និយាយរួចហើយ ខ្ញុំក៏ត្រឡប់មកវិញ មកដល់កំពង់ធំខ្ញុំចូលផ្ទះបងផែនទៅជំរាបគាត់អំពីសភាពការណ៍នៅខាងខ្ញុំ នឹងនៅខាងបងភាន ពេលនោះបងផែននិយាយថា បើដូច្នេះមិត្តឃុំឯងរៀបចំកងទ័ពមួយអនុសេនាធំ ឯខាងខ្ញុំ ក៏រៀបចំមួយអនុសេនាធំដែរ ហើយរៀបចំពួកនៅក្នុងក្រសួង - មន្ទីរដែលប្រើ - ការបាន មួយទៀតយើងត្រូវលាក់ស្រូវឱ្យបានមួយចំនួនដែរ បើយើងមិនឈ្នះបដិវត្ត យើងយកស្រូវនោះគ្រាន់ដោះស្រាយ ទំរាំយើងទាក់ទងគ្នាបាន ។ និយាយគ្នាតែប៉ុណ្ណោះ ខ្ញុំក៏បែកគាត់ទៅកន្លែងរបស់ខ្ញុំវិញ ។ ពេលទៅដល់ខ្ញុំបានហៅមិត្ត អួក - មិត្តសាញ់ - មិត្តសៀន - មិត្តវង់ - មិត្តវុន - មិត្តមិន - មិត្តខុន មិត្តផន - មិត្ត មកពិភាក្សាគ្នា ខ្ញុំនិយាយថា សភាពការណ៍សព្វថ្ងៃនេះយើងឃើញថា យួនត្រូវបរាជ័យហើយ ដូច្នេះយើងត្រូវរៀបចំកងទ័ពឱ្យបានមួយអនុសេនាធំ ដើម្បីដល់ពេលយើងត្រូវការនៅពេលខាងមុខនេះ ។ បើអព្វឹងខាងកងទ័ពឱ្យមិត្តអួក ទទួលចុះ ព្រោះគេធ្លាប់កាន់ខាងកងទ័ព ឯមិត្តក្រៅពីនេះយើងត្រូវលាក់ស្រូវ នឹងស្បៀងអាហារ សម្រាប់ពេលយើងត្រូវការ ឯ ខាងលាក់ស្រូវ ខ្ញុំប្រគល់ឱ្យមិត្តស៊ាន - នឹងមិត្តវង់ - ។ ទន្ទឹមនេះយើងត្រូវ កសាងកម្លាំងយើងឱ្យបានច្រើនទៀត ពិសេសយើងត្រូវអូសទាញអ្នកដែលមិនពេញចិត្តនឹងបដិវត្ត ។ ក្រោយពីដាក់ផែនការមក មិត្តអួកបានរៀបចំកងទ័ពបាន - បានមួយអនុសេនាធំ មិត្តសៀន - មិត្តវង់ បានប្រមូលស្រូវបាន ១០០០ថាំង ហើយទូនៅចុងខែ ៣ ឆ្នាំ ១៩៧៨ ខ្ញុំបានកសាងកម្លាំងបាន ៥នាក់គឺឈ្មោះ នារីទូចនារីម៉ែម - នារីភាត - មិត្តសាំ ពេលដែលខ្ញុំកសាងបានកម្លាំងនេះហើយ ខ្ញុំចាត់ - តាំងមិត្តនារីទូច - មិត្តនារីម៉ែមឱ្យទទួលកងចល័តស្រុកស្នាង ហើយខ្ញុំបានណែនាំឱ្យគាត់ជួយអូសទាញកម្លាំងយុវនារីនៅកន្លែងនឹងថែម នឹងឱ្យចលនានារីឱ្យរត់ទៅផ្ទះ នឹងឱ្យលួចបំពុលកងចល័ត ដើម្បីកុំឱ្យកងចល័តប្រមូលផ្តុំធ្វើការងារបាន

ឯខាងមិត្តភាត - មិត្តសាឱ្យទទួលខាងសំណង់ទ្វារទឹក សម្រាប់បំផ្លាញខាងសំ ណង់ មួយទៀតខ្ញុំបានប្រាប់មិត្តសាញ់ថា នៅតាមផ្លូវជាតិ ត្រូវរែកនេ ឱ្យសឹងទឹង ពិសេសរែករកកូនទ្បានតូចៗ ដើម្បីឱ្យយឺតដំដើរ ។

ក្រោយពីផ្លាក់ផែនការមក ខាងមិត្តទូច - មិត្តយ៉ិម - បំពុលកងចល័ត បាន ២ ស៊ង ពុលមួយសងអស់ ១០០នាក់តែគ្មានស្លាប់ទេ ។ ពុលលើកទី.២អស់៤៨ នាក់ស្លាប់ពីរនាក់ សភាពការណ៍ក្រោយពីកងចល័តពុលមក ឃើញកងល័តរត់-ទៅផ្ទះជាបន្តបន្ទាប់ ។ ឯខាងមិត្តសាំ - និងមិត្តភាត ក្រោយពីចាត់តាំងរួចមក បានធ្វើឱ្យទ្វារទឹក ៣០ កញ្ញា សម្រាប់បំរើខាងស្រុកស្មោង ត្រូវបាក់ស្រុតអស់មួយចំហៀង ។

នៅខែ ៥ ឆ្នាំ ១៩៧៨ តាចាបបានហៅបងផែន - មិត្តឃុត -បងភាន មិត្តលន - មិត្តកាន - អ៊ុំលិន - និងខ្ញុំទៅប្រជុំនៅកន្លែងគាត់សៀមរាប ពេល-ប្រជុំតាចាបលើកអំពីផែនការនៅខែ១ ៥ ឆ្នាំ ១៩៧៨ និងសភាពការណ៍យួន បូពារ៉ៃយើងសង្គ្រាមខ្លាំងណាស់ដែរ តែឥឡូវនេះយើងអស់សង្គ្រាមបុំន្មានទេ ព្រោះសព្វថ្ងៃនេះកងទ័ពបដិវត្តន៍វាយបណ្តេញវាស្ទើរតែអស់ទៅហើយ ដូច្នេះយើងត្រូវជួយបន្ទខាងភូមិភាគបូព៌ាផង តាមបងញ៉ឹមលើកផែនការ នៅថ្ងៃ ១៧មេសា ឆ្នាំ ១៩៧៨ យើងត្រូវផ្ទុះភារទុតពីកន្លែង ទី១ យើងផ្ទុះនៅត្រើមកំពង់ធំ មកសៀមរាប ។ ទី ២ យើងផ្ទុះពីពោធិ៍សាត់ មកបាត់ដំបង ទាំងពីផ្លូវយើងចាប់ដៃជាមួយនឹងថៃ ។ ខាងកំពង់ធំយើងត្រូវរៀបរមីនគ្រាប់បែក សម្រាប់កាត់-ផ្លូវលេខ ៦ ពីកំពង់ចាម ហើយតាចាបថា ខាងកំពង់ធំយោធាមួយវរៈសេនាធំបុំណ្ណោះ យើងទប់ទល់បានហើយ ព្រោះកម្លាំងខាងយោធាភូមិភាគកណ្តាល-រវាល់តែជាប់ដៃជាមួយនឹងយួន សល់យើងដកមកវាយមិនបានបុំន្មានទេ ដូច្នោះមិនព្រួយបារម្ភទេ កម្លាំងពីមុខយើងមានកងទ័ពយើងហើយ កម្លាំងពីខាងក្រោយខ្ញុំបានទាក់ទងជាមួយនឹងថៃហើយ ឥឡូវយើងចាំមើលបញ្ជាពីបងញ៉ឹមពាយ័ព្យ -គាត់ជាអ្នកបញ្ជា ហើយម្យ៉ាងទៀត នៅខាងមិត្តផែន ឬមិត្តភាន ត្រូវ-

រកវិធីសម្លាប់មិត្តពក លេខាភូមិភាគកណ្តាល ពេលនោះដែរ បើតាមពិនិត្យកន្លងមក មិត្តពករករឿងកម្មាភិបាលមកពីនិរតីខ្លាំងណាស់ ខុសពីគំនិតរាយការណ៍ជូនអង្គការ ខុសអីបន្តិចចោទថាខ្មាំង គ្មានពិធីកសាង ដូចជាមានមិត្តណាខុស - ចោទយកទោសតែម្តង ហើយតាមមើលកម្មាភិបាលនិរតី ឃុំអាចអស់មិនខានៗ ដូច្នេះខាងមិត្តដែនឯងត្រូវរកវិធីសម្លាប់ឱ្យបាន ព្រោះមិត្តពកមកកំពង់ធំញឹក - ញាប់ ដោយចាក់ថ្នាំបំពុល នឹងដាក់ក្នុងបាយ - ទឹកក្តៅ - ទឹកដូងជាដើម ។ តាចាបនិយាយហើយ បងអានថា បងពកសព្វថ្ងៃនេះមិនពេញចិត្តពួកយើងពីនិរតីទេ ដូចជាមិត្តយុតទៅរកដំឡើងខាងភូមិភាគបស្ចិម គឺបងពកថា ស្រែកយើមិនចេញទៅរកខាងបស្ចិម ព្រោះភូមិភាគបស្ចិមនៅក្រ ។ ហើយគ្រាន់តែមិត្តឃុំរាយការណ៍ថាខ្វះនេះខ្វះនោះនៅក្នុងសហករណ៍ ថាឱ្យមិត្តឃុំអាក្រហ៊ុន បងអាននិយាយទៀតថា បើមិត្តនារីភឿក - មិត្តអុន - នឹងមិត្តនារីមកពីស្រែអំបិលត្រូវចាប់គ្នាដាក់គុកអត់ហេតុផលអីសោះ ។ ហើយខ្ញុំគឺយល់ទៅតាមយោបល់បងអានដែរ ហើយការប្រជុំនេះត្រូវចប់ ហើយខ្ញុំទាំងអស់គ្នាបានត្រឡប់មកវិញ មកដល់រៀបចំតាមផែនការតាចាប នៅថ្ងៃ ១៧ មេសា ឆ្នាំ ១៩៧៨ នេះ លុះជិតដល់ថ្ងៃផ្ទុះ ឃើញនិរសារតាចាបយកសំបុត្រមកប្រាប់បងអានថា ថ្ងៃផ្ទុះអាវុធនៅថ្ងៃ ១៧ មេសា ឆ្នាំ ១៩៧៨ត្រូវបរាជ័យហើយ ព្រោះបញ្ជាការខាងកងទ័ព នឹងគណៈបញ្ជាការកងទ័ព ត្រូវអង្គការចាប់មួយចំនួន ដូច្នេះផែនការផ្ទុះអាវុធត្រូវអាខាន ។ តែយើងនៅតែត្រៀមកម្លាំងសៀងជានិច្ច ។ រួចបងផែនឱ្យខ្ញុំទៅធ្វើសកម្មភាពនៅទំនប់ ៣០ កញ្ញា ខ្ញុំបានហៅឈ្មោះសាំ ភាត - គឹម - មកដាក់ផែនការឱ្យប្រមូលកម្លាំង ប្រជាជនទាំងអស់មករួមគ្នា - ចាក់ដីទៅនោះស្ទឹង ដើម្បីឱ្យទឹកហូរដាន់ទ្វារទឹកឱ្យបាក់ នឹងឱ្យលិចស្រូវប្រជាជនអស់ ៨០ហិកតានៅលើទំនប់ ក្រោយពីខ្ញុំណែនាំមកបងសាំ - បងភាតមិត្តគឹម ប្រមូលកម្លាំងមកវាយនៅលើពោះស្ទឹង ទឹកត្រូវទៀងដាន់ទ្វារធំបណ្តាលឱ្យបាក់ដីពីខាងក្រោមកន្លុយទ្វារហូរទៅជាស្ទឹង នឹងបាក់បេតុងពីខាងក្រោមទ្វាទឹកអស់ទទឹង ១០ម៉ែត្រ បណ្តោយ ៦០ម៉ែត្រ ជំរៅប្រហែល ១០ ម៉ែត្រ -

ក្រោយមកខ្ញុំបានចាត់តាំងបង សារ៉ំ ឱ្យបើកទ្វារទឹកតាមព្រែកដីក ខាងស្រុកកំពង់ស្វាយ ឱ្យលិចសំណាបអស់ ១០០ហិកតាទៀត នឹងឱ្យឈ្មោះ ភាគ- គីម យកដែកស្បែងចំពុះសរសេរទៅទំលុះផ្លូវជាតិលេខ ៦ ដាច់អស់មួយកង់ រំខានដល់ការដឹកជញ្ជូនគ្រាប់រំសេវទៅវាយយួន ។

នៅក្នុងខែ ៥ ឆ្នាំ ១៩៧៨ដែរ បងផែនគាត់ទៅផ្ទះខ្ញុំ គាត់បានណែនាំខ្ញុំឱ្យរកពីធីបំផ្លាញ ស្រូវកុំឱ្យសហករណ៍ឃ្លូតលាស់ទៅមុខបានតាមផែនការបក្ស ។ ក្រោយពីទទួលការណែនាំពីបងផែនមក ខ្ញុំបានឱ្យឈ្មោះ សាញ់-មិត្តវង់- នឹងមិត្តសៀន ទៅបំផ្លាញស្រូវក្នុងសហករណ៍ ក្នុងផែនការធ្វើ ស្រូវកន្លះដើមឆ្នាំ ចំនួន ២.០០០ហិកតា ឱ្យប្រជាជននៅឃុំសាគ្រាម- ឃុំពាក - ឃុំក្រសា- នឹងឃុំចំណាខាងកើត យកស្រូវកន្លះនេះទៅស្ទូងក្រោមទំនប់ ហើយ មិត្តសាញ់- មិត្តវង់- មិត្តសាន- បានទំលាយទំនប់ឱ្យលិចស្រូវ រលួយខូចអស់ទាំង- អស់ ២.០០០ហិកតា ហើយយកស្រូវទៅស្ទូងទៀត ខ្ញុំបានចាត់តាំងមិត្តសាញ់មិត្ត សៀន- មិត្តវង់ ទំលាយទំនប់នេះ ឱ្យលិចរលួយទាំង២២០០ហិកតានេះម្ដងទៀត

នៅចុងខែ ៥ ឆ្នាំ ១៩៧៨ ទឹកភ្លៀងត្រូវធ្លាក់ជោកជាំស្រែទាំង- អស់ ខ្ញុំទុកប្រជាជនចំនួន ៥.០០០នាក់ឱ្យនៅជីកព្រែក ជីកប្រឡាយ នៅឡើយ ខ្ញុំមិនឱ្យប្រជាជនចុះទៅធ្វើស្រែទេ ទុកព្យារពេលកុំឱ្យប្រជាជនធ្វើស្រែបាន ។

នៅដើមខែ ៥ ឆ្នាំ ១៩៧៨ ខ្ញុំយកក្របៅ ១០ហាប់ទៅព្រួស ខ្ញុំបាន ចាត់តាំងមិត្តគីម- ឱ្យយកគ្រាប់ក្របៅនោះទៅព្រួសលើទឹក ឱ្យក្របៅ រលួយខូចអស់ ៨៥ហិកតា ។ បន្ទាប់មកខ្ញុំបានចាត់តាំងមិត្ត ភួក- មិត្តសៀន- មិត្តវង់- ឱ្យប្រជាជននៅឃុំសំព្រោជ- ឃុំកំពង់ចិនខាងជើង- នឹងឃុំកំពង់ចិនខាង- ត្បូង យកស្រូវពន្លកមកព្រួស លើភាងទឹកមួយវិច្ឆិការ ពេលស្រូវកំពុងដុះល្អូត លាស់ល្អ ខ្ញុំបានចាត់តាំងមិត្តគីម ឱ្យបើកទ្វារទឹកទំនប់ លិចរលួយស្រូវអស់១,៥០០ ហិកតា ។ នៅរដូវធ្វើស្រែ ខែ ៥ ឆ្នាំ ១៩៧៨ ខ្ញុំបានលើកផែនការបំផ្លាញ

តាមការណែនាំរបស់បងផែន ខ្ញុំបានចាត់តាំងមិត្ត សៀន - មិត្តសាញ់នឹងមិត្តវង់ ឱ្យដើរប្រាប់ប្រជាជននៅគ្រប់ឃុំ កំណត់ឱ្យសាបស្រូវមួយហិកតា ៣០ថាំង គឺឱ្យដើមសំណាបដុះដើមល្អិត ហើយឆាប់ថ្នាំងផង និងឱ្យឆាប់អស់ស្រូវជួពងផល់ពេលមានទឹកខ្ញុំបញ្ជាឱ្យដកសំណាបនោះទៅស្ទូង និងឱ្យភ្ជួរតែមួយជើងនង្គ័ល ហើយទៅស្ទូង ហើយសន្ទូងនោះទៀងប្រាកភ្លើងខូចអស់ ៣.០០០ហិកតា បានផល់មួយហិកតាតែ ៤.៥ បាវប៉ុណ្ណោះ ខ្ញុំធ្វើឱ្យប្រជាជនកាន់តែអត់បាយ ហើយឱ្យប្រជាជនកាន់តែមានទំនាស់ជាមួយនឹងអង្គការបដិវត្តពីទៀងខ្វះបាយ ។

នៅដើមខែ ៦ ឆ្នាំ ១៩៧៨ បងផែនបានទៅផ្ទះខ្ញុំ គាត់ហៅខ្ញុំ - ទៅនិយាយថា សព្វថ្ងៃនេះនៅក្នុងស្រុកស្វាង កម្មសិទ្ធឯកជន នឹងរបបសមូហភាពណាធ្ងន់ជាងណា ខ្ញុំថារបបសមូហភាពធ្ងន់ជាងរបបឯកជនបន្តិច បងផែននិយាយថា ធ្វើបដិវត្តសង្គមនិយម គេមិនសំដៅហូបបាយរួមដាក់របស់របរួមនោះទេ - គឺគេសំដៅត្រង់តែសំបូរសប្បាយប៉ុណ្ណោះ ដូច្នេះយើងកុំតឹងពេក យើងឱ្យ- ប្រជាជនរកស៊ីខ្លះទៅ ព្រោះរបបឯកជននេះគង់តែធ្លាក់មកលើទិសយើង ទេ ហើយឱ្យប្រជាជនធ្វើបណ្តើរៗទៅ ក្រោយពីការណែនាំមក ខ្ញុំហៅមិត្តសៀន- នឹងមិត្ត រុន មិត្តមិន មកដាក់ផែនការ តាមការណែនាំរបស់បង ផែន ខ្ញុំថា មិត្តទាំងអស់ទៅបំផុសប្រជាជននៅឃុំកំពង់ចិនខាងត្បូង - ឃុំកំពង់ចិនខាងជើង - នឹងឃុំមន្រាគ្រង ឱ្យប្រជាជនរកស៊ីឯកជនវិញ ព្រោះធ្វើសមូហភាពមិនសំបូរ ទេ ថែមទាំងចុះក្រទៅៗ ។ រួចហើយចែកចានឆ្នាំងមាន់ទា នឹងដំណាំ ដៀងពុតាមផ្ទះវិញទាំងអស់ ម្យ៉ាងទៀតនៅតាមផ្ទះបាយរួម ខ្ញុំឱ្យដាំបាយ ចែកទៅហូបតាមផ្ទះ ឯខ្ញុំមិនអើពើលើការខ្វះខាតរបស់ប្រជាជនទេ នឹងរិត តែជំរុញឱ្យទៅឯកជន ៗ ក្នុងខែ ៦ ឆ្នាំ ១៩៧៨ ខ្ញុំនឹងមិត្ត សាញ់ បានទៅ បំផុសប្រជាជននៅឃុំចំណាខាងកើត កំពុងធ្វើនង្គ័ល ខ្ញុំសួរបងប្អូននៅទីនោះ- ថា ពីការរស់នៅឯកជន នឹងសមូភាព បងប្អូនក៏ឆ្លើយថា សមូហភាពគ្នាច្រើន ហើយលំបាកដោះស្រាយណាស់ បើតាមគ្រួសារយើងនៅតាមផ្ទះហូបស្រួល ហើយ គ្មានលំបាកអ្វីទេដូចសព្វថ្ងៃនេះ ៗ ខ្ញុំបានបំផុសប្រជាជនដូច្នេះចលនានេះសុសសាយ

ពាស់ពេញទាំងស្រុក ហើយបណ្ដាឯកជនសព្វថ្ងៃនេះ នៅក្នុងស្រុកស្លាងគឺមានទូទៅ ។ ម្យ៉ាងទៀតខ្ញុំបានឲ្យប្រជាជនពង្រីកដីភូមិ ជុំវិញផ្ទះគ្រួសារមួយៗ ហើយមានដីស្រែក្នុងនោះមួយម្នាក់ពីផង សម្រាប់ស្ទូងយកផលក្នុងគ្រួសារគេ ហើយខ្ញុំបានណែនាំឲ្យចាស់ៗថែរក្សាព្រះ ច្បេសប្រដះវិហា ហើយខ្ញុំបានទុកវិហា-កុដិសាលាជាច្រើនមិនឲ្យប្រជាជនរុះរើទេសំរាប់បន្តិតសាសនាទៀងវិញ ។ ដូចជានៅឃុំកំពង់ចិនខាងត្បូង កំពង់ចិនខាងជើង និង នៅឃុំប្រទ្បាយពពកជាដើម ។

សកម្មភាពបំផុប្រជាជនឲ្យទៅឯកជននេះ ខ្ញុំមិត្តមិន មិត្តសៀន មិត្តសាញ់ មិត្តភួក និង មិត្តវ៉ង់ គឺបានបលនាតាមភូមិ ឃុំ និងថែបកជារបស់វេបឲ្យទ្រ្បីឯកជនធ្វើឲ្យលោកខាំធ្វើស្រែមិនសំរេចតាមផែនការរបស់បក្ស ហើយក៏ឲ្យប្រ-ជាជនមានជំងឺស្សើបជិវត្ត ហើយម្យ៉ាងទៀតឲ្យប្រជាជនឃើញតែឯកជនស្រួល សម្បូណភាពលំបាក់តឹងតែង ។

